# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំសាន់គ
# ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២





រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកំពង់ស្វាយ

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC) , ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា


អារម្ភកថា ........ VII

សេចក្តីផ្តើម ........ 1

ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពឃុំសាន់គ........ 3

១.១.ស្ថានភាពឃុំ........ 3

១.១.១.ទីតាំងរដ្ឋបាលឃុំ ........ 3

ក.ចំនួនប្រជាជន........ 5

ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន........ 7

គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ........ 8

ឃ.របររកទទួលទាន ........ 8

ង.ចំណូលស្រុក និងចំណាកស្រុក ........ 10

១.១.៣.ស្ថានភាពសេដ្ឋកិច្ច........ 11

ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ........ 11

ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ........ 11

គ.ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ ........ 13

ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ........ 14

ង.ចំណូលពីប្រភពផ្សេងៗ ........ 14

១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ ........ 14

ក.ស្ថានភាពអប់រំ........ 14

ខ.ស្ថានភាពអក្ខរកម្ម........ 15

គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត........ 16

១.១.៥.ស្ថានភាពសុខាភិបាល........ 17

១.១.៦.ស្ថានភាពយេនឌ័រ........ 19

១.២.ស្ថានភាពភូមិសាស្ត្រ........ 21

១.២.១.ទីតាំងភូមិសាស្ត្រ........ 21

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)........ 29

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន........ 30

១.២.៤.បរិក្ខាសាធារណៈ ..... 32
ក.ស្ថានភាពប្រើប្រាស់អគ្គិសនី ..... 32
ខ.ប្រព័ន្ធទឹកស្អាត ..... 32
**១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ..... 33
១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង ..... 33
ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ ..... 36
ក.១.ដីលំដីលំនៅឋាន ភូមិ ..... 36
ខ.ដីកសិកម្ម ..... 37
ខ.១.ដីស្រែវស្សា ..... 37
ខ.២.ដីស្រែប្រាំង ..... 38
គ.ព្រៃគុម្ពោត/តម្របព្រៃ ..... 39
គ.១.ព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ ..... 39
គ.២.ព្រៃលិចទឹក ..... 40
ង.ផ្ទៃទឹក និងខ្សែទឹក ..... 40
ង.១.ដីបឹង ..... 40
ង.២.អាងស្តុកទឹក ..... 41
ង.៣.ស្រះទឹក ..... 42
១.៣.២.ផលិតកម្មកសិកម្ម ..... 43
ក.ផលិតកម្មដំណាំស្បៀង ..... 43
ខ.ផលិតកម្មដំណាំរួមផ្សំ ..... 44
គ.ផលិតកម្មខ្វស្សាហកម្ម ..... 45
១.៣.៣.ធនធានធម្មជាតិ ..... 45
ក.ធនធានព្រៃឈើ ..... 45
ខ.ធនធានជលផល ..... 46
១.៣.៤.ធនធានរ៉ែ ..... 46
**១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ..... 46

១.៨.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ 46
១.៨.២.ខ្សែសង្វាក់ និងចរាចរផលិតផល 47
**ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត** 50
**២.១.តម្រូវការសម្រាប់អនាគត** 50
២.១.១.ផែនការអភិវឌ្ឍឃុំ 50
ក.ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ (២០១៨-២០២២) 50
ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច 53
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ 54
២.១.៣.តម្រូវការដីជាមូលដ្ឋាន 56
ក.ដីលំនៅឋាន 56
ខ.ដីកសិកម្ម 57
គ.ដីព្រៃឈើ 57
ឃ.ធនធានទឹក 58
ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណ:ផ្សេងៗទៀត 58
ង.១.វិស័យអប់រំ 58
ង.២.សម្រាប់វិស័យសុខាភិបាល 60
ង.៣.អគ្គិសនី 60
ង.៤.ទីលានចាក់សំរាម 61
ង.៥.ដីកប់ខ្មោច 61
ង.៦.ស្រះ និងអណ្តូងទឹក 61
**២.២.តំបន់សើប** 62
២.៣.១.ការប្រឈមដោយធម្មជាតិ 63
ក.កំណើនប្រជាជន 63
ខ.គ្រោះធម្មជាតិ ការអេចរឹលនៃធម្មជាតិ 63
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព 63
**២.៤.ឱកាស** 64

២.៤.១.ដោយអំណោយផលពីធម្មជាតិ 64

២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ 64

២.៤.៣.ដោយគម្រោងវិនិយោគ 65

**២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ 65**

**ជំពូក៣៖ ផែនការប្រើប្រាស់ដីអនាគតឆ្នាំ២០១៧-២០៣២ 69**

**៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង 69**

៣.១.១.តម្រូវការដីទៅតាមប្រភេទ 69

៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល 69

**៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់ 70**

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ 70

៣.២.២.ផែនទីប្រើប្រាស់ដីអនាគត 72

៣.២.៣.សេចក្តីអត្ថាធិប្បាយ 74

ក.ដីលំនៅឋានតូមិ 74

ខ.ដីស្រែវស្សា 74

គ.ដីស្រែប្រាំង 75

ង.ដីព្រៃលិចទឹក 77

ច.ដីបឹង 77

ឆ.ដីអាងស្តុកទឹក 78

ជ.ស្រះទឹក 78

**៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី 79**

**៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 79**

៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព 79

ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម 79

ខ.ការគ្រប់គ្រងព្រៃឈើ ផលផល និង ធនធានសំខាន់ៗផ្សេងៗទៀត 81

៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព 81

**៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២) 82**

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ ..... 3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្ដាភូមិ ..... 6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ ..... 7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្ដាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម ..... 8
តារាង 5៖ តារាងមុខរបរ ..... 8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ..... 10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្ដូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ ..... 10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក ..... 11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន ..... 12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧ ..... 15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ..... 16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ..... 16
តារាង 13៖ សុខភាពមាតា និងទារក ..... 17
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ..... 19
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ..... 20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំសាន់គ ស្រុកកំពង់ស្វាយ ..... 24
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ ..... 28
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ..... 30
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន ..... 31
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី ..... 32
តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់ ..... 32
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីនីមួយៗ ..... 35
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 43
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 44
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 45
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ..... 46
តារាង 27៖ស្ថិតិផលិតផលស្រូវ និងតម្លៃ ..... 47
តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល ..... 49
តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត ..... 50
តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) ..... 55
តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) ..... 55

តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២ ........ 56
តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២ ........ 57
តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ ........ 59
តារាង 35៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ........ 65
តារាង 36៖ តារាងផែនការប្រើប្រាស់ដីនាពេលអនាគត ........ 71
តារាង 37៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត ........ 71
តារាង 38៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត ........ 72

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧ ........ 6
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព ........ 19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ........ 30

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងឃុំសាន់គ ស្រុកកំពង់ស្វាយ ........ 4
ផែនទី 2៖ រដ្ឋបាលឃុំសាន់គ ........ 5
ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំសាន់គ ........ 22
ផែនទី 4៖ បង្ហាញពីតំបន់ក្សេត្រ-បរិស្ថានឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ........ 23
ផែនទី 5៖ ប្រព័ន្ធស្រោចស្រព ឃុំសាន់គ ........ 29
ផែនទី 6៖ ហេដ្ឋារចនាសម្ព័ន្ធឃុំសាន់គ ........ 31
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំសាន់គ ........ 33
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំសាន់គ ........ 34
ផែនទី 9៖ គម្រោងវិនិយោគជាអាទិ៍ភាពឃុំសាន់គ ........ 54
ផែនទី 10៖ ផែនទីតំបន់រសើបឃុំសាន់គ ........ 62
ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ ........ 68
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតឃុំសាន់គ ........ 73

## បញ្ជីរូបភាព

រូបភាព 1៖ សាលារៀន ........ 14
រូបភាព 2៖ មណ្ឌលសុខភាពឃុំសាន់គ ........ 18
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ ........ 28
រូបភាព 4៖ ប្រព័ន្ធផ្លូវ ........ 31
រូបភាព 5៖ លំនៅឋានភូមិ ........ 36

រូបភាព 6៖ ស្រូវវស្សា......................................................................................................37
រូបភាព 7៖ ស្រូវប្រាំង ......................................................................................................39
រូបភាព 8៖ ព្រៃគុម្ពោត និងវាលស្មៅ ......................................................................................39
រូបភាព 9៖ ព្រៃលិចទឹក.....................................................................................................40
រូបភាព 10៖ បឹងធម្មជាតិ .................................................................................................. 41
រូបភាព 11៖ អាងស្តុកទឹក ..................................................................................................42
រូបភាព 12៖ ស្រះទឹក........................................................................................................42
រូបភាព 13៖ ដំណាំស្រូវ ....................................................................................................44
រូបភាព 14៖ ដំណាំរួមផ្សំ ..................................................................................................45

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ ក្នុងការជួយទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបទៅដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រង និងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយដល់ទៅជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ សម្រាប់ការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុកនិងធ្វើការអនុម័តនៅថ្នាក់រាជធានី/ខេត្តទៅតាមនីតិវិធី ដូចដែលធ្លាប់អនុវត្តក្នុងការកសាងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ មានចក្ខុវិស័យរហូតដល់ឆ្នាំ២០៣២ ដែលក្រុមការងារបានខិតខំប្រឹងប្រែងធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី(ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុន ផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោង និងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកកំពង់ស្វាយ ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងឃុំសាន់គនេះ។ យើងខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គនេះនឹងបានចូលរួមចំណែកទៅដល់ការអភិវឌ្ឍឃុំប្រកបទៅដោយចីរភាពថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់៕

ថ្ងៃ ច័ន្ទ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សាន់គ ថ្ងៃទី ២១ ខែ ១១ ឆ្នាំ ២០២០

**ប្រធានក្រុមប្រឹក្សាឃុំ និងជា**

**មេឃុំសាន់គ**

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិយាកាសណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកទៅតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវនឹងបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មផែនការយុទ្ធសាស្រ្តរៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធានឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ។

ឃុំសាន់គ ជាឃុំមួយនៅក្នុងចំណោមឃុំទាំង១១ ស្ថិតក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានតំបន់លំនៅឋានមួយផ្នែក និងមួយផ្នែកទៀតជាតំបន់កសិកម្ម មានផ្ទៃដីសរុបចំនួន ២២ ២២០,៤៤ហិកតា ព្រមទាំងមានព្រំប្រទល់ខាងជើងជាប់នឹងឃុំដំរីស្លាប់ ខាងត្បូងជាប់នឹងឃុំកំពង់គោ ខាងកើតជាប់នឹងឃុំត្បែង និងខាងលិចជាប់នឹងឃុំចំណាក្រោម និងឃុំចំណាលើ ស្រុកស្ទោង ហើយមានប្រជាជនសរុបចំនួន ១៨ ៩៧១នាក់ ក្នុងនោះស្រ្តី ៩៦៧៨នាក់ ដែលប្រជាជន ៨២ភាគរយ ជាកសិករ។ ឃុំសាន់គមានផ្ទៃដីស្រែសរុប ១៨ ១៦៦,១៣ ហិកតា ជាទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៨២ភាគរយ នៃផ្ទៃដីសរុបរបស់ឃុំ និងជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំសាន់គ ប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍឃុំសាន់គ ប្រកបទៅដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ព្រមទាំងក្រុមប្រឹក្សាឃុំសាន់គ ក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេស ដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានការគាំទ្រ និងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍអាស៊ី ដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសទៅដល់ការអភិវឌ្ឍឃុំ ពាក់ព័ន្ធនឹងការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ឆ្លើយតបនឹងកំណើនប្រជាសាស្រ្ត ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ នៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំសាន់គ ឱ្យអស់ពីសក្តានុពល ដែលមានក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើន នាពេលខាងមុខ ដែលអាចឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល សល់ពីការហូបចុកតាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គនេះ ធ្វើជាមូលដ្ឋានបង្អែក សម្រាប់រៀបចំផែនការអភិវឌ្ឍឃុំនៅតាមអាណត្តិនីមួយៗរបស់ខ្លួន។

ផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ត្រូវបានរៀបចំឡើង ដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្រ្ត សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិត

បទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតការសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។ ចំពោះនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់ដីនេះវិញ ត្រូវបានរៀបចំឡើង ដោយផ្អែកលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិត សម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពី ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ មានដំណើរការរៀបចំផែនការ ដូចមាន សង្ខេបក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ▭ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពឃុំសាន់គ

## ១.១.ស្ថានភាពឃុំ

យុំសាន់គមានរឿងរ៉ាវដំណាលតៗគ្នាមកថា កាលពីដើមឡើយនៅក្នុងឃុំនេះ មានគងដ៏ធំមួយស្ថិតនៅកប់ក្នុងបឹងមួយកន្លែង។ ក្រោយពីប្រជាពលរដ្ឋបានឃើញគងធំនេះក៏នាំគ្នាត្បាញខ្សែ ដើម្បីចងអូសគងនោះចេញពីបឹង រួចសែងយកទៅតំកល់ទុកនៅកន្លែង ដែលមានសុវត្ថិភាព ដោយបានសាងសង់រោងមួយ ដើម្បីរក្សាការពារទុកកុំឱ្យខូចផង និងគោរពបូជាដល់បុព្វបុរស ដែលបានកសាងគងនោះផង។ ក្រោយមកប្រជាពលរដ្ឋនៅទីនោះបានដាក់ឈ្មោះតំបន់នោះថាភូមិសែងគង តែតំណក្រោយៗមកទៀតភូមិនេះ ក៏ក្លាយទៅជាភូមិសាន់គ ទៅតាមសំនៀងអ្នកស្រុកទៅវិញ ដែលមកដល់បច្ចុប្បន្ននេះ ក៏បានក្លាយទៅជាឃុំសាន់គ នៅពេលដែលរាជរដ្ឋាភិបាលបានបង្កើតជាឃុំ (ប្រកាសលេខ៤៩៣ប្រ.ក/៣០-មេសា-២០០១)។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ទីតាំសាលាឃុំសាន់គ ស្ថិតនៅភាគខាងលិចនៃទីរួមខេត្តកំពង់ធំ ដែលមានចម្ងាយប្រហែលជា ២៥គីឡូម៉ែត្រ។ ជាឃុំមួយក្នុងចំណោមឃុំទាំង១១ ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់រដ្ឋបាលស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ឃុំសាន់គ មានចំនួន១៤ភូមិ ដូចជា៖ ភូមិប្រាសាទ ភូមិបាឡាំង ភូមិតាំងក្រូច ភូមិវាល ភូមិជ័យ ភូមិស្លែងខ្ពស់ ភូមិសារី ភូមិសំពៅមាស ភូមិក្បៀល ភូមិអំពិល ភូមិសាន់គ ក ភូមិសាន់គ ខ ភូមិក្រសាំង ក និងភូមិក្រសាំង ខព្រមទាំងមានផ្ទៃដីសរុបចំនួន ២២២០៦ ហិកតា និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹង ឃុំដំរីស្លាប់
- ខាងត្បូង ជាប់នឹង ឃុំកំពង់គោ
- ខាងកើត ជាប់នឹង ឃុំត្បែង
- ខាងលិច ជាប់នឹង ឃុំចំណាក្រោមនិង ឃុំចំណាលើ ស្រុកស្ទោង។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| ខេត្ត | កំពង់ធំ | លេខកូដខេត្ត:៦ |
|---|---|---|
| ស្រុក | កំពង់ស្វាយ | លេខកូដស្រុក: ៦០២ |
| ឃុំ | ឃុំសាន់គ | លេខកូដឃុំ: ៦០២០៧ |
| ចំនួន១៤ភូមិ | ១. ភូមិប្រាសាទ | លេខកូដភូមិ: ៦០២០៧០១ |
| | ២. ភូមិបាឡាំង | លេខកូដភូមិ: ៦០២០៧០២ |
| | ៣. ភូមិតាំងក្រូច | លេខកូដភូមិ: ៦០២០៧០៣ |
| | ៤. ភូមិវាល | លេខកូដភូមិ: ៦០២០៧០៤ |
| | ៥. ភូមិជ័យ | លេខកូដភូមិ: ៦០២០៧០៥ |
| | ៦. ភូមិស្លែងខ្ពស់ | លេខកូដភូមិ: ៦០២០៧០៦ |
| | ៧. ភូមិសារី | លេខកូដភូមិ: ៦០២០៧០៧ |
| | ៨. ភូមិសំពៅមាស | លេខកូដភូមិ: ៦០២០៧០៨ |
| | ៩. ភូមិក្បៀល | លេខកូដភូមិ: ៦០២០៧០៩ |
| | ១០. ភូមិអំពិល | លេខកូដភូមិ: ៦០២០៧១០ |

| | | |
|---|---|---|
| | ១១. ភូមិសាន់គ ក | លេខកូដភូមិៈ ៦០២០៧១១ |
| | ១២. ភូមិសាន់គ ខ | លេខកូដភូមិៈ ៦០២០៧១២ |
| | ១៣. ភូមិក្រសាំង ក | លេខកូដភូមិៈ ៦០២០៧១៣ |
| | ១៤. ភូមិក្រសាំង ខ | លេខកូដភូមិៈ ៦០២០៧១៤ |

*ប្រភពៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំសាន់គ ស្រុកកំពង់ស្វាយ



ផែនទី 2៖ រដ្ឋបាលឃុំសាន់គ




## ១.១.២.ប្រជាសាស្ត្រ

### ក.ចំនួនប្រជាជន

នៅក្នុងឃុំសាន់គ ចែកចេញជា ១៤ ភូមិ ដែលមានគ្រួសារសរុបចំនួន ៣ ៦៩៩ គ្រួសារ ប្រជាជនសរុបចំនួន ១៨ ៩៧១ នាក់ និងស្ត្រី ៩ ៦៧៨ នាក់ ក្នុងនោះប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ១០ ១៥៣នាក់ ស្រីចំនួន ៥ ១៥៣នាក់។ ភូមិដែលមានប្រជាជនច្រើនជាងគេនៅក្នុងឃុំសាន់គ គឺភូមិក្រសាំង ក មាន ៥៣៦គ្រួសារ ស្មើនឹង ១១,៨ ភាគរយ មនុស្សសរុបចំនួន ២ ៣៣៩ នាក់ ក្នុងនោះស្ត្រីចំនួន ១ ២២៥នាក់។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ១១៩១នាក់ ក្នុងនោះស្រីចំនួន ៦១៩នាក់ ចំណែកភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិសាន់គ ក មានគ្រួសារសរុបចំនួន ៨៥ គ្រួសារ ស្មើនឹង ២,៣ ភាគរយ ប្រជាជនសរុបចំនួន ៥០៤នាក់ ក្នុងនោះមានស្ត្រី ២៦៥នាក់។ ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ៣៧៩នាក់ នៅក្នុងនោះស្រីចំនួន ១៩៩នាក់។ ទន្ទឹមនឹងនេះ ក៏សង្កេតឃើញថាប្រជាជននៅក្នុងឃុំ ស្ត្រីមានចំនួនច្រើនជាងបុរស ដូចមាន ក្នុងតារាងដែលក្រុមការងារបានរៀបចំសង្ខេបខាងក្រោម។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ប្រាសាទ | ១៧២ | ៤,៦ | ៨២៨ | ៤១២ | ៤១៦ | ៤៦៥ | ២២៦ | ២៣៩ |
| បាឡាំង | ១៦៨ | ៤,៥ | ៧៦៨ | ៣៧៥ | ៣៩៣ | ៣៩៣ | ១៩៩ | ១៩៤ |
| តាំងក្រូច | ១១៣ | ៣,១ | ៦៨៣ | ៣៣៩ | ៣៤៤ | ៣០២ | ១២៧ | ១៧៥ |
| វាល | ១៩៤ | ៥,២ | ១២១៩ | ៥៨៣ | ៦៣៦ | ៦៣៩ | ៣១៧ | ៣២២ |
| ជ័យ | ១៧៧ | ៤,៨ | ៨៣១ | ៤១៧ | ៤១៤ | ៥៣៩ | ២៨១ | ២៥៨ |
| ស្លែងខ្ពស់ | ១៥៨ | ៤,៣ | ៨៦៤ | ៤៧៨ | ៣៨៦ | ៤៩៩ | ២៣៥ | ២៦២ |
| សារី | ២៣២ | ៦,៣ | ១១៥៧ | ៥៤២ | ៦១៥ | ៨១៧ | ៣៦៩ | ៤៤៨ |
| សំពៅមាស | ៣៧៤ | ១០,១ | ១៨៤៧ | ៨៧៩ | ៩៦៨ | ៩០៨ | ៤៤០ | ៤៦៨ |
| ក្បៀល | ៤៥៥ | ១២,៣ | ២២៣៣ | ១១៨៩ | ១០៤៤ | ១២២០ | ៧២០ | ៥០០ |
| អំពិល | ១០៨ | ២,៩ | ៦៧៦ | ២៩២ | ៣៨៤ | ២៦១ | ៩៤ | ១៦៧ |
| សាន់គ ក | ៨៥ | ២,៣ | ៥០៤ | ២៣៩ | ២៦៥ | ៣៧៩ | ១៨០ | ១៩៩ |
| សាន់គ ខ | ៥៤៧ | ១៤,៨ | ២៨៩១ | ១៣៦៦ | ១៥២៥ | ១២៧៧ | ៦០៦ | ៦៧១ |
| ក្រសាំង ក | ៤៣៨ | ១១,៨ | ២៣៣៩ | ១១១៤ | ១២២៥ | ១១៩១ | ៥៧២ | ៦១៩ |
| ក្រសាំង ខ | ៤៧៨ | ១២,៩ | ២១៣១ | ១០៦៨ | ១០៦៣ | ១២៦៣ | ៦៣២ | ៦៣១ |
| **សរុប** | **៣៦៩៩** | **១០០** | **១៨៩៧១** | **៩២៩៣** | **៩៦៧៨** | **១០១៥៣** | **៤៩៩៨** | **៥១៥៣** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

បើយោងទៅតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុក្នុងឆ្នាំ២០១៧ ខាងក្រោម បានបង្ហាញឱ្យឃើញថា ប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ឆ្នាំ ដល់ ៦០ឆ្នាំ មានចំនួន ២ ១០២នាក់ ស្មើប្រហាក់

ប្រហែល ៤២ ភាគរយ នៃប្រជាជនសរុប ក្រៅពីនេះមានអាយុពីកើតដល់ ២៤ឆ្នាំ មានចំនួន ២ ៦៣០នាក់ ស្មើប្រហាក់ប្រហែល ៥៣ ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំឡើង ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងារមានចំនួន ២៥៤ នាក់ ស្មើប្រហាក់ប្រហែល ៥ ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងឃុំសាន់គ មនុស្សពេញកម្លាំងពលកម្មមួយនាក់រកចំណូលបានគិតជាមធ្យម ត្រូវចិញ្ចឹមមនុស្ស បន្ថែមមួយនាក់លើសបន្តិច។

តារាង ៣៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| តាមក្រុមអាយុ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ១០៥១ | ៥១៣ | ៥៣៨ | កុមារ |
| អាយុពី៣-៤ | ៩៥២ | ៤៤៥ | ៥០៧ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៦៤០ | ៣១៤ | ៣២៦ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៦៤៣ | ២៨៧ | ៣៥៦ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ២០០៩ | ១០៥២ | ៩៥៧ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ១៧៣៩ | ៨៣៣ | ៩០៦ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ១៧៨៤ | ៨៥១ | ៩៣៣ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ២១១៣ | ១០៣២ | ១០៨១ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២២៤៨ | ១១០២ | ១១៤៦ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ២២៩១ | ១១១៦ | ១១៧៥ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ១៨៣១ | ៩១០ | ៩២១ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ១៦៧០ | ៨៣៨ | ៨៣២ | អាយុចូលនិវត្តន៍ |
| **សរុប** | **១៨៩៧១** | **៩២៩៣** | **៩៦៧៨** | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន ១,៥៥ ភាគរយ ដោយសង្កេតឃើញថា មានការធ្លាក់ចុះច្រើននៅក្នុងឆ្នាំ ២០១៦ គឺមានអត្រាកំណើនប្រជាជនចំនួន -០,១០ ភាគរយ មូលហេតុនៃការធ្លាក់ចុះនេះ គឺដោយសារមានការផ្លាស់ប្តូរលំនៅឋានចេញ ការចំណាកស្រុក ការពន្យាកំណើត មរណភាពកុមារ និងដោយកត្តាគ្រោះថ្នាក់ចរាចរណ៍ និងជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននៅក្នុងឆ្នាំ២០១៧ មានការកើនឡើងខ្លាំងវិញ គឺមានចំនួន ២,១០ភាគរយ ហើយមូលហេតុនៃការកើនឡើងនេះដោយសារតែមានការផ្លាស់ប្តូរទីលំនៅចូលតាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី។ តែបើពិនិត្យទៅការធ្វើជំរឿនទូទៅនៅក្នុងឆ្នាំ២០១៩ បានឱ្យដឹងថា អត្រាកំណើនប្រជាជន ជាមធ្យមក្នុងអំឡុង ១០ឆ្នាំ ២០០៨-២០១៨ នៅខេត្តកំពង់ធំមានចំនួន ០,៦ ភាគរយ ។ ដូច្នេះ យើងអាចកំណត់យកអត្រាកំណើនប្រជាជន ជាមធ្យមប្រចាំឆ្នាំនៅក្នុងឃុំសាន់គ ចំនួន ១,៥៥ ភាគរយ ជាបានការដើម្បីប្រើប្រាស់ក្នុងការព្យាករណ៍កំណើនប្រជាជនក្នុងឃុំ ។

នៅក្នុងឃុំសាន់គ នៅក្នុងឆ្នាំ២០១៧ មានដង់ស៊ីតេប្រជាជនរស់នៅចំនួន ៨៤ នាក់/គម² ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើន បានតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងឃុំ ជាពិសេសនៅតាមដងផ្លូវជាតិលេខ៦។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្ដាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម% |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជសរុប | ១៧៥៧០ | ១៨០៣០ | ១៨៥០៣ | ១៨៥៩៩ | ១៨៥៨០ | ១៨៩៧១ | |
| កំណើនមធ្យម(%) | | ២,៦២ | ២,៦២ | ០,៥២ | -០,១០ | ២,១០ | ១,៥៥ |

☞**ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង) x ១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយ/ចំនួនឆ្នាំ)

### គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំសាន់គ មានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងមានតិចតួចកាន់សាសនាគ្រិស្ត ដែលពួកភាគច្រើនគោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរ ដូចជា ពិធីរៀបមង្គលការ ប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាម តាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមានប្រជាជនតិចតួចមានទំនៀមទម្លាប់បែបចិន ដូចជា ពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព ចំណែកប្រជាជនមួយចំនួនតូចទៀតកាន់ទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជា មានប្រារព្ធពិធីចូលព្រះវិហារគ្រិស្ត នៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ និយាយរួមប្រជាជនក្នុងឃុំសាន់គ តែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទម្លាប់ពីបុរាណរៀងមក តាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រិស្តសាសនា។

### ឃ.របររកទទួលទាន

បើយោងទៅតាមទិន្នន័យនៅក្នុងតារាងមុខរបរខាងក្រោម បានបង្ហាញឱ្យឃើញថា ឃុំសាន់គទាំងមូលមានប្រជាពលរដ្ឋមានមុខរបរចម្បងចំនួន ៨ ៥៣៧នាក់ នៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្មជាចម្បង ដែលមានរហូតដល់ចំនួន ៧ ០១២ នាក់ ស្មើនឹង ៨២,១ ភាគរយ ចំណែកមុខរបរសិប្បកម្ម ជាចម្បងមានចំនួន ៨ នាក់ ស្មើនឹង ០,១ ភាគរយ និងសេវាកម្មជាចម្បងមានចំនួន ១ ៥១៧ នាក់ ស្មើនឹង ១៧,៨ ភាគរយ ដែលមុខរបរទាំងអស់នោះមានដូចជា ធ្វើស្រែ អាជីវករលក់ដូរ ចិញ្ចឹមសត្វ ដាំដំណាំ នេសាទត្រី កម្មករសំណង់ ស៊ីឈ្នួលដកស្ទូង ហាលស្រូវ ច្រកស្រូវ លីស្រូវ លក់ដូរ (បបរ នំបញ្ចុក ចេកចៀន) ជាងជួសជុលកង់ ម៉ូតូ រថយន្ត ជាងកាត់ដេរ ជាមន្ត្រីរាជការ ធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | ២០១៧ |
|---|---|
| សរុបអ្នកមានមុខរបរចម្បង | ៨៥៣៧ នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | ១០០,៦ % |
| %ស្រីមានមុខរបរចម្បង(គឺតក្នុងស្រី១៨-៦០ឆ្នាំ) | ៧៧,៥ % |
| %ប្រុសមានមុខរបរចម្បង(គឺតក្នុងប្រុស១៨-៦០ឆ្នាំ) | ៩០,៩ % |

| បរិយាយ | | ២០១៧ |
|---|---|---|
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | **៧០១២ នាក់** |
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម( គិតក្នុងមុខរបរចម្បង )** | | **៨២,១ %** |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម( គិតក្នុងមុខរបរចម្បង )** | | **៣៨,៣ %** |
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | ៦៨,៩ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ០,២ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ៣,៩ % |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ០,៩ % |
| | %អ្នកមានមុខរបរនេសាទ | ៣ % |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ៥,៣ % |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ០,០ % |
| **សរុបអ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសិប្បកម្ម** | | ៨ នាក់ |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,១ %** |
| **%ស្រីបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **០,០ %** |
| ក្នុងនោះ | %អ្នកបម្រើការងារសិប្បកម្មត្បាញរវៃ | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីផ្តៅ វល្លិ ល្ពាក់... | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតគ្រឿងសង្ហារឹម | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់... | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | ០,១ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតពីជ័រ ប្លាស្ទិក... | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មកែច្នៃ ឬ វេចខ្ចប់គ្រាប់ធញ្ញជាតិ | ០,០ % |
| | %អ្នកបម្រើការងារសិប្បកម្មផលិតផ្សេងៗ | ០,០ % |
| **សរុបអ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ១៥១៧ នាក់ |
| **%អ្នកបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ១៧,៨ % |
| **%ស្រីបម្រើការងារ( មុខរបរចម្បង ) ក្នុងផ្នែកសេវាកម្ម** | | ៨,៥ % |
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | ១,៦ % |
| | %អ្នកបម្រើការងារជាជាងជួសជុល | ០,៤ % |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | ០,២ % |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៤,៨ % |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន( កម្មកររោងចក្រ បុគ្គលិក អង្គការ ) | ៨,៥ % |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | ២,២ % |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

ប្រជាពលរដ្ឋនៅក្នុងសាន់គ ពួកគាត់បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង ដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង ហើយក្នុងនោះប្រជាជន ដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្មមានចំនួន ២ ២០៥ នាក់ ស្មើនឹង ៧៣ ភាគរយ នៅក្នុងនោះស្ត្រីចំនួន ៨៩៩ នាក់ ស្មើនឹង ២៩,៨ ភាគរយ អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្មមិនមាននោះទេ ចំណែកអ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម ចំនួន ៥៩៥ នាក់ ស្មើនឹង ២៧ ភាគរយ ក្នុងនោះស្ត្រីចំនួន ២៧២ នាក់ ស្មើនឹង ៩ ភាគរយ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋក្នុងឃុំសាន់គ ក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានប្រជាពលរដ្ឋប្រមាណជិតពាក់កណ្តាលបានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត ដូចជា លក់ដូរ ជំនួញ ផ្នែកដឹកជញ្ជូន និងកម្មករសំណង់។ល។ ចំណែកអ្នកដែលមានរបរផ្នែកសេវាកម្មជាចម្បងមានស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្ម ដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ។

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៧៣ % | ២២០៥ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ២៩,៨ % | ៨៩៩ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0 | 0 |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0 | 0 |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ២៧ % | ៥៩៥ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៩ % | ២៧២ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ង.ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារធាតុបម្រុង ដីខ្សោះ ឬហឹរជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ គ្មានទីផ្សារ សមាជិកគ្រួសារកើនឡើង និងគ្រួសារមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋាន របស់ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត/រាជធានី និងធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុករបស់ពួកគាត់ ក្នុងគោលបំណងលើកស្ទួយជីវភាពគ្រួសារ។ តាមរបាយការណ៍របស់រដ្ឋបាលឃុំសាន់គ បានបង្ហាញថា ប្រជាជនផ្លាស់លំនៅឋានចូលមានចំនួន ០៤គ្រួសារ ដែលមានមនុស្សសរុប ១៣នាក់ ក្នុងនោះមានស្រី ០៧នាក់ និងប្រជាជនផ្លាស់លំនៅឋានចេញមានចំនួន ០៥ គ្រួសារ មានមនុស្សសរុប ១៨ នាក់ ដែលមានស្រីចំនួន ០៩នាក់។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ០៤ | ១៣ | ០៧ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ០៥ | ១៨ | ០៩ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧ បានបង្ហាញថាប្រជាជនដែលធ្វើចំណាកស្រុកទូទាំងឃុំមានចំនួនសរុប ២ ០៥០ នាក់ និងមានស្រីចំនួន ១ ០០៩ នាក់។ នៅក្នុងនោះអ្នកធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួន ១ ២៨៧ នាក់ ស្ត្រីចំនួន ៧២៤ នាក់ និងចំណាកស្រុកទៅក្រៅប្រទេសមានចំនួន ៧៦៣ នាក់ ក្នុងនោះមានស្រីចំនួន ២៨៥នាក់ ។ ជាទូទៅចំណាកស្រុករបស់ប្រជាពលរដ្ឋភាគច្រើនទាំងក្នុង និងក្រៅប្រទេសគឺមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅឃុំ ស្រុក ខេត្តផ្សេង រាជធានីភ្នំពេញ ប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើមតែមួយរយៈប៉ុណ្ណោះ ពួកគាត់នឹងវិលត្រលប់មកស្រុកកំណើតវិញជារើយៗ។ ប្រជាជនធ្វើចំណាកស្រុក ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្ដាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៩៖ ស្ថិតិប្រជាជនចំណាកស្រុក

| **បរិយាយ** | **២០១៦** | | | **២០១៧** | | |
|---|---|---|---|---|---|---|
| | **សរុប** | **ប្រុស** | **ស្រី** | **សរុប** | **ប្រុស** | **ស្រី** |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ១៤៧៥ | ៥៦៥ | ៩១០ | ១២៨៧ | ៥៦៣ | ៧២៤ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ៨៥៦ | ៥២០ | ៣៣៦ | ៧៦៣ | ៤៧៨ | ២៨៥ |
| **សរុប** | **២៣៣១** | **១០៨៥** | **១២៤៦** | **២០៥០** | **១០៤១** | **១០០៩** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ១.១.៣.ស្ថានភាពសេដ្ឋកិច្ច

#### ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ ស្ដីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថា គ្រួសារដែលមានជីវភាពគ្រាន់បើ មានប្រភពចំណូលទី១ គឺលក់ស្រូវ ប្រភពចំណូលទី២ គឺចងការប្រាក់ និងប្រភពចំណូលទី៣ គឺលក់សម្ភារៈកសិកម្ម។ គ្រួសារមានជីវភាពមធ្យម មានប្រភពចំណូលទី១ គឺលក់ស្រូវ ប្រភពចំណូលទី២ គឺលក់ឱឡឹក និងធ្វើជាកម្មករ។ គ្រួសារមានជីវភាពក្រ និងក្រណាស់ មានប្រភពចំណូលទី១ គឺលក់កម្លាំងពលកម្ម ប្រភពចំណូលទី២ គឺនេសាទ និងប្រភពចំណូលទី៣ គឺលក់ស្រូវ។

#### ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើតាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ ២០១៧ ដែលទទួលបានពីរបាយការណ៍ ស្ដីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើ បានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងឃុំសាន់គមានកម្រិត

ជីវភាពរស់នៅចែកចេញជាបួនកម្រិត គឺ ១)គ្រួសារបង្គួរ/គ្រាន់បើ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេ មានដីលំនៅឋានកាន់កាប់ចំនួន ០,១៤ ហិកតា និងដីស្រែចំនួន ១៦ ហិកតា ២)គ្រួសារមធ្យម មានដីលំនៅឋាន ចំនួន ០.១០ ហិកតា និងដីស្រែចំនួន ៣,៥ ហិកតា ៣) គ្រួសារក្រ មានដីលំនៅឋានចំនួន ០,០៦ ហិកតា និង ដីស្រែចំនួន ០,៨ ហិកតា និង ៤)គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុត ដីលំនៅឋានចំនួន ០,០៤ ហិកតា និងដីស្រែចំនួន ០,១០ ហិកតា ចុះក្រោមរហូតដល់អ្នកគ្មានដី។

បើយោងទៅតាមការសាកសួរ ជាមួយនឹងក្រុមប្រឹក្សាឃុំសាន់គ បានបង្ហាញថាចំណូលប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋជាមធ្យមចាប់ពី ១៥០ ០០-២០០ ០០ រៀល/គ្រួសារ/ថ្ងៃ ស្មើនឹង ៥ ៤៧៥ ០០០- ៧ ៣០០ ០០០ រៀល/គ្រួសារ/ឆ្នាំ ចំណែកការចំណាយផ្សេងៗប្រចាំឆ្នាំ ដែលមានដូចជាស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ ប្រើប្រាស់ សម្ភារៈសិក្សា និងថ្នាំសង្កូវជាដើម ស្មើនឹង ៣ ៦៥០ ០០០-៥ ៤៧៥ ០០០ រៀល/គ្រួសារ/ឆ្នាំ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| ប្រៀបធៀបជា(%)តំបន់ទីI | ៣៥ | ៦០ | ៥ | ០ | ១០០% |
| តំបន់ទីII | ៣៥ | ៦០ | ៥ | ០ | ១០០% |
| តំបន់ទីIII | ៣០ | ៧០ | ០ | ០ | ១០០% |
| តំបន់ទីIII.A | ២៥ | ៥៥ | ២៥ | ០ | ១០០% |
| តំបន់ទីIV(៨0F) | ៦៥ | ៣៥ | ០ | ០ | ១០០% |
| ទូទាំងឃុំ | | | ៣៧៦ | ៤៤៨ | ១០០% |
| ទំហំគ្រួសារ | ៣ | ៤ | ៦ | ៧ | - |
| កម្លាំងពលកម្ម | ២ | ៣ | ៣ | ៤ | - |
| ទំហំដីកាន់កាប់សរុប(ហ.ត) | | | | | - |
| ចំនួន និងប្រភេទក្បាលដី | - | - | - | - | - |
| ដីលំនៅឋាន(ហ.ត) | ០,១៤ | ០.១០ | ០,០៦ | ០,០៤ | - |
| ដីស្រែ(ហ.ត) | ១៦ | ៣,៥ | ០,៨០ | ០,១០ | - |
| ដីផ្សេងៗទី១(ហ.ត) | - | ឪឡឹក | - | - | - |
| ដីផ្សេងៗទី២(ហ.ត) | | | | | - |
| ប្រភេទពូជស្រូវដាំដុះ | ផ្ការំដួល IR៥០៤ រាំងជ័យ | ផ្ការំដួល IR៥០៤ រាំងជ័យ | នាងគង់ រាំងជ័យ | នាងគង់ រាំងជ័យ | |
| ដំណាំទី១៖ ស្រូវ (ហ.ត) | ស្រូវ ១៦ហ.ត | ស្រូវ ៣,៥ហ.ត | ស្រូវ ០,៨ហ.ត | - | |
| ដំណាំទី២៖ ឪឡឹក (ហ.ត) | - | ២,៥ | - | - | |
| ការចិញ្ចឹមត្រី | ត្រីធម្មជាតិ បានពីការជីកអាងទឹក | ត្រីធម្មជាតិ បានពីការជីកស្រះ | - | - | - |
| ចំនួនគោ-ក្របី | ១០ | ៤-៥ | ១ ប្រវាស់គេ | - | |
| ចំនួនក្របី | ៨ | ៥ | - | - | |

| | | | | | |
|---|---|---|---|---|---|
| ចំនួនជ្រូក | ៧ | ២ | - | - | |
| ការប្រើប្រាស់ឧបករណ៍នេសាទ | - | ម៉ង សន្ទូច សំណាញ់ | ម៉ង សំណាញ់ | - | |
| ប្រភពចំណូលទី១៖ | លក់ស្រូវ | លក់ស្រូវ | លក់កម្លាំងពលកម្ម | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី២៖ | ចងការប្រាក់ | ឌីឡឹក | នេសាទ | នេសាទ | |
| ប្រភពចំណូលទី៣៖ | សម្ភារៈកសិកម្ម | កម្មករ | លក់ស្រូវ | | |
| ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម) | លក់ចាប់ហួយ | លក់កម្លាំងពលកម្ម ក្នុង និង ក្រៅប្រទេស | លក់កម្លាំងពលកម្ម ក្នុង និងក្រៅប្រទេស | លក់កម្លាំងពលកម្ម ក្នុង និងក្រៅប្រទេស | |
| ការប្រើប្រាស់ឥណទាន | ចងការពីធនាគារ និងឯកជន | ចងការពីឯកជន | ចងការពីសហគមន៍កសិកម្ម និងឯកជន | - | |

ប្រភព៖ *របាយការណ៍ប្រព័ន្ធគ្រួសារ-បរិស្ថាន និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### គ.ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំសាន់គ មានចំនួន ១ ០២១ គ្រួសារ ស្មើនឹងប្រមាណ ២៨ ភាគរយ ដែលជាប់បំណុលមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារឬមីក្រូហិរញ្ញវត្ថុឯកជនទេ ដោយសារគ្មានទ្រព្យប្រចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

នៅក្នុងសាន់គ មានទីតាំងធនាគារចំនួន២កន្លែង និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ចំនួន២កន្លែង។ ប្រជាពលរដ្ឋទទួលបានសេវាប្រាក់កម្ចីពីធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើន ទាំងនៅក្នុង និងក្រៅមូលដ្ឋាន មានដូចជា ធនាគាអេស៊ីលីដា ABA កាណាឌីយ៉ា ប្រៃសណីយ៍ និងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនទៀត មានដូចជា ស្ថាបនាហត្ថាកសិករ ប្រាសាក់ LOLC អេអឹមខេ មហានគរ និរន្តរ វីហ្សិនហ្វាន់ និងមីក្រូហិរញ្ញវត្ថុបណ្តាញសេដ្ឋកិច្ច ចំណែកអត្រាការប្រាក់វិញគិតទៅតាមចំនួនប្រាក់កម្ចី បើសិនជាកម្ចីកាន់តែច្រើន នោះអត្រាការប្រាក់កាន់តែទាបរហូត ០,៩ ភាគរយ តែបើកម្ចីកាន់តែតិចនោះ អត្រាការប្រាក់កាន់តែខ្ពស់រហូតដល់ ១,៨ ភាគរយ។ ទាំងធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ គឺមានអត្រាការប្រាក់ គឺប្រហាក់ប្រហែលគ្នា។ ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម មានអត្រាការប្រាក់ខ្ពស់ គឺចាប់ពី ១,៥ ភាគរយ ទៅ ១០ ភាគរយ។

### ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅប្រជាពលរដ្ឋនៅក្នុងឃុំសាន់គ ប្រើប្រាស់មីក្រូឥណទាន ដែលជាសាច់ប្រាក់សុទ្ធ ដើម្បីយកទៅពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់ទៅតាមតម្រូវការចាំបាច់ផ្សេងៗទៀត ហើយក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួន ទៅទទួលយកជីជាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង.ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំសាន់គ ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស(ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ ជាដើម
- និងចំណូលមួយចំនួនតូចទៀត ដែលបានមកពីគ្រួសារឬបងប្អូនរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

## ១.១.៤.ស្ថានភាពអប់រំ និងសិក្សាធិការ

### ក.ស្ថានភាពអប់រំ

បើតាមផែនការអភិវឌ្ឍឃុំសាន់គ៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារីគ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ននេះ វិស័យអប់រំនៅក្នុងឃុំសាន់គ មានការរីកចម្រើនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់ នៅតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ (អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជំរុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ។

រូបភាព 1៖ សាលារៀន

| | |
|---|---|
|  |  |
| សាលាបឋមសិក្សាឃុំសាន់គ | សាលាអនុវិទ្យាល័យឃុំសាន់គ |

នៅក្នុងឃុំសាន់គ មានកម្រិតអប់រំ ចាប់ពីមត្តេយ្យសិក្សារហូតទៅដល់អនុវិទ្យាល័យ ចំណែកឯវិទ្យាល័យវិញមិនទាន់មាននៅក្នុងឃុំនោះទេ តែមាននៅក្រៅឃុំដែលជាប់ព្រំប្រទល់គ្នា។ សាលាមត្តេយ្យសិក្សាមានចំនួន ១ កន្លែង ២ បន្ទប់ ២ ថ្នាក់ គ្រូបង្រៀនចំនួន ០២ នាក់ ដែលជាស្ត្រី ហើយសិស្សកំពុងរៀនមានចំនួន ៤៧ នាក់ ក្នុងនោះស្រីមានចំនួន ២៨ នាក់។ សាលាបឋមសិក្សាមានចំនួន ១០ កន្លែង ៧៥ បន្ទប់ ១០០ ថ្នាក់ គ្រូបង្រៀនចំនួន ៥៩ នាក់ ក្នុងនោះជាស្ត្រី ៣០ នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួន ៣ ១៩៤ នាក់ ដែលមានសិស្សស្រីចំនួន ១ ៥៩៤ នាក់។ ចំណែកសាលាអនុវិទ្យាល័យវិញ មានចំនួន ២ កន្លែង ៧ បន្ទប់ ១២ ថ្នាក់ គ្រូបង្រៀន ៣០ នាក់ ក្នុងនោះស្ត្រី ១៥ នាក់ និងសិស្សកំពុងរៀនមានចំនួន ៦៥០ នាក់ ក្នុងនោះស្រីចំនួន ៣៧៧ នាក់។

នៅក្នុងឃុំសាន់គ មិនទានមានសាលាវិទ្យាល័យនោះទេ ចំណែកសាលារៀនមួយចំនួន មានសភាពទ្រុឌទ្រោម នៅខ្វះគ្រូបង្រៀន ដែលសព្វថ្ងៃមានតែគ្រូកិច្ចសន្យា។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | ១ | ២ | ២ | ៤៧ | ២៨ | ២ | ២ |
| ២.សាលាបឋមសិក្សា | ១០ | ៧៥ | ១០០ | ៣១៩៤ | ១៥៩៤ | ៥៩ | ៣០ |
| ៣.អនុវិទ្យាល័យ | ២ | ១៧ | ១២ | ៦៥០ | ៣៧៧ | ៣០ | ១៥ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ខ.ស្ថានភាពអក្ខរកម្ម

យោងទៅតាមទិន្នន័យពីមន្ទីរផែនការក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសាន់គ អ្នកមានអាយុពី ១៥-២៤ឆ្នាំ មានចំនួន ៨ ៤៣៦ នាក់ នៅក្នុងនោះមានចំនួន ៣,២ ភាគរយ ដែលមិនចេះអក្សរ បើគិតទៅតាមក្រុមអាយុវិញ អ្នកមិនចេះអក្សរអាយុចាប់ពី ១៥-២៤ឆ្នាំមានចំនួន ២៥ នាក់ ស្មើនឹង ០,៦ ភាគរយ និងអ្នកមិនចេះអក្សរអាយុចាប់ពី ២៥-៤៥ឆ្នាំមានចំនួន ២៤៨ នាក់ ស្មើនឹង ៥,៥ ភាគរយ ។ ដូច្នេះប្រជាពលរដ្ឋដែលមិនចេះអក្សរ នៅតែមានចំនួនច្រើននៅឡើយ ជាពិសេសនោះ អ្នកដែលមានអាយុចាប់ ២៥ ឡើងទៅ។

ប្រជាពលរដ្ឋភាគច្រើនដែលមិនចេះអក្សរ គឺដោយសារមិនបានចូលរៀន មូលហេតុដោយសារសាលារៀននៅឆ្ងាយពីភូមិឃុំ ប្រជាពលរដ្ឋនៅតែមានកង្វះខាតមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹល ឬមិនជឿនលឿន។ ទោះបីយ៉ាងនោះក្តី នៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលអាចចូលសិក្សា ព្រោះជាប់រវល់នឹងប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ នៅក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយ បានពង្រឹងតាមរយៈការពិនិត្យឡើងវិញ នូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញនូវកម្មវិធីចូលរៀនឡើងវិញ ព្រមទាំងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសមមូល។ ដើម្បីធ្វើការជំរុញឱ្យផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ២៦ | ២៥ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ០,៧ | ០,៦ |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ២៩១ | ២៤៨ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៦,៤ | ៥,៥ |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៨២៩០ | ៨៤៣៦ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ៣,៨ | ៣,២ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរផែនខេត្ត នៅក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា លទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្ស នៅក្នុងឃុំសាន់គ ទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៤២៧ នាក់  ស្រីមានចំនួន ២០៦ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៨២៧ នាក់  ស្រីមានចំនួន ៤៤១ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ១៧៩ នាក់  ស្រីមានចំនួន ១៧៩ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៤៧៤ នាក់  ស្រីមានចំនួន ១៥២ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១៥៩ នាក់  ស្រីមានចំនួន ៨៦ នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ១៧៩ នាក់ ស្រីចំនួន ១០៤ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈពុំមានចំនួន ៩៦ នាក់ ស្រី ៥០ នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ៨៩ នាក់ ស្រី ៦២ នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ៤២៧ | ២០៦ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ៨២៧ | ៤៤១ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ១៧៩ | ១៧៩ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ៤៧៤ | ១៥២ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ១៥៩ | ៨៦ |

| | | |
|---|---|---|
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ១៧៩ | ១០៤ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩៦ | ៥០ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ៨៩ | ៦២ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ។ ឃុំសាន់គ មានមណ្ឌលសុខភាពចំនួន ១ កន្លែង ដែលស្ថិតនៅភាគខាងកើតនៃឃុំស្ថិតនៅក្នុងភូមិវាល មានចម្ងាយប្រហែលជា ០៤ គីឡូម៉ែត្រ។ មណ្ឌលសុខភាពនេះមានគ្រូពេទ្យចំនួន ០៧ នាក់ នៅក្នុងនោះមានស្រីចំនួន ៤ នាក់ ក្នុងនោះពេទ្យឆ្មបចំនួន ០២ នាក់ ចំណែកគ្លីនិកឯកជនមិនទាន់មាននោះទេ។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លងដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម។ ស្ថានភាពមាតា និងទារកនៅក្នុងឃុំសាន់គមានស្រ្តីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន ១៩ នាក់ ស្រ្តីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន ២៥២នាក់ ទារកដែលបានកើតរស់ដោយឆ្មបបុរាណមានចំនួន ១៩ នាក់ ស្រ្តីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន ២៥២ នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបពេទ្យមិនមាននោះទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយឆ្មបពេទ្យមិនមាននោះទេ ទារកដែលបានចុះសំបុត្រកំណើតមានចំនួន ១៨៧ នាក់ កុមារដែលមានអាយុចន្លោះពី ៩-១២ ខែ ចំនួន ១៨៨ នាក់ កុមារដែលមានអាយុចន្លោះពី ៩-១២ខែ បានចាក់ថ្នាំបង្ការគ្រប់ចំនួន ១៨៤ នាក់។ សម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗដល់កុមារនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋទៅលើជម្ងឺមួយចំនួនដូចជា ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងជម្ងឺគ្រុនឈាម។

ប្រសិនបើករណីជម្ងឺធ្ងន់ធ្ងរ ការបញ្ជូនអ្នកជម្ងឺ ដោយមធ្យោបាយខ្លួនឯងផ្ទាល់មកកាន់មណ្ឌលសុខភាព ព្រោះមណ្ឌលសុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យបង្អែក ដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែក ចំណែកការចំណាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺ នៅក្នុងករណីអ្នកជម្ងឺមិនប័ណ្ណក្រីក្រ។ សុខភាពរបស់ប្រជាពលរដ្ឋក្នុងឃុំសាន់គ ពុំទាន់បានល្អប្រសើរនោះទេ ហើយមណ្ឌលសុខភាពនៅមានការខ្វះខាតសម្ភារៈពេទ្យ ការងារបច្ចេកទេស ខ្វះថ្នាំព្យាបាល និងជម្ងឺឆ្លង ដែលជាបញ្ហាសម្រាប់អាជ្ញាធរមូលដ្ឋានចាំបាច់ត្រូវតែរកដំណោះស្រាយនៅពេលខាងមុខ។

តារាង 13៖ សុខភាពមាតា និងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ០៧ នាក់ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ០២ នាក់ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | ០ |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ៤ បន្ទប់ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៦ គ្រែ |

| | | |
|---|---|---|
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ០៦ នាក់ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ១៩ នាក់ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ២៥២ នាក់ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ១៩ នាក់ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ២៥២ នាក់ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបបុរាណ | 0 |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ 0-១ខែដោយឆ្មបពេទ្យ | 0 |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ១៨៧ នាក់ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ១៨៨ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ១៨៤ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាពឃុំសាន់គ




បើយោងតាមទិន្នន័យមន្ទីរផែនការខេត្ត នៅក្នុងឆ្នាំ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹម ៩,៨ គីឡូម៉ែត្រប៉ុណ្ណោះ ដូចដែលមាននៅក្នុងតារាងសង្ខេបខាងក្រោម ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពវិញ ក៏មិនពិបាកនៅក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ប្រាសាទ | ៤,៥ គីឡូម៉ែត្រ | |
| ២ | បាឡាំង | ១ គីឡូម៉ែត្រ | |
| ៣ | តាំងក្រូច | ០,៣ គីឡូម៉ែត្រ | |
| ៤ | វាល | ០ គីឡូម៉ែត្រ | |
| ៥ | ជ័យ | ៦ គីឡូម៉ែត្រ | |
| ៦ | ស្លែងខ្ពស់ | ៧ គីឡូម៉ែត្រ | |
| ៧ | សារី | ១ គីឡូម៉ែត្រ | |
| ៨ | សំពៅមាស | ២ គីឡូម៉ែត្រ | |
| ៩ | ក្បិល | ៥ គីឡូម៉ែត្រ | |
| ១០ | អំពិល | ៤ គីឡូម៉ែត្រ | |
| ១១ | សាន់គ (ក) | ០,៥ គីឡូម៉ែត្រ | |
| ១២ | សាន់គ (ខ) | ៤ គីឡូម៉ែត្រ | |
| ១៣ | ក្រសាំង (ក) | ៨ គីឡូម៉ែត្រ | |
| ១៤ | ក្រសាំង (ខ) | ៩,៨ គីឡូម៉ែត្រ | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ១.១.៦.ស្ថានភាពយេនឌ័រ

យោងតាមផែនការអភិវឌ្ឍឃុំសាន់គ សម្រាប់រយៈពេល៥ឆ្នាំ(២០១៨-២០២២)បានបង្ហាញឱ្យឃើញថា សមភាពការងាររបស់ស្ត្រី និងបុរសនៅក្នុងឃុំសាន់គ នាពេលបច្ចុប្បន្នគ្មានការរើសអើង ឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងឃុំកំពុងតែត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្ម នៅក្នុងការកសាងផែនការអភិវឌ្ឍឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើត

មានឡើងទៅលើសមត្ថភាពស្ត្រី ដោយស្ត្រីមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅភ្នំពេញ ដើម្បីធ្វើកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ទីរការិយាល័យជំនាញ និងដៃគូអភិវឌ្ឍនានាជំរុញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើយោងតាមរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំសាន់គនៅក្នុងឆ្នាំ២០១៧បានឱ្យដឹងអំពីតួនាទីយេនឌ័រ នៅក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករក្នុងឃុំសាន់គ មានលម្អិតក្នុងតារាងខាងក្រោម។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| **ស្រូវវស្សា និង ប្រាំង** | | | |
| ការរៀបចំដីលើកទី១ | ៩០% | ១០% | បុរសអនុវត្តនៅទីវាល ស្ត្រីរៀបចំផ្ទះ |
| ការរៀបចំដីលើកទី២ | ៧០% | ៣០% | ស្ត្រីអាចជួយបាចជីទ្រាបបាត, សម្អាតស្មៅ |
| ការត្រាំពូជ | ៥០% | ៥០% | |
| ព្រួស | ៧០% | ៣០% | ស្ត្រីអាចជួយព្រួសមួយចំនួន |
| ការដាក់ជីបំប៉ន | ៩០% | ១០% | ស្ត្រីជួយជញ្ជូនជីបានខ្លះ |
| គ្រប់គ្រងទឹកស្រែ | ៥០% | ៥០% | |
| ការថ្នាំសម្លាប់ស្មៅ | ៨០% | ២០% | ស្ត្រីជួយទិញថ្នាំ, រៀបចំ ម្ហូបអាហារ សម្ភារៈឱ្យប្តី |
| ការច្រូតកាត់ | ៥០% | ៥០% | |
| ការដឹកជញ្ជូន | ៧០% | ៣០% | ស្ត្រីជួយចងមាត់បាវ, ច្រកស្រូវ |
| ហាលសម្ងួត | ៥០% | ៥០% | |
| ទុកដាក់ស្រូវ | ៥០% | ៥០% | |
| លក់ស្រូវ | ៥០% | ៥០% | |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| សួនបន្លែ | ៥០% | ៥០% | |
| ចិញ្ចឹមជ្រូក | ៣០% | ៧០% | បុរសជួយធ្វើទ្រុង,ជួយលាងសម្អាតទ្រុងម្តងម្កាល |
| ចិញ្ចឹមគោ ក្របី | ៧០% | ៣០% | ស្ត្រីជួយរៀបចំម្ហូបអាហារផ្ទះ |
| ចិញ្ចឹមមាន់ ទា | ៥០% | ៥០% | |
| ការប្រមូលអនុផលព្រៃឈើ | ៧០% | ៣០% | ជួយជញ្ជូនដាក់រទេះ |
| រកត្រី | ៧០% | ៣០% | ជួយកាន់ឧបករណ៍រកត្រី |
| ជំនួញទូទៅ | ៥០% | ៥០% | |
| ការថែទាំប្រព័ន្ធធារាសាស្ត្រ | ៧០% | ៣០% | ស្ត្រីជួយឱ្យយោបល់ |
| ដំណាំឪឡឹក | | | |
| ការរៀបចំដី | ៨០% | ២០% | ជួយរៀបចំម្ហូបអាហារ |
| ភ្ជួរ | ៩០% | ១០% | ដាំបាយ ស្ល យកបាយឱ្យប្តី |

| | | | |
|---|---|---|---|
| រាស់ | ៩០% | ១០% | ស្ត្រីមើលកូននៅផ្ទះ, បោកខោអាវឱ្យប្តី |
| ឆូតរង | ៥០% | ៥០% | |
| ដាក់ជី | ៥០% | ៥០% | |
| ផ្គុំរង | ៩០% | ១០% | ធ្វើកិច្ចការនៅផ្ទះ |
| ដាំគ្រាប់ | ១០% | ៩០% | ទៅមើលគោ ក្របី |
| ដាក់ជី | ១០% | ៩០% | |
| ពូនរង | ៩០% | ១០% | |
| បូមទឹក | ៩០% | ១០% | រៀបចំសម្ភារៈស្រាល |
| ថែទាំ | ៥០% | ៥០% | |
| លក់ដោយម៉ៅ | ៥០% | ៥០% | |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសាន់គ ឆ្នាំ២០១៧*

យោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសាន់គ នៅក្នុងឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រនៅក្នុងឃុំសាន់គដូចខាងក្រោម៖

១.ស្ត្រីភាគច្រើនជាអ្នកផលិតកសិកម្ម

២.បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣.ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤.សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥.ការងារធ្ងន់ៗជាបន្ទុករបស់បុរស

តាមប្រភពព័ត៌មានដែលទទួលបាន ដូចមាន រៀបរាប់ខាងលើពាក់ព័ន្ធ ការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំសាន់គ យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជាការងារធ្វើស្រែយើងសង្កេតឃើញថាបុរសមានការចូលរួមច្រើនជាងស្ត្រី ជាពិសេស ការងាររៀបចំដីស្រែ ការងារនេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុង ដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ចំណែកការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំ សម្លាប់សត្វល្អិត ដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារនៅក្នុងផ្ទះ និងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែនៅក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅតែមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅតែទទួលរងអំពើហឹង្សានៅក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបី ជាមានបញ្ហាប្រឈមខ្លះនៅក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងសង្កេតឃើញថា កិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២.ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

ឃុំសាន់គ ជាឃុំមួយស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៦៩០៤៦,៦២ និង(អ័រដោនេ) ១៤១៦៤៤៩,៧២ ចំណែកសណ្ឋានដីនៅក្នុងឃុំសាន់គ បើផ្អែកទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ បានឱ្យដឹងថា មិនរាបស្មើនោះទេ មានទាបមានខ្ពស់ ដោយបានចែកចេញជា៤តំបន់ គឺ

**តំបន់ I** ៖ នៅប៉ែកខាងលិចឆៀងខាងជើងនៃឃុំ ដែលជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក មានក្រុមដីប្រទះឡាន ក្រុមដីបាកាន(ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ)ពណ៌ត្នោត ត្រូវបានប្រើប្រាស់ជាតំបន់លំនៅឋាន ដំណាំ និងស្រូវរដូវវស្សា។

**តំបន់ II** ៖ នៅផ្នែកកណ្តាលនៃឃុំ ជាតំបន់រាបស្មើទាបជាងតំបន់ទី១ ដែលមានប្រភេទក្រុមដីក្រគរ ក្រុមដីគោកត្រប់(កណ្តោងខ្លះល្បាយខ្សាច់)ប្រផេះស្រាលត្រូវបានប្រើប្រាស់សម្រាប់ស្រូវដើមរដូវ និងស្រូវប្រដេញទឹក។

**តំបន់ III** ៖ នៅប៉ែកកណ្តាលនៃឃុំ ជាប់នឹងតំបន់២ ជាតំបន់រាបស្មើទាបជាងតំបន់ទី២ មានប្រភេទក្រុមដីក្រគរ ក្រុមដីក្បាលពោ(កណ្តោងសុទ្ធពណ៌ខ្មៅប្រផេះ) ដីល្បាប់ចាស់ ដែលត្រូវបានប្រើប្រាស់សម្រាប់ស្រូវសម្រករដូវប្រាំង និងដំណាំដីខ្ពស់មួយចំនួនតូច។

**តំបន់ IIIA** ៖ នៅប៉ែកកណ្តាលនៃឃុំ ជាប់នឹងតំបន់២ ជាតំបន់រាបស្មើទាបជាងតំបន់ទី២ មានប្រភេទក្រុមដីគោកត្រប់ ក្រុមដីក្រគរ ក្រុមដីក្បាលពោ (ដីកណ្តោងពណ៌ខ្មៅប្រផេះ) ដីល្បាប់ចាស់ ដែលត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវធ្វើបាន១ម្តង/ឆ្នាំ និងដំណាំឪឡឹកធ្វើបាន១ដង/ឆ្នាំ។

**តំបន់ IV** ៖ នៅប៉ែកខាងត្បូងនៃឃុំ ជាតំបន់ដែលមានសណ្ឋានដីជម្រាលរាបស្មើ(ទាប)មានប្រភេទក្រុមដីក្បាលពោ ដីកណ្តោង ដីពពាយកណ្តុល និងដីល្បាប់ចាស់ ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវ ហើយធ្វើបាន១ម្តង/ឆ្នាំ និងតំបន់ព្រៃលិចទឹក។

ផែនទី 3៖ ផែនទីរយៈកម្ពស់ឃុំសាន់គ

**ផែនទីរយៈកម្ពស់ ឃុំសាន់គ**



ផែនទី 4៖ បង្ហាញពីតំបន់ក្បេត្រ-បរិស្ថានឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ



តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹង ឃុំសាន់គ ស្រុកកំពង់ស្វាយ

| តំបន់ / បរិយាយ | តំបន់កៀ្សត្រ-បរិស្ថាន I | តំបន់កៀ្ស-ត្របរិស្ថាន II | តំបន់កៀ្សត្រ-បរិស្ថាន III | | តំបន់កៀ្សត្រ-បរិស្ថាន IV |
|---|---|---|---|---|---|
| | | | III | III A | |
| **រូបថតតំណាងតំបន់កៀ្សត្រ-បរិស្ថាន** |  |  |  |  |  |
| **ឈ្មោះតំបន់** | តំបន់លំនៅឋានដំណាំដំដុះនិងស្រូវវស្សាមានការស្រោចស្រពដោយកន្លែង**៧,៨៤៧ ហ.ត** | តំបន់ដំណាំស្រូវដើមរដូវនិងស្រូវប្រដេញទឹកដោយប្រើប្រាស់ប្រព័ន្ធស្រោចស្រព **soil.៤,៧៦៥ ហ.ត** | តំបន់ស្រូវប្រដេញទឹកស្រូវប្រាំងនិងឪឡឹកធ្វើ១/ឆ្នាំស្រោចស្រពដោយទឹកអាង **៤,១៣៥ ហ.ត** | តំបន់ស្រូវប្រដេញទឹកស្រូវប្រាំងនិងឪឡឹកធ្វើ១/ឆ្នាំស្រោចស្រពដោយទឹកអាងគ្រប់គ្រងដោយក្រុមហ៊ុន **២,៥១៣ ហ.ត** | តំបន់ព្រៃលិចទឹក បឹងទន្លេសាប **២,៩៦១ ហ.ត** |
| **រៀបរាប់ដោយសង្ខេប** | -ដីមានរាងជម្រាលមកខាងត្បូងឆៀងខាងលិច<br>-ស្រោចស្រពទឹកភ្លៀង និងទឹកអាង៣០កញ្ញា<br>-ពុំមានភ្លឺស្រែគ្រប់គ្រាន់<br>-ផ្ទៃដី ៧ ៨៤៦,៥៨ ហ.ត | -ជម្រាលរាបស្មើ<br>-មានលំនៅឋាន<br>-ស្រោចស្រពដោយទឹកភ្លៀង និងទឹកប្រឡាយ ៣០កញ្ញា<br>-ពុំមានភ្លឺស្រែគ្រប់នគ្រាន់<br>-ផ្ទៃដីប្រហែល៤៧៦៥ហ.ត<br>-មានវាលស្រែ | -ជម្រាលរាបស្មើ<br>-មានអាងស្ទាក់ទឹករបស់ប្រជាពលរដ្ឋ<br>-ស្រោចស្រពដោយទឹកប្រឡាយ៣០កញ្ញា,ទឹកបឹង,ទឹកអាងចៅភារុន ,អាងអ៊ុយអ៊ី<br>-ផ្ទៃដីប្រហែល៤១៣៤ហ.ត<br>-វាលស្រែ | -ជម្រាលរាបស្មើ<br>-មានអាងស្ទាក់ទឹកដូងហេង<br>-ស្រោចស្រពពីប្រឡាយទឹក៣០កញ្ញាតិចតួច<br>-ផ្ទៃដីប្រហែល២៥១៣ហ.ត<br>-មានស្រែ | -ជម្រាលរាបស្មើ ( ទាប )<br>-មានបឹងធម្មជាតិ<br>-មានព្រៃលិចទេក<br>-មានសហគមន៍នេសាទ<br>-មានស្រែខ្លះៗ<br>-ស្រោចស្រពដោយទឹកបឹង<br>-រកឧស ត្រី |
| **ឋានលេខា** | -តំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក | -តំបន់រាបស្មើទាបជាងតំបន់ទី១ | -តំបន់រាបស្មើទាបជាងតំបន់ទី២ | -តំបន់រាបស្មើទាបជាងតំបន់ទី២ | -តំបន់ទំនាបព្រៃលិចទឹក |

| | | | | | |
|---|---|---|---|---|---|
| **ប្រភេទដី** | -ក្រុមដីប្រទះឡាន<br>-ក្រុមដីបាកាន (ខ្សាច់+ឥដ្ឋ =ខ្សាច់ល្បាយ)ពណ៌ត្នោត | -ក្រុមដីក្រគរ<br>-ក្រុមដីគោកត្រប់(កណ្ដេងខ្លះល្បាយខ្សាច់) ប្រផេះស្រាល | -ក្រុមដីក្រគរ<br>-ក្រុមដីក្បាលពោ(កណ្ដេងសុទ្ធពណ៌ខ្មៅប្រផេះ)<br>-ដីល្បាប់ចាស់ | -ក្រុមគោកត្រប់<br>-ក្រុមដីក្រគរ<br>-ក្រុមដីក្បាលពោ(ដីកណ្ដេងពណ៌ខ្មៅប្រផេះ)<br>-ដីល្បាប់ចាស់ | -ក្រុមដីក្បាលពោ<br>-ដីកណ្ដេងពពាយកណ្ដុល<br>-ដីល្បាប់ចាស់ |
| **ជលសាស្ត្រ** | -ស្រោចស្រពដោយទឹកភ្លៀង<br>-ស្រោចស្រពដោយប្រឡាយ ៣០កញ្ញា | -ស្រោចស្រពដោយទឹកភ្លៀង<br>-ទឹកប្រឡាយ៣០កញ្ញា<br>-ទឹកជំនន់រយៈពេលខ្លី២ខែ | -ស្រោចស្រពដោយទឹកប្រឡាយ ៣០កញ្ញា<br>-ទឹកអាង,បឹងធម្មជាតិ<br>-ទឹកជំនន់រយៈពេលខ្លី៣ខែ | -ស្រោចស្រពដោយទឹកប្រឡាយ ៣០កញ្ញា<br>-ទឹកអាង,បឹងធម្មជាតិ<br>-ទឹកជំនន់រយៈពេលខ្លី៣ខែ | -ស្រោចស្រពដោយទឹក បឹងធម្មជាតិ<br>-ទឹកជំនន់រយៈពេល៥ខែ |
| **ធនធានទឹក** | -ប្រឡាយ៣០កញ្ញា<br>-ប្រឡាយអភិវឌ្ឍន៍គម្រោងស្ទឹងស្ទោង | -ប្រឡាយ៣០កញ្ញា (អាង៣០កញ្ញា) | -ប្រឡាយ៣០កញ្ញា<br>-បឹងធម្មជាតិ,អាងប្រជាពលរដ្ឋ | -ប្រឡាយ៣០កញ្ញា<br>-បឹងធម្មជាតិ,អាងប្រជាពលរដ្ឋ | -បឹងធម្មជាតិ |
| **គំរបដី/ការប្រើប្រាស់ដី** | -ព្រៃរបោះមានដោយកន្លែង<br>-វាលស្រែ<br>-ដីលំនៅឋាន<br>-ដីសាងសងប្រឡាយ | -វាលស្រែត្រពាំងធម្មជាតិ<br>-ត្រពាំងធម្មជាតិ<br>-អាងទឹក(វុធ) | -វាលស្រែ<br>-ដីអាងទឹកម្មជាតិ,ត្រពាំង<br>-ប្រឡាយ | -វាលស្រែ<br>-ដីអាងទឹកម្មជាតិ,ត្រពាំង<br>-ប្រឡាយ | -ព្រៃលិចទឹក<br>-បឹងធម្មជាតិ<br>-វាលស្រែ |
| **ដំណាំសំខាន់ៗ** | -ស្រូវធ្វើបានតែមួយម្តង/ឆ្នាំ<br>-ដំណាំឪឡឹក<br>-ដំណាំរួមផ្សំ(ពោត សណ្តែក ដំឡូង ននោង) | -ដំណាំស្រូវ២ដងដោយ កន្លែង<br>-ដំណាំឪឡឹកធ្វើបាន១ម្តង/ឆ្នាំ | -ស្រូវធ្វើបាន១ម្តងក្នុង១ឆ្នាំ<br>-ដំណាំឪឡឹកធ្វើបាន១ដង/ឆ្នាំ | -ដំណាំស្រូវធ្វើបាន១ម្តង/ឆ្នាំ<br>-ដំណាំឪឡឹកធ្វើបាន១ ដង/ឆ្នាំ | -ដំណាំស្រូវធ្វើបាន ១ម្តង/ឆ្នាំ |
| **ពូជស្រូវ** | -ពូជផ្កាំរំដួល(ទិញពីក្រុមហ៊ុន) ខ្លះទុកពូជខ្លះឯងខ្លះ)<br>-ពូជនាងគង់ ពូជពីបុរាណ (ពូជតៗគ្នា) | -ពូជរាំងជ័យខ្លះ<br>-ពូជ ៥០៤ (VN) | -ពូជ៥០៤ (VN) | -ពូជ៥០៤ (VN) | -ពូជ៥០៤ (VN) |

| | | | | | |
|---|---|---|---|---|---|
| | -ពូជស្រូវដំណើប(នាងនក់)<br>ពូជពីបុរាណ<br>-ពូជរាំងជ័យ (អង្គការ) | | | | |
| **ការប្រើប្រាស់ជី** | -DAP (១៨-៤៦-0)<br>-N.P.K (ក្បាលក្របី)<br>-កាលី+អ៊ុយរ៉េ ១បាវ<br>-ស្រូវពង្រួស<br>-ជីធម្មជាតិខ្លះៗ | -ស្រែវស្សាដូចគ្នានឹងតំបន់១<br>-ស្រូវប្រាំង<br>-DAP ២បាវ<br>-NPK២បាវ<br>-កាលី+អ៊ុយរ៉េ១-២បាវ សម្រាប់ស្រូវពង្រួស | -ស្រែវស្សាដូចគ្នានឹងតំបន់១<br>-ស្រូវប្រាំង<br>-DAP ២បាវ<br>-NPK២បាវ<br>-កាលី+អ៊ុយរ៉េ១-២បាវសម្រាប់ស្រូវពង្រួស | -ស្រែវស្សាដូចគ្នានឹងតំបន់១<br>-ស្រូវប្រាំង<br>-DAP ២បាវ<br>-NPK២បាវ<br>-កាលី+អ៊ុយរ៉េ ១-២បាវ សម្រាប់ស្រូវពង្រួស | -ស្រែប្រាំង<br>-DAP ២បាវ<br>-Urea ១(ស្រូវពង្រួស) |
| **ការចិញ្ចឹមសត្វ** | -គោ ក្របី<br>-មាន់ ទា ជ្រូក ក្ងាន | -គោ ក្របី<br>-មាន់ ទា | -យកគោ ក្របីទៅចិញ្ចឹម រយៈពេលចាប់ពី ខែ ១២ ដល់ ៧ | -យកគោ ក្របីទៅចិញ្ចឹម រយៈពេលចាប់ពី ខែ១២ ដល់ ៧ | -យកគោ ក្របីទៅចិញ្ចឹម រយៈពេលពីខែ ១ដល់៥ |
| **ដីរបស់រដ្ឋ ដីសហគមន៍** | -ដីទួលបុរាណចាស់ (ឈ្មោះស្បូវអំបែង)ទំហំ ប្រហែល១,១០ហ.ត<br>-ទួលស្រះស្នោ ទួល យាយពុំ ទួលលោកតា ស្ពានបាក់ ទួល លោកតាក្រហមកជាប់ថ្នល់ជាតិ ទាំងអស់មានទំហំ0,៥៩A<br>-ត្រពាំងឈូក១,១០ហិកតា<br>-ដីសហគមន៍ឃុំសាន់គ មានជ័យ ចំនួន ៩ហ.ត<br>-អូរស្ទឹងកំបុត<br>-ដីក្រុមហ៊ុន ដួង ហេង (ដីសម្បទានសេដ្ឋកិច្ចមាន ទំនាស់ជាមួយ ប្រជាពលរដ្ឋ) | -ដីត្រពាំងក្រឡាញ់<br>-ត្រពាំងក្អក់<br>-ត្រពាំងឈូករ៉ាន់<br>-បឹងអណ្តើក<br>-ស្រះសហគមន៍អំពិល<br>-ត្រពាំងកៀប<br>-ត្រពាំងមេនំ<br>-ត្រពាំងសែងទួល<br>-ត្រពាំងគ្រួស<br>-អូរស្ទឹងកំបុត<br>-ដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនដួងហេង(មាន ទំនាស់ជាមួយ ប្រជាពលរដ្ឋ) | -ត្រពាំងព្រីង<br>-បឹងចំណារ<br>-ត្រពាំងកក់វាល<br>-ត្រពាំងអង្ក្រង<br>-ដៃឈូករ៉ាន់ | -ត្រពាំង បឹងធម្មជាតិ<br>-ដីរាជអាវុធហត្ថលើ ផ្ទៃប្រទេស<br>-បឹងសហគមន៍កក់ធំ | -ដីព្រៃលិចទឹក របស់រដ្ឋ<br>-បឹងសហគមន៍ នេសាទ(បឹងស្ពុង) |

| | | | | | |
|---|---|---|---|---|---|
| | -ដីរាជអាវុធហត្ថលើផ្ទៃប្រទេស | | | | |
| **បញ្ហាផ្សេងៗ** | -បម្រែបម្រួលអាកាសធាតុ<br>-ខ្វះប្រព័ន្ធស្រោចស្រព<br>-សត្វល្អិតបំផ្លាញដំណាំ<br>-ពូជមិនសុទ្ធល្អ<br>-ជម្ងឺលើសត្វ(គោ ក្របី មាន់ ទា)<br>-ខ្វះកម្លាំងពលកម្ម<br>-ខ្វះបច្ចេកទេសផលិតកម្ម ដំណាំស្រូវ និងចិញ្ចឹមសត្វ<br>-តម្លៃស្រូវថោក | -បម្រែបម្រួលអាកាសធាតុ<br>-ខ្វះប្រព័ន្ធស្រោចស្រព<br>-សត្វល្អិតបំផ្លាញ<br>-ពូជមិនសុទ្ធល្អ<br>-ជម្ងឺលើសត្វ(គោ ក្របី មាន់ ទា)<br>-ខ្វះកម្លាំងពលកម្ម<br>-ខ្វះបច្ចេកទេសផលិតកម្ម ដំណាំស្រូវ និង ចិញ្ចឹមសត្វ<br>-តម្លៃស្រូវថោក<br>-ទំនាស់ដីក្រុមហ៊ុន ដួង ហេង ជាមួយប្រជាពលរដ្ឋ | -នេសាទត្រីខុស ច្បាប់ | -នេសាទត្រីខុស ច្បាប់ | -កាប់ទន្រ្ទានដី ព្រៃលិចទឹក<br>-នេសាទខុសច្បាប់ |
| **កាឡានុវត្តភាព/ឱកាស** | -អាចធ្វើស្រែបាន២ដង/ឆ្នាំ<br>-ពង្រីកការចិញ្ចឹមសត្វ<br>-ពង្រីកការផលិតពូជស្រូវ<br>-អាចបង្កើនផ្ទៃដីដាំដុះ (ឪឡឹក ដំឡូងមី ពោត)<br>-បង្កើនចំណេះដឹងបច្ចេកទេស | -ពង្រីកធ្វើស្រែបាន២ដង/ឆ្នាំ<br>-ពង្រីកការចិញ្ចឹមសត្វ<br>-ពង្រីកការផលិតពូជ ស្រូវ<br>-អាចបង្កើនផ្ទៃដីដាំដុះ(ឪឡឹក, ដំឡូងមី, ពោត) | -ពង្រីកការផ្សព្វផ្សាយច្បាប់នេសាទ<br>-ពង្រីកការចិញ្ចឹម សត្វ<br>-ពង្រីកការផលិតពូជស្រូវ<br>-អភិរក្សបឹងធម្មជាតិ, ត្រពាំងធម្មជាតិ | -ពង្រីកការផ្សព្វផ្សាយច្បាប់នេសាទ<br>-ពង្រីកការចិញ្ចឹម សត្វ<br>-ពង្រីកការផលិតពូជស្រូវ<br>-អភិរក្សបឹងធម្មជាតិ, ត្រពាំងធម្មជាតិ | -ពង្រីកការផ្សព្វផ្សាយច្បាប់នេសាទ<br>-អភិរក្សព្រៃលិចទឹក<br>-ផ្សព្វផ្សាយពង្រឹងលិខិតបទដ្ឋានអាជ្ញាធរទន្លេសាប និងរាជរដ្ឋាភិបាល |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសាន់គ ឆ្នាំ២០១៧*

បើយោងទៅតាមរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសាន់គ មានប្រភពទឹកពី ១)ទឹកភ្លៀង ២)បឹងចំនួន៧ ដូចជា បឹងរៀល បឹងប្រទេះជៀល បឹងស្ដង់ បឹងស្មៅ បឹងចក បឹងត្រពាំងអង្រង និងបឹងឈូកវ៉ាន់ ៣)អាងស្តុកទឹកចំនួន៤ និង៥)ស្រះទឹកចំនួន ៦០ ។ ទន្ទឹមនោះឃុំសាន់គ មានប្រឡាយនាំទឹកពីប្រភពទឹកខាងលើចំនួន ៣១ខ្សែ ប្រវែង ៩៦ ៥៩៤,៤១ម៉ែត្រ ក្នុងនោះមានប្រឡាយមេ ២ខ្សែ ប្រវែង ១៥ ៥២១,០២ម៉ែត្រ ប្រឡាយរង ៦ខ្សែ ប្រវែង ២៣ ២៦៧,១៦ម៉ែត្រ និងប្រឡាយតូចៗចំនួន ២៣ខ្សែ ប្រវែង ៥៧ ៨០៦,២៣ម៉ែត្រ ដែលបានបង្ហាញនៅក្នុងតារាខាងក្រោម។ ចំណែកទឹកក្រោមដីក្នុងឃុំសាន់គ មានការប្រើប្រាស់សម្រាប់បំពេញបន្ថែមការខ្វះខាតទឹកស្រោចស្រពផងដែរ រួមទាំងការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទៀតផង តាមរយៈការប្រើប្រាស់អណ្តូងស្នប់ ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងឃុំមានតែនៅរដូវវស្សាប៉ុណ្ណោះ ពីអាង៣០កញ្ញា តាមរយៈប្រឡាយមេ និងប្រឡាហយរង ដែលឃុំបានជីក និងស្តារសម្រាប់ការនាំយកទឹកមកស្រោចស្រពក្នុងភូមិសាស្រ្តស្រែវស្សា និងស្រែប្រាំង ក្រៅពីអាង៣០កញ្ញា ឃុំមានតែបឹង និងស្រះទឹក ជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ។

តារាង 17៖ ប្រព័ន្ធធារាសាស្រ្ត

| ល.រ | ប្រភេទប្រឡាយ | ចំនួនប្រឡាយ | ប្រវែង(ម៉ែត្រ) |
|---|---|---|---|
| ១ | ប្រឡាយមេ | ២ | ១៥៥២១.០២ |
| ២ | ប្រឡាយរង | ៦ | ២៣២៦៧.១៦ |
| ៣ | ប្រឡាយតូច | ២៣ | ៥៧៨០៦.២៣ |
| **ប្រវែងប្រឡាយសរុប** | | **៣១** | **៩៦៥៩៤.៤១** |

រូបភាព 3៖ ប្រព័ន្ធធារាសាស្រ្ត


ប្រឡាយបេតុងក្នុងឃុំសាន់គ


ប្រឡាយតូចក្នុងឃុំសាន់គ

ផែនទី 5៖ ប្រព័ន្ធស្រោចស្រព ឃុំសាន់គ




១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំសាន់គ ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់ពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅហើយសើម។ របបខ្យល់មូសុង បានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗ។

បើយោងតាមប្រភពទិន្នន័យមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកកំពង់ស្វាយ នៅក្នុងឆ្នាំ២០១៧បង្ហាញថា ស្រុកកំពង់ស្វាយ មានភ្លៀងធ្លាក់ចំនួន ៩១ដង ដែលមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ៣៦៥,៨ ម.ម។

**អំពីសីតុណ្ហភាព៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)

- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)

- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

ក្នុងឃុំសាន់គមានសំណើមជាមធ្យម៥០ភាគរយ និងមានល្បឿនខ្យល់៧គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ១,៥ | ០ | ៧៣,៨ | ៧៥,៦ | ២១២,៥ | ៨៧,៣ | ២៥៦,៧ | ១៧៣,៥ | ៩៣,៥ | ២៦៣,៧ | ៩៦,៩ | ៣០,៨ |
| ថ្ងៃមានភ្លៀង | ១ | ០ | ៣ | ៥ | ១៥ | ៩ | ១៧ | ១១ | ១០ | ៩ | ៨ | ៣ |

ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវ គោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំសាន់គ មានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ នៅក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដែលនៅក្នុងនោះ មានផ្លូវជាតិលេខ៦ ឆ្លងកាត់ ប្រវែង ១២ ៧២២,៥៩ ម៉ែត្រ មានទិសដៅពីភ្នំពេញ ទៅខេត្តសៀមរាប ដែលកាត់ភូមិមួយចំនួនក្នុងឃុំសាន់គ មានដូចជាភូមិបាឡាំង ភូមិវាល ភូមិសារី ភូមិតាំងក្រូច ភូមិសាន់គ ភូមិសំពៅមាស ភូមិសាន់គ ខ ភូមិក្បិល ភូមិក្រសាំង ក និងភូមិក្រសាំង ខ ជាច្រកចេញចូលសំខាន់សម្រាប់គ្រប់ចរាចរណ៍ពីភ្នំពេញទៅសៀមរាប ពីសៀមរាបទៅភ្នំពេញវិញ និងបណ្ដាខេត្តផ្សេងៗទៀត។ ឃុំសាន់គ ក៏នៅមានផ្លូវគ្រួសក្រហម១ខ្សែទៀត ដែលស្ថិតនៅភាគខាងត្បូងផ្លូវជាតិ ដែលមានតំណភ្ជាប់ពីផ្លូវជាតិត្រង់ភូមិសំពៅមាស ទៅកាត់នឹងភូមិប្រាសាទ ភូមិជ័យ ភូមិស្លែងខ្ពស់ និងទៅចូលផ្លូវជាតិវិញនៅត្រង់ភូមិក្រសាំង ក និងផ្លូវក្នុងឃុំផ្សេងៗគ្រប់គ្រាន់អាចតភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ រួមទាំងអាចទំនាក់ទំនងទៅក្រៅឃុំបានយ៉ាងងាយស្រួល។

ឃុំសាន់គ មានផ្លូវចំនួន ១៧៧ខ្សែ ដែលមានប្រវែង ២៨៤ ៦៧៦,៨៦ ម៉ែត្រ ក្នុងនោះមាន៖

- ផ្លូវស៊ូមាន ១ ខ្សែ ប្រវែង ១២៧ ២២,៥៩ ម៉ែត្រ
- ផ្លូវក្រាលគ្រួសក្រហមខ្សាច់ភ្នំមាន ២៧ ខ្សែ ប្រវែង ៤៦៧ ៥២,៤៨ ម៉ែត្រ
- ផ្លូវលំដីស ឬផ្លូវរទេះ ១៤៩ ខ្សែ ប្រវែង ២២៥ ២០១,៧៩ ម៉ែត្រ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម៉ែត្រ) |
|---|---|---|---|
| ១ | ផ្លូវចាក់កៅស៊ូ | ១ | ១២៧ ២២,៥៩ |
| ២ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ២៧ | ៤៦៧ ៥២,៤៨ |
| ៣ | ផ្លូវដីស ឬផ្លូវរទេះ | ១៤៩ | ២២៥ ២០១,៧៩ |

រូបភាព 4៖ ប្រព័ន្ធផ្លូវ


ផ្លូវជាតិលេខ៦នៅក្នុងឃុំសាន់គ


ផ្លូវលំនៅក្នុងឃុំសាន់គ

ផែនទី 6៖ ហេដ្ឋារចនាសម្ព័ន្ធឃុំសាន់គ



## ១.២.៤.បរិក្ខាសាធារណៈ

### ក.ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី ក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងនៅក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសាន់គ មានប្រជាពលរដ្ឋប្រើប្រាស់បណ្ដាញអគ្គិសនីចំនួន ១៣៩២ ខ្នងផ្ទះ ស្មើនឹង ៤៨,១ ភាគរយ ផ្ទះបំភ្លឺដោយអាគុយចំនួន ៩៧៩ ខ្នងផ្ទះ ស្មើនឹង ៣៣,៩ ភាគរយ ផ្ទះប្រើប្រាស់បន្ទះសូឡាមានចំនួន ៦០ ខ្នងផ្ទះ ស្មើនឹង ២,១ ភាគរយ ផ្ទះបំភ្លឺដោយជីវឧស្ម័ន មិនមាននោះទេ នៅក្នុងនោះផ្ទះប្រើប្រាស់អគ្គិសនីមានចំនួនច្រើនជាងគេ និងផ្ទះប្រើប្រាស់បន្ទះសូឡាមានចំនួនតិចជាងគេ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦ភាគរយ | ២០១៧ | |
|---|---|---|---|
| | | ភាគរយ | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្ដាញអគ្គិសនី | ២៥,៧ | ៤៨,១ | ១៣៩ ២ |
| ផ្ទះបំភ្លឺដោយអាគុយ | ៥៧,១ | ៣៣,៩ | ៩៧៩ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៦,0 | ២,១ | ៦0 |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | 0,0 | 0,0 | 0 |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

### ខ.ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹក ត្រពាំង ឬអណ្ដូងដៃ ងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅជនបទ។ នៅក្នុងឃុំសាន់គ បានចំណាយថវិកាមូលនិធិឃុំ ឬបានកៀរគរធនធានពីខាងក្រៅ ក្នុងការសាងសង់ អណ្ដូងទឹក និងស្រះទឹក ដែលមានការកើនឡើងយ៉ាងច្រើន ដែលគួរឱ្យកត់សម្គាល់ ដូចជា អណ្ដូងស្នប់ឬអណ្ដូងចម្រុះមានចំនួន ៤៣២ អណ្ដូង អណ្ដូងជីកមានការពារចំនួន ៥៥៦ អណ្ដូង អណ្ដូងជីកគ្មានការពារ ២៧៧ អណ្ដូង និងស្រះទឹកដែលប្រើប្រាស់មាន ១២ ស្រះ។

តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់

| ល.រ | បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|---|
| ១ | ចំនួនអណ្ដូងស្នប់ឬអណ្ដូងចម្រុះ | ៣៨៥ | ៤៣២ |
| ២ | ចំនួនអណ្ដូងជីកមានការពារ | ៥៣៧ | ៥៥៦ |
| ៣ | ចំនួនអណ្ដូងជីកគ្មានការពារ | ២៧០ | ២៧៧ |
| ៤ | ចំនួនស្រះទឹកដែលប្រើប្រាស់ | ១២ | ១២ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំសាន់គ ខែមេសា ២០១៨*

## ១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រង

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំសាន់គ



ផែនទី ៩៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំសាន់គ



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីនីមួយៗ

| ប្រភេទដីប្រើប្រាស់ | បរិយាយ | ទំហំ(ហិតា) | ទំហំ(%) |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **៣៧៩** | **១៧១** |
| **ក.១.ដីលំនៅឋាន ភូមិ** | | **៣៧៩** | **១,៧១** |
| - ដីលំនៅឋាន ភូមិក្រៅតំបន់ការពារ | ដីភូមិ | ៤៦ | ០,២១ |
| - ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីភូមិ | ៣៣៣ | ១,៥០ |
| **ខ.ដីកសិកម្ម** | | **១៨ ១៧៤** | **៨១,៨៤** |
| **ខ.១.ដីស្រែវស្សា** | **ដីស្រែ** | **៨ ៦៧៦** | **៣៩,០៣** |
| - ដីស្រែវស្សាក្រៅតំបន់ការពារ | ដីស្រែវស្សា | ៥ ០៧៨,២៨ | ២៣,៤៨ |
| - ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែវស្សា | ៣ ៤៥៦ | ១៥,៥៥ |
| - ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ដីស្រែវស្សា | ១៤១,៧២ | ០,៦៤ |
| **ខ.២.ដីស្រែប្រាំង** | **ដីស្រែ** | **៩ ៤៩៨** | **៤២,៧៨** |
| - ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ៣ ០៣១ | ១៣,៦៥ |
| - ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ៥ ៥៩៣ | ២៥,១៩ |
| - ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង | ៨៧៤ | ៣,៩៤ |
| **គ.ដីព្រៃ/គម្របព្រៃ** | | **១៦៩៩** | **៨,២២** |
| គ.១.ព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ | ដីទួល | ១៦ | ០,៦៤ |
| គ.២.ព្រៃលិចទឹក | ព្រៃលិចទឹក | ១ ៦៨៣ | ៧,៥៨ |
| - ព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ព្រៃលិចទឹកក្នុងតំបន់២ | ៩ | ០,០៤ |
| - ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ព្រៃលិចទឹកក្នុងតំបន់៣ | ១ ៦៧៤ | ៧,៥៤ |
| **ង.ផ្ទៃទឹក និងខ្សែទឹក** | | **១ ៩៥៤** | **៨,៨០** |
| ង.១.បឹង | បឹង | ៥១២ | ២,៣១ |
| - បឹងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | បឹងក្នុងតំបន់១ | ២ | ០,០១ |
| - បឹងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | បឹងក្នុងតំបន់២ | ៩១ | ០,៤១ |
| - បឹងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | បឹងក្នុងតំបន់៣ | ៤១៩ | ១,៨៩ |
| ង.២.អាងស្តុកទឹក | | ១ ៤០៧ | ៦,៣៤ |
| - អាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប | អាងទឹកក្នុងតំបន់១ | ៤៩៧ | ២,២៤ |
| - អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | អាងទឹកក្នុងតំបន់២ | ៩១០ | ៤,១០ |
| ង.៣.ស្រះ | | ៣៥ | ០,១៦ |

| | | | |
|---|---|---|---|
| - ស្រះក្រៅតំបន់ការពារ | ស្រះទឹក | ៦ | ០,០៣ |
| - ស្រះទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ស្រះទឹកក្នុងតំបន់១ | ២៩ | ០,១៣ |
| **សរុបផ្ទៃដីក្នុងឃុំ** | | **២២ ២០៦** | **១០០** |

### ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

### ក.១.ដីលំដីលំនៅឋាន ភូមិ

ដីលំនៅឋាន ភូមិ ជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នៅក្នុងឃុំសាន់គ ដីលំនៅឋានភូមិ មានទំហំផ្ទៃដីសរុបចំនួន ៣៧៩ ហិកតា ដែលភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយផ្លូវជាតិលេខ៦ ក្នុងនោះមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិ ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានចំនួន ០៩ ភូមិ គឺភូមិប្រាសាទ ភូមិបាឡាំង ភូមិតាំងក្រូច ភូមិសារី ភូមិសំពៅមាស ភូមិក្បិល ភូមិសាន់គ ក ភូមិក្រសាំង ក និងភូមិក្រសាំង ខ ដែលមានទំហំផ្ទៃដីសរុបចំនួន ៤៦ ហិកតា ព្រមទាំងមួយផ្នែកនៅខាងត្បូងតាមបណ្តោយផ្លូវជាតិលេខ ៦ និងមួយផ្នែកទៀត នៅខាងត្បូងផ្លូវជាតិចូលទៅក្នុងដែលឃ្លាតពីផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិ ស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានចំនួន ១៣ភូមិ គឺភូមិប្រាសាទ ភូមិបាឡាំង ភូមិតាំងក្រូច ភូមិវាល ភូមិសារី ភូមិសំពៅមាស ភូមិក្បិល ភូមិសាន់គ ក ភូមិសាន់គ ខ ភូមិក្រសាំង ក ភូមិក្រសាំង ខ ភូមិសំពៅមាស និងភូមិអំពិល ដែលមានទំហំផ្ទៃដីចំនួន ៣៣៣ ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក ដែលមានប្រភេទក្រុមដីប្រទះឡាង និងក្រុមដីបាកាន (ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ) ពណ៌ត្នោត និងជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) កំពុងដំណើការចុះបញ្ជីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០ ភាគរយ ។

រូបភាព 5៖ លំនៅឋានភូមិ



ទិដ្ឋភាពលំនៅឋានភូមិ



ទិដ្ឋភាពលំនៅឋានភូមិក្នុងតំបន់១

## ខ.ដីកសិកម្ម

### ខ.១.ដីស្រែវស្សា

នៅក្នុងឃុំសាន់គ ដីស្រែវស្សាមានផ្ទៃដីសរុបទំហំ ៨ ៦៧៦ ហិកតា ក្នុងនោះមានមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ជាដីស្រែវស្សាស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៥ ២២០ ហិកតា និងមួយផ្នែកទៀត ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ជាដីស្រែវស្សាស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ៣៤៥៦ ហិកតា ។ ក្នុងតំបន់ដីស្រែវស្សាទាំងនេះមានទួលបុរាណចំនួន ០៩កន្លែង គឺទួលអ្នកតាជ័យ ទួលខ្នា ទួលអង្កាញ់វៀន ទួលព្រះធាតុ ទួលស្បូវអំបែង ទួលយាយពុំ ទួលច្រេស ទួលស្រះស្មោ និងទួលក្តីអង្គង។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គ នៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ ជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក ដែលមានប្រភេទក្រុមដីប្រទះឡាង និងក្រុមដីបាកាន(ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ) ពណ៌ត្នោត និងជាដីកម្មសិទ្ធិឯកជន ហើយត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ លើកលែងតែដីទួលបុរាណទាំង៩កន្លែងខាងលើ ជាដីសាធារណៈរបស់រដ្ឋ ហើយកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ៣០ភាគរយ។ ដីស្រែវស្សាទាំងនេះ មានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួចប្រជាពលរដ្ឋនៅក្នុងឃុំតែងតែនាំគ្នាដាំដំណាំរួមផ្សំថែមទៀតមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្វៀរស្ទាក់ទឹកស្ទឹងស្ទោង នៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែគឺ ប្រឡាយ ៣០ កញ្ញា ព្រមទាំងអាងស្តុកទឹកតូចៗចំនួន ១១ កន្លែង បឹងធម្មជាតិ នៅភាគខាងត្បូងឃុំ និងស្រះទឹកចំនួន ៦០ កន្លែង ដែលភាគច្រើនមាននៅលើដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប និងមានតិចតួចនៅលើដីស្រែវស្សាក្រៅតំបន់ការពារ ជាភាគខាងជើងនៃឃុំ ។

**- ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំសាន់គមានដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ ទំហំផ្ទៃដីសរុបចំនួន ១៤១,៧២ ហិកតា ចំនួន ០៣ទីតាំង ស្ថិតនៅភាគខាងជើងឃុំជាប់ព្រំប្រទល់ឃុំដំរីស្លាប់ ។ ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ ២០០២ ជាតំបន់ទំនាបខ្ពស់ និងមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាដីស្រែ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០កញ្ញា ដែលមានទំនប់បង្វៀរស្ទាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោង។

រូបភាព ៦៖ ស្រូវវស្សា



ដីស្រែវស្សាក្រៅតំបន់ការពារ



ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប

ខ.២.ដីស្រែប្រាំង

**-ដីស្រែប្រាំងក្នុងតំបន់១ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅកណ្តាលឃុំ ដោយចាប់គិតឃ្លាតពីផ្លូវជាតិលេខ៦ ប្រមាណមួយគីឡូម៉ែត្រឆ្ពោះទៅទិសខាងត្បូងឃុំ រហូតដល់ប្រមាណ ២គីឡូម៉ែត្រ ដែលមានទំហំផ្ទៃដីសរុបចំនួន ៣០៣១ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ក្សេត្រ-បរិស្ថាន II គឺជាតំបន់រាបស្មើជម្រាលទាបជាង តំបន់ក្សេត្រ-បរិស្ថាន I ដែលមានប្រភេទក្រុមដីក្រគរ និងក្រុមដីគោកត្រប់(កណ្តេងខ្លះល្បាយខ្សាច់)ប្រផេះស្រាល ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ហើយកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈ ប្រព័ន្ធបានចំនួន ៣០ ភាគរយ និងមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០កញ្ញា ដែលមាន ទំនប់បង្ហៀរស្នាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោងដែលបាននាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈ ប្រឡាយមេមួយខ្សែ គឺប្រឡាយ៣០កញ្ញា ។

**-ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាបស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ៥ ៥៩៣ហិកតា ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ក្សេត្រ-បរិស្ថាន III និងតំបន់ក្សេត្រ-បរិស្ថាន IIIA គឺជាតំបន់ ដែលមានសណ្ឋានដីរាបស្មើទាបជាងតំបន់ក្សេត្រ-បរិស្ថានII មានប្រភេទក្រុមដីក្រគរ ក្រុមដីក្បាលពោ (កណ្តេងសុទ្ធពណ៌ខ្មៅប្រផេះ) និង ដីល្បាប់ចាស់ ហើយជាដីសាធារណៈរបស់រដ្ឋ ដែលមិនទាន់ត្រូវបានចុះបញ្ជី កាន់កាប់ដីជាលក្ខណៈប្រព័ន្ធ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិ ចាត់ចែងអ្វីនោះឡើយ ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និង អាងស្តុកទឹក ៣០កញ្ញា ដែលមានទំនប់បង្ហៀរស្នាក់ទឹកស្ទឹងស្ទោង ស្ថិតនៅក្នុងស្រុកស្ទោង ដែលបាននាំទឹកមកពី ភាគខាងជើងមកស្រោចស្រពតាមរយៈ ប្រឡាយមេមួយខ្សែគឺ ប្រឡាយ ៣០ កញ្ញា ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ការពារព្រៃលិចទឹក នៅភាគខាងត្បូងនៃឃុំ ដែលមានទំហំផ្ទៃដីសរុបចំនួន ៨៧៤ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គ នៃរបាយការណ៍ វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ក្សេត្រ-បរិស្ថាន IV គឺជា តំបន់ទំនាបព្រៃលិចទឹក មានប្រភេទក្រុមដីក្បាលពោ(កណ្តេងសុទ្ធពណ៌ខ្មៅប្រផេះ) ដីកណ្តេងពពាយកណ្តុរ និង ដីល្បាប់ចាស់ ជាដីសាធារណៈរបស់រដ្ឋ ស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់គ្រប់ប្រភេទ ដែលមិនទាន់ត្រូវ បានចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនោះទេ ។ ក្នុងករណីដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំសាន់គពិតមែន គឺត្រូវស្នើសុំធ្វើការដោះស្រាយ ក្នុងការផ្តល់ដីស្រែនៅក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជា នានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្សៀលដីនេះជូនមែន ក៏ដីទាំងនេះ មិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិ ចាត់ចែងនោះឡើយ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និង

អាងស្តុកទឹក ៣០កញ្ញា ដែលមានទំនប់បង្ងៀរស្ទាក់ទឹកស្ទឹងស្ទោងស្ថិតក្នុងនៅស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែគឺប្រឡាយ ៣០កញ្ញា ។

រូបភាព 7៖ ស្រូវប្រាំង

| | |
|---|---|
|  |  |
| ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប |

### គ.ព្រៃគុម្ពោត/គម្របព្រៃ

### គ.១.ព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ

នៅក្នុងឃុំសាន់គមានព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយស្ថិតនៅខាងជើងចាប់ពីផ្លូវជាតិលេខ៦ ដែលជាព្រៃនៅលើដីទួលជាច្រើនកន្លែងដាច់ពីគ្នាក្នុងតំបន់វាលស្រែ ដែលមានទំហំផ្ទៃដីសរុបចំនួន ១៦ ហិកតា សម្បូរទៅដោយដើមឈើធំមានដូចជា ដើមក្រសាំង អំពិល កកោះ តាសេក ចម្រៀក ខ្លុងត្បែង និងដើមត្រយឹងជាដើម។ ដីព្រៃគុម្ពោតនិងដើមឈើដុះរាយប៉ាយ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយប្រជាពលរដ្ឋ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំសាន់គនៃរបាយការណ៍ វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ ជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក ដោយមានប្រភេទក្រុមដីប្រទះឡាង និងក្រុមដីបាកាន ( ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ ) ពណ៌ត្នោត។

រូបភាព ៨៖ ព្រៃគុម្ពោត និងវាលស្មៅ

 

### គ.២.ព្រៃលិចទឹក

**-ព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ព្រៃលិចទឹកនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប  គឺជាដីដែលត្រូវបានរាជរដ្ឋាភិបាល កំណត់ឱ្យប្រជាពលរដ្ឋជួយថែរក្សាទុក ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នា ដូចជា ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្នាច់ ដើមរាំងជាដើម ។ ព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ០៩ ហិកតា គឺជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវការពារ ហើយស្ថិតនៅលើទីតាំងដីភាគខាងត្បូងនៃឃុំ  មានស្ថានភាពដីទាបលិចទឹកជំរាលរាបស្មើ ជាប្រភេទក្រុមដីក្បាលពោ ដីកណ្ដេង  ដីពាយកណ្ដុរ និងដីល្បាប់ចាស់ ។ បច្ចុប្បន្ន ព្រៃលិចទឹកទាំងនេះ ត្រូវបានទទួលរងការកាប់បំផ្លាញពីសំណាក់បងប្អូនប្រជាពលរដ្ឋ  ដើម្បីយកដីធ្វើស្រែ  យកឈើធ្វើសំរាស់  ធ្វើឧសដុត  និងដុតព្រៃចាប់សត្វអណ្ដើក និងឃ្មុំជាដើម។

**-ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅចុងភាគខាងត្បូងនៃឃុំ ជាដែនការពារព្រៃលិចទឹកជុំវិញបឹងទន្លេសាប ហាមដាច់ខាតការកាប់រាន ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក និងការសាងសង់សំណង់គ្រប់ប្រភេទ ។ ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១ ៦៧៤ហិកតា ដែលសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នា ដូចជា ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្នាច់ និងដើមរាំងជាដើម  ហើយបច្ចុប្បន្ននេះ បានទទួលរងការកាប់បំផ្លាញព្រៃទាំងនេះពីសំណាក់បងប្អូនប្រជាពលរដ្ឋ ដើម្បីយកដីធ្វើស្រែ យកឈើធ្វើ សម្រាស់ ធ្វើឧសដុត និងដុតព្រៃយកសត្វអណ្ដើក ឃ្មុំជាដើម។

រូបភាព ១៖ ព្រៃលិចទឹក



ព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប



ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

### ង.ផ្ទៃទឹក និងខ្សែទឹក

#### ង.១.ដីបឹង

នៅឃុំសាន់គ មានបឹងចំនួន ០៧ កន្លែង ដូចជា បឹងរៀល បឹងប្រទេះជៀល បឹងស្លង់ បឹងស្មៅ បឹងចក បឹងត្រពាំងអង្រង និងបឹងឈូករ៉ាន់ ដែលមានទំហំផ្ទៃដីសរុបចំនួន ៥១២ ហិកតា នៅក្នុងនោះមានបឹងចំនួន ០១ កន្លែងទំហំផ្ទៃដីចំនួន ០២ ហិកតា ស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប និងមានបឹង ០២ កន្លែង ទំហំផ្ទៃដីចំនួន ៩១ ហិកតាស្ថិតក្នុងតំបន់២ជុំវិញបឹងទន្លេសាប  ព្រមទាំងមានបឹង ០៤ កន្លែងទៀត ទំហំផ្ទៃដីចំនួន ៤១៩ ហិកតា ស្ថិតក្នុងតំបន់

៣ជុំវិញបឹងទន្លេសាប។ បឹងធម្មជាតិទាំងនេះ ជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្នត្រូវបាននិងកំពុងប្រើប្រាស់ សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសនោះស្រែប្រាំង និងការប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 10៖ បឹងធម្មជាតិ



ង.២.អាងស្តុកទឹក

**-អាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានចំនួន ៤ កន្លែង មានផ្ទៃដីសរុបទំហំ ៩៩៧ ហិកតា។ អាងស្តុកទឹកទាំងនេះ ជាដីកម្មសិទ្ធិឯកជន ដែលកាន់កាប់ដោយប្រជាពលរដ្ឋ បច្ចុប្បន្នត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងការប្រើប្រាស់ផ្សេងៗទៀត ទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ។

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានចំនួន ០៣ កន្លែង មានផ្ទៃដីសរុបទំហំ ៩១០ ហិកតា។ អាងស្តុកទឹកនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែ អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយក្នុងបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ។

រូបភាព 11៖ អាងស្តុកទឹក



ង.៣.ស្រះទឹក

នៅក្នុងឃុំសាន់គ មានស្រះទឹកសរុបចំនួន ៦០ កន្លែង មានទំហំផ្ទៃដីសរុបចំនួន ៣៥ ហិកតា ក្នុងនោះ មានចំនួន ៨កន្លែង មានផ្ទៃដីទំហំ ០៦ ហិកតា ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ដែលភាគច្រើនស្ថិតនៅក្នុងតំបន់ស្រែវស្សា ក្បែរតំបន់លំនៅឋានភូមិ តាមបណ្តោយផ្លូវជាតិលេខ៦ប៉ែកខាងជើងឃុំ និងមានស្រះទឹកចំនួន ៥២ កន្លែង មានផ្ទៃដីទំហំ ២៩ ហិកតា ស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប ដែលភាគច្រើនស្ថិតនៅក្នុងតំបន់ស្រែវស្សា ក្បែរតំបន់លំនៅឋានភូមិនៅតាមបណ្តោយផ្លូវជាតិលេខ៦ប៉ែកខាងត្បូងឃុំ។ ដីស្រះទឹកទាំងអស់នៅក្នុងឃុំសាន់គ ជាកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ចាត់ចែងដោយប្រជាពលរដ្ឋ លើកលែងតែស្រះទឹកអម្ពិលមួយស្ថិតនៅក្នុងតំបន់១ប៉ុណ្ណោះ ដែលជាកម្មសិទ្ធិរបស់រដ្ឋ ។ បច្ចុប្បន្នដីស្រះទាំងអស់ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងការប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 12៖ ស្រះទឹក



ពាក់ព័ន្ធបញ្ហាផ្សេងៗ នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ តាមរយៈការសម្ភាសន៍លោកមេឃុំ បានឱ្យដឹងថា មានប្រជាពលរដ្ឋនៅក្នុងឃុំចំនួន ៦៥គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ២៧៨ គ្រួសារមិនមានដីធ្វើរបរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀត ពួកគាត់រស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំសាន់គវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ដោយសារតែដីក្នុងឃុំទាំងមូល កំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធ។

### ១.៣.២.ផលិតកម្មកសិកម្ម

#### ក.ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀង នៅក្នុងឃុំសាន់គ បានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំទាំងនេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ ឃុំដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់ សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ផលិតកម្មដំណាំស្រូវបានផលិតនៅលើផ្ទៃដីស្រែសរុបទំហំ ១៨ ១៧៤ ហិកតា ដែលជាប្រភេទក្រុមដីបាកាន (ខ្សាច់+ឥដ្ឋខ្សាច់ល្បាយ)ពណ៌ត្នោតនៅប៉ែកខាងជើងនៃឃុំ ដែលបច្ចុប្បន្នធ្វើស្រែបានតែម្តងគត់ នៅក្នុងរដូវវស្សា ហើយនិយមប្រើប្រាស់ពូជស្រូវផ្ការំដួល(ទិញពីក្រុមហ៊ុន) ស្រូវនាងគង់ ស្រូវពីបុរាណ(ពូជតៗគ្នា)ស្រូវដំណើប(នាងនក់) និងពូជស្រូវរាំងជ័យ(អង្គការ) ព្រមទាំងមានប្រភេទក្រុមដីក្រគរ ក្រុមដីក្បាលពោ(កណ្តេងសុទ្ធ ពណ៌ខ្មៅប្រផេះ) ក្រុមដីគោកត្រប់ ដីល្បាប់ចាស់ នៅប៉ែកកណ្តាលនៃឃុំ ដែលបច្ចុប្បន្នធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ ដោយកន្លែង ហើយនិយមប្រើប្រាស់ពូជស្រូវរាំងជ័យ និងពូជស្រូវ ៥០៤(VN) ។ ការស្រោចស្រពដំណាំស្រូវក្នុងឃុំសាន់គ បានប្រើប្រាស់ទឹកពីប្រភពទឹកភ្លៀង និងអាងស្តុកទឹក៣០កញ្ញា ដែលស្ថិតនៅក្នុងស្រុកស្ទោងមានចម្ងាយប្រមាណជាង ១២គីឡូម៉ែត្រ ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រឡាយ៣០កញ្ញា ហើយក៏មានប្រភពទឹកពីបឹងធម្មជាតិ អាងស្តុកទឹក និងស្រះទឹកផងដែរ ដោយមានប្រើប្រាស់ប្រព័ន្ធប្រឡាយរង និងប្រឡាយតូចមួយចំនួន ដែលបច្ចុប្បន្ន នៅមានការខ្វះខាតនៅឡើយ។ ជាទូទៅឃុំសាន់គ បានទទួលផលស្រូវវស្សាជាមធ្យម ២តោន/ហ.ត និងស្រូវប្រាំងជាមធ្យម ៣,៥ តោន/ហ.ត ហើយបានពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៧នេះ ឃុំទទួលបានផលស្រូវសរុបចំនួន ៣១ ៥៨៦តោន ក្នុងនោះស្រូវវស្សាមានចំនួន ១១៨ ៦៧ តោន និងស្រូវប្រាំងមានចំនួន ១៩៧១៩តោន។ ផលស្រូវដែលទទួលបានទុកហូបចំនួន ៣០ភាគរយ ស្មើនឹង ៩៤៧៦តោន ទុកពូជចំនួន ១០ ភាគរយ ស្មើនឹង ៣១៥ ៨ តោន ចំណែកស្រូវដែលនៅសល់ប្រមាណ ១៨៩៥២តោន បានលក់ចេញក្នុងតម្លៃ ៧៥៤ រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ១៤ ២៩០ លានរៀល។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ | - ដីស្រែធំទូលាយរហូត ៨២ភាគរយ នៃផ្ទៃដីសរុប<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាពនាំទឹកពីប្រភពស្ទឹងស្ទោង ប្រឡាយ៣០កញ្ញា បឹងធម្មជាតិ អាងប្រជាពលរដ្ឋ មកផ្គត់ផ្គង់ការស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដង |

| | |
|---|---|
| - ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) ។ | ក្នុងមួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

រូបភាព 13៖ ដំណាំស្រូវ

| | |
|---|---|
|  |  |
| ទិដ្ឋភាពស្រូវកំពុងលូតលាស់នៅក្នុងឃុំសាន់គ | ទិដ្ឋភាពស្រូវទុំនៅក្នុងឃុំសាន់គ |

### ខ.ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំសាន់គ បច្ចុប្បន្នមានដូចជា ឪឡឹក ពោត សណ្តែក ននោង ល្ពៅជាដើម ដែលប្រជាពលរដ្ឋក្នុងឃុំសាន់គធ្វើការដាំដុះជាលក្ខណៈគ្រួសារនៅលើដីស្រែវស្សា បន្ទាប់ពីច្រូតកាត់ស្រូវ រួចរាល់ មានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកាន (ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ) ពណ៌ត្នោត ដែលទទួលបានការស្រោចស្រពពីប្រភពទឹកភ្លៀងនិងអាងស្តុកទឹក៣០កញ្ញាដែលស្ថិតនៅក្នុងស្រុកស្ទោងមានចម្ងាយប្រមាណប្រហែលជាង ១២គីឡូម៉ែត្រ ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រឡាយ៣០កញ្ញា ហើយក៏មានប្រភពទឹកពីបឹងធម្មជាតិ អាងស្តុកទឹកទឹក និងស្រះទឹកផងដែរ។ ផលិតផលដំណាំរួមផ្សំទាំងនេះ បានជួយផ្គត់ផ្គង់ការហូបចុក និងលក់ដូរបន្តិចបន្តួច សម្រាប់ជួយដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ ជាទូទៅទិន្នផលដែលទទួលបានមិនទាន់បានខ្ពស់នៅឡើយទេ ដោយសារដំណាំទាំងនេះតែងជួបនូវបញ្ហាមួយចំនួនដូចជា សត្វល្អិត ជម្ងឺ និងមិនទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការដាំដុះដំណាំទាំងនេះ ហើយក៏មានការខ្វះខាតឧបករណ៍ និងពូជល្អដើម្បីផលិតផងដែរ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានដីតិចតួចនៅជុំវិញលំនៅឋាន<br>- ដីខ្វះជីជាតិ<br>- ខ្វះទឹកស្រោចស្រពនៅរដូវប្រាំង<br>ការយល់ដឹងពីបច្ចេកទេសដាំដំណាំ របស់ប្រជា | - មានដីស្រែ<br>- មានប្រភពទឹកភ្លៀង ទឹកស្រះ និងទឹកក្រោមដី សម្រាប់ការស្រោចស្រព<br>- ប្រជាពលរដ្ឋមានការយល់ដឹងពីសារៈប្រយោជន៍នៃ |

| | |
|---|---|
| ពលរដ្ឋនៅមានកម្រិត។ | ដំណាំរួមផ្សំដែលអាចជួយផ្គត់ផ្គង់ដល់ការហូបចុក ដោះស្រាយដល់ជីវភាពរស់នៅប្រចាំថ្ងៃ កាត់បន្ថយបានលើការចំណាយ។ |

រូបភាព 14៖ ដំណាំរួមផ្សំ


ដំណាំឪឡឹកក្នុងឃុំសាន់គ


ដំណាំសណ្តែកក្នុងឃុំសាន់គ

### គ.ផលិតកម្មឧស្សាហកម្ម

នៅឃុំសាន់គ ប្រជាពលរដ្ឋមិនបានធ្វើការដាំដុះដំណាំឧស្សាហកម្មនោះទេ ដោយសារតំបន់នេះជាតំបន់ទំនាបលិចទឹក ស្ថានភាពដីមិនសមស្របទៅនឹងដំណាំនេះទេ។

## ១.៣.៣.ធនធានធម្មជាតិ

### ក.ធនធានព្រៃឈើ

នៅក្នុងឃុំសាន់គ បច្ចុប្បន្នមានព្រៃឈើតិចតួច ដែលជាព្រៃគុម្ពោតមានដុះដើមឈើមួយៗរាយប៉ាយ នៅលើដីទួលជាច្រើនកន្លែងនៅតាមវាលស្រែនៅប៉ែកខាងជើងផ្លូវជាតិលេខ៦ មានទំហំផ្ទៃដីសរុប១៦ហិកតា ស្មើនឹង ០,០៧ ភាគរយ ។ ដីទួលទាំងនេះមានដើមឈើមួយចំនួន ដូចជា ដើមកកោះ តាសេក ចម្រៀក ត្រយឹង និងដើមល្ពាក់ជាដើម។ល។ ទោះបីបច្ចុប្បន្ននេះ នៅក្នុងឃុំសាន់គមានព្រៃគុម្ពោតតិចតួចមែន តែឃុំមានព្រៃលិចទឹកច្រើនរហូតដល់ ១ ៦៨៣ ហិកតា ស្មើនឹង ៧.៥៨ភាគរយ ដែលសម្បូរទៅដោយដើមរាំង អញ្ចាញ ត្រោះ ភ្នំភ្លើង បបួយ តាសែង និងទ្រនំអែអូតជាដើម ដែលរាជរដ្ឋាភិបាលបានកំណត់ជាដែនការពារដាច់ខាតសម្រាប់ការធានាបាននូវនិរន្តរភាពបរិស្ថាន និងប្រព័ន្ធជីវចម្រុះបឹងទន្លេសាប ជាពិសេសនោះ ការធានាជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ជាដើម។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការកាប់ឈើសម្រាប់ធ្វើជាឱសដុត និងប្រើប្រាស់ផ្សេងៗ<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនិងព្រៃលិចទឹកនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើ និងព្រៃលិចទឹកនៅមិនទាន់ | - មានច្បាប់ស្តីពីព្រៃឈើដែលបានកំណត់ករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមដាំដើមឈើ<br>- មានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដល់ការចូលរួមដាំដើមឈើរបស់ប្រជាពលរដ្ឋ<br>- មានការផ្តល់នូវជំនួយបច្ចេកទេសដាំដើមឈើពី |

| | |
|---|---|
| បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | រដ្ឋបាលព្រៃឈើ។<br>- មានដីតាមដងផ្លូវសាធារណៈប្រព័ន្ធប្រឡាយ សាលារៀន មណ្ឌលសុខភាព វត្តអារាម តាមភូមិ ដែលអាចដាំដើមឈើបាន |

**ខ.ធនធានជលផល**

នៅក្នុងឃុំសាន់គ បច្ចុប្បន្នមានបឹងចំនួន ១១ កន្លែង មានផ្ទៃដីសរុបចំនួន ៥១២ ហិកតា ដែលក្នុងនោះមានបឹងរៀល បឹងប្រទះជៀល បឹងស្លូង បឹងស្មៅ បឹងចក បឹងត្រពាំងអង្រ្គង បឹងឈូកវ៉ាន់ ដែលចេញពីបឹងប្រទះជៀលទៅឃុំកំពង់គោ ដែលចេញពីបឹងប្រទះជៀល ដែលបឹងទាំងអស់នេះស្ថិតនៅភាគខាងត្បូងនៃឃុំ។ ទន្ទឹមនេះ ឃុំសាន់គ នៅមានអាងស្តុកទឹកចំនួន ៧កន្លែង មានផ្ទៃដីសរុបចំនួន ១ ៤០៧ហិកតា ដែលអាងទាំងនោះស្ថិតនៅផ្នែកកណ្តាលឃុំ ក្នុងតំបន់ស្រែប្រាំង ព្រមទាំងស្រះចំនួន ៦០ កន្លែង មានផ្ទៃដីទំហំ ០៦ ហិកតា ដែលភាគច្រើនស្ថិតនៅភាគខាងផ្លូវជាតិលេខ ៦ នៅលាយឡំជាមួយនឹងលំនៅឋាន និងស្រែវស្សា។ ចំពោះបឹង អាងស្តុកទឹក និងស្រះទាំងអស់សម្បូរទៅដោយ ក្តាម ខ្យង ត្រីរ៉ស់ ត្រីឆ្តោរ ត្រីទក់ ត្រីក្រាញ់ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចង្វា។ល។ ហើយបច្ចុប្បន្ន ត្រូវបានប្រជាពលរដ្ឋនេសាទជាលក្ខណៈគ្រួសារបានផលនេសាទតិចតួច សម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារ តែក្នុងនោះក៏មានគ្រួសារខ្លះនេសាទបានសល់ពីហូបចុកបានលក់ដូរខ្លះដែរ ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្រប នាំឱ្យមានការថយចុះបរិមាណធនធានជលផល<br>- ការនេសាទខុសច្បាប់។ | - មានស្ទឹង បឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល<br>- មានច្បាប់ជលផល។ |

**១.៣.៤.ធនធានរ៉ែ**

នៅក្នុងឃុំសាន់គ មិនមានទិន្នន័យពីជំនាញពាក់ព័ន្ធអំណះអំណាងពីវត្តមានធនធានរ៉ែ នៅក្នុងឃុំគួរឱ្យកត់សម្គាល់បាននោះទេ គឺជាក់ស្តែងឃើញមានតែវាលស្រែគ្របដណ្តប់ស្ទើរទូទាំងឃុំប៉ុណ្ណោះ។

## ១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងឃុំសាន់គមានតែផលិតផលស្រូវ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវដែលសល់ពីការហូបចុកអាចធ្វើការនាំចេញទៅរកទីផ្សារមានប្រភេទស្រូវប្រដេញទឹក ( ពូជ ៥០៤ ) ស្រូវនាងគង់ និងស្រូវផ្ការំដួល។ យោងទៅតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំសាន់គ ឆ្នាំ២០១៧ បានឱ្យដឹងថាប្រភេទស្រូវប្រដេញទឹក ( ពូជ ៥០៤ ) មានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសវៀតណាម ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម ៧០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ ដែលមានតម្លៃចាប់ពី ៧២០-៩២០រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវផ្ការំដួលវិញ មានទីផ្សារនៅក្នុងប្រទេស និងទីផ្សារនៅប្រទេសប្រទេសវៀតណាមដូចគ្នា ប្រជាពលរដ្ឋតែងលក់ស្រូវសើម ៨០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំដែរ មានតម្លៃ ១ ៥០០-១ ៨០០ រៀលនៅក្នុងមួយគីឡូក្រាម ព្រមទាំងស្រូវនាងគង់មានតែទីផ្សារនៅប្រទេស

វៀតណាម ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម ៧០ ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងឃុំ មានតម្លៃត្រឹម ៨០០៖-៩០០ រៀលក្នុងមួយគីឡូក្រាម។

តារាង 27៖ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | តម្លៃជារៀលទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | ស្រូវប្រដេញទឹក(ពូជ៥០៤) | ១ គ.ក្រ | ៧២០-៩២០ | | វៀតណាម |
| ២ | ស្រូវផ្ការំដួល | ១ គ.ក្រ | ១,៥០០-១,៨០០ | | វៀតណាម |
| ៣ | ស្រូវនាងគង់ | ១ គ.ក្រ | ៨០០៖-៩០០ | | វៀតណាម |

## ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកេសិត្រ-បរិស្ថានឃុំសាន់គ ឆ្នាំ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននេះនៅក្នុងឃុំសាន់គ  មានការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញ គឺត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវ ដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង ៥០ភាគរយ និងមានការទិញចូល ៥០ ភាគរយ  ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូតដល់ច្រូតកាត់ ដែលប្រើដោយគ្រឿងយន្តរហូតដល់ ៩៥ ភាគរយ  និងច្រូតកាត់ដោយដៃតែ ៥ ភាគរយ ប៉ុណ្ណោះ ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ១០ ភាគរយ និងទុកផ្គត់ផ្គង់សម្រាប់ការហូបចុកប្រមាណ ២ ភាគរយ ចំណែកផលស្រូវនៅសើម ដែលសល់ប្រមាណជា ៥០ ភាគរយ ត្រូវយកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ១៥០០-១៨០០រៀលក្នុងមួយគីឡូក្រាម  ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារនៅក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ ចំពោះស្រូវនាងគង់ពូជត្រូវបានទុកដោយខ្លួនឯង ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជី និងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្ត ៩០ ភាគរយ និងច្រូតកាត់ដោយដៃតែ ១០ ភាគរយ ចំណែកផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ ១០ ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ២០ ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៧០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃត្រឹមតែ ៨០០-៩០០ រៀល ក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម  និងមួយចំនួនទៀតបន្តលក់ឱ្យម៉ាស៊ីនកិនស្រូវបានតម្លៃ ៨០០-៩០០រៀល ក្នុងមួយគីឡូក្រាម ដូចគ្នា។ តែចំពោះស្រូវប្រដេញទឹក(ពូជ ៥០៤)វិញ ត្រូវបានទិញពីគ្នាឯងនៅក្នុងឃុំ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិតរហូតដល់ច្រូតកាត់ ដែលប្រើប្រាស់ដោយគ្រឿងយន្ត១០០ភាគរយ ចំណែកផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ ២០ ភាគរយ និងទុកផ្គត់ផ្គង់សម្រាប់ការហូបចុកប្រមាណ ១០ ភាគរយ ប៉ុណ្ណោះ  ចំណែកផលស្រូវនៅសើមសល់ប្រមាណ ៧០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃចាប់ពី ៧២០-៩២០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញក៏បន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

## គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់






### ១.៤.៣.ឧបសគ្គ និងឱកាស

តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ ដោយគិតការប្រាក់ខ្ពស់រហូតដល់២ភាគរយក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម។ | - មានឈ្មួញមកទិញដល់កន្លែង<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផល<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច។ |

# ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១.តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍឃុំ

ក.ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ (២០១៨-២០២២)

ផែនការអភិវឌ្ឍឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីធ្វើការដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការ ជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំយ៉ាងមានប្រសិទ្ធភាព តាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ ដែលមានរយៈពេលប្រាំឆ្នាំ សម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ។ តារាងក្របខ័ណ្ឌអភិវឌ្ឍឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបានស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងជាគោលដៅអភិវឌ្ឍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សា ចង់បានតាមវិស័យនីមួយៗ។ ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗខាងលើ។

ចំណែកឃុំសាន់គ ក្រុមប្រឹក្សាឃុំនៅក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំ ក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍឃុំ ដូចមាន ខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលទៅក្នុងតារាងខាងក្រោម៖

តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ ២០១៨ | -កែលម្អជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក | -កសាងច្រកផ្លូវបេតុង<br>-ជួសជុលផ្លូវលំគ្រួសក្រហម/ខ្សាច់ភ្នំ<br>-គម្រោងសាងសង់លូកាត់ផ្លូវ<br>-គម្រោងសាងសង់ផ្លូវលំដីស | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ | -ស្តារប្រឡាយស្រោចស្រព<br>-ធ្វើអាងស្តុកទឹក<br>-ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |

| | | | | | |
|---|---|---|---|---|---|
| ៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ឆ្នាំឲ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន៩ឆ្នាំ<br>-ចំនួនអនក្ខរជននឹងថយនៅត្រឹម២% | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឲ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជម្រុញការយល់ដឹងដល់ឪពុកម្ដាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតថ្នាក់មត្តេយ្យ<br>-ផ្តល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយឱ្យឪពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់សម្ភារសិក្សាដល់សិស្សក្រីក្រ<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឲ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាក់សាំងការពារជម្ងឺ០៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើសុំគ្រូពេទ្យ និងថ្នាំ<br>-ជួសជុលជីកអណ្តូងទឹកស្អាត<br>-ធ្វើទស្សនកិច្ចសិក្សាយកបទពិសោធន៍ ពីកន្លែងផ្សេងៗ<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្របង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លងដូចជារបេង ថ្លើម គ្រុនចាញ់ និងគ្រុណឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.ឃុំមានបរិស្ថាន និង ធនធានធម្មជាតិស្រស់បំព្រង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឲ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -បណ្តុះបណ្តាលច្បាប់ការពារព្រៃសហគមន៍<br>-បណ្តុះបណ្តាលច្បាប់វក្ខាប្រមាញ់ និងនេសាទត្រីខុសច្បាប់<br>-ដាំកូនឈើតាមទីសាធារណៈ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិ | |
| ៦.ឃុំអាចផ្គត់ផ្គង់បាននូវតម្រូវការថាមពល | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋនៅក្នុងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -លើកកម្ពស់ការយល់ដឹង ផ្នែកធនធាន ធម្មជាតិ និងបរិស្ថាន | -បច្ចេកទេសប្រើចង្រ្កាន ជីវឧស្ម័ន<br>-បច្ចេកទេសប្រើចង្ក្រានសន្សំឧស<br>-ផ្សព្វផ្សាយច្បាប់ការពារព្រៃឈើ | |
| ៧.ធ្វើឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | សាលាឃុំ | -ភូមិឃុំមានសន្តិសុខនិងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារភូមិ ដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់ | -បង្កើតប៉ុស្តិ៍ស្ម័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិឃុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជីអត្រានុកូលដ្ឋានបានគ្រប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់ | |

| | | | | | |
|---|---|---|---|---|---|
| | | | ភូមិ-ឃុំ | គ្រឿងញៀន<br>-កាត់បន្ថយល្បែងស៊ីសងគ្រប់ប្រភេទ<br>-បំផុសឱ្យចូលរួមសហការណ៍ជាមួយសមត្ថកិច្ច | |
| ៨.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជម្រុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់គ្រងដីធ្លីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗ<br>-ជម្រុញឲ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឲ្យបានច្បាស់លាស់ | |
| ៩.ទិន្នផលកសិកម្មកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិតកសិកម្ម | -បង្កើនចំណេះដឹងបច្ចេកទេសដាំដុះដល់កសិករ<br>-ផ្សព្វផ្សាយការប្រើប្រាស់ពូជផ្តល់ទិន្នផលខ្ពស់និងស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>-បង្កើនប្រសិទ្ធភាពការប្រើប្រាស់គ្រឿងយន្តកសិកម្ម<br>-បង្កើនបច្ចេកទេសការគ្រប់គ្រងផលិតផលស្រូវមុននិងក្រោយពេលប្រមូលផល<br>-ជម្រុញអនុវត្តប្រពលវប្បកម្មដំណាំស្រូវ<br>-បណ្តុះបណ្តាលពីសាលារៀនទីផ្សាកសិក<br>-ផ្តល់ចំណេះដឹងពីការកែឆ្នៃវេចខ្ចប់ទុកដាក់ផលិតផល<br>-បង្កើនទំនាក់ទំនងព័ត៌មានទីផ្សាផលិផល | |
| ១០.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០០៨-២០១២ | -ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់ | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -ជីកអណ្តូងលូ ស្នប់ ស្រះសហគមន៍<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹក | |
| ១១សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឲ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រីនិងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រីនិងកុមារ<br>-បណ្តុះបណ្តាលពីតួនាទីយេនឌ័រ | |
| ១២.សត្វព្រៃមានការកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនវិធានការការពារសត្វព្រៃ | -ជម្រុញការផ្សព្វផ្សាយច្បាប់និងពង្រឹងវិធានការ | ដាក់ទោសឬផាកពិន័យអ្នកសម្លាប់សត្វព្រៃ<br>-ផ្សព្វផ្សាយច្បាប់ការពារសត្វព្រៃ | |

| | | | | | |
|---|---|---|---|---|---|
| | | | ទប់ស្កាត់<br>-សហការជាមួយស្ថាប័នពាក់ព័ន្ធពង្រឹងការការពារសត្វព្រៃ | | |
| ១៣.ទិន្នផលត្រីកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនធនធានជលផល | -ជម្រុញការបង្កើតវារីវប្បកម្ម | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ជ្រើសរើសទីតាំងល្អ<br>-ផ្តល់ឥណទាន<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង | |
| ១៤.គ្រួសារចិញ្ចឹមសត្វកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជម្រុញការផ្តល់បច្ចេកទេសជំនាញកសិកម្ម<br>-ជម្រុញការផ្តល់បច្ចេកទេសចិញ្ចឹមថែទាំសុខភាពសត្វនិងជ្រើសរើសពូជ | -ចាក់វ៉ាក់សាំងការពារជម្ងឺគោក្របីឲ្យបានទៀងទាត់<br>-ផ្តល់ឥណទានគោក្របី<br>-ផ្តល់ឥណទានមានការប្រាក់ទាប | |
| ១៥.កាត់បន្ថយមរណៈមាតា និងទារកក្រោយសម្រាល | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល | -ពង្រឹងនិងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជម្រុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជម្រុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ០៧មុខ | |
| ១៦.ឲ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ទូទាំងឃុំមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជម្រុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្តាញអគ្គិសនីតាមភូមិ | |

ប្រភព៖ *សៀវភៅផែនការអភិវឌ្ឍឃុំ ២០១៨-២០២២*

## ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំសាន់គ បច្ចុប្បន្នមិនមានគម្រោងណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍឃុំឡើយ។

ផែនទី ១៖ គម្រោងវិនិយោគជាអាទិ៍ភាពឃុំសាន់គ




## ២.១.២.ចំណោលប្រជាសាស្រ្តគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំនុចសំខាន់ណាស់សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជននៅក្នុងឃុំនេះរយៈពេល ១៥ ឆ្នាំខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលត្រូវបានបង្ហាញនៅក្នុងជំពូកទី១ បានឱ្យដឹងថាគឺ ១,៥៥ ភាគរយ ដូច្នេះ ប្រជាពលរដ្ឋនៅក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ ២០៣២ ដែលត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៨៩៧១នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ១,៥៥ %

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំៈ **១៨ ៩៧១ នាក់** x ១,៥៥ % = **២៩៤ នាក់/ឆ្នាំ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបានៈ ២៩៤ នាក់/ឆ្នាំ** x **១៥ ឆ្នាំ** = **៤ ៤១០ នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខទៀត: ១៨ ៩៧១នាក់ + ៤ ៤១០នាក់ = ២៣ ៣៨១ នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៨ ៩៧១ នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ៣ ៦៩៩ គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺ:

**១៨ ៩៧១ នាក់ /៣ ៦៩៩ គ្រួសារ = ៥,១៣នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

**៤ ៤១០នាក់/ ៥,១៣នាក់/គ្រួសារ = ៨៦០គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមាន:

**៣ ៦៩៩គ្រួសារ + ៨៦០គ្រួសារ = ៤ ៥៥៩គ្រួសារ**

តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ៣៦៩៩ | ១៨៩៧១ | ៩៦៧៨ |
| ២០២២ | ៣៩៨៧ | ២០៤៤៤ | ១០៤២៩ |
| ២០២៧ | ៤២៧៤ | ២១៩១៦ | ១១១៨១ |
| ២០៣២ | ៤៥៥៩ | ២៣៣៨១ | ១១៩៣២ |

**☞ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំ x ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ + ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ១ ០៥១ | ៥៣៨ | ១ ១៣២ | ៥៨០ | ១ ២១៤ | ៦២១ | ១ ២៩៥ | ៦៦៣ |
| អាយុពី៣-៤ | ៩៥២ | ៥០៧ | ១ ០២៦ | ៥៤៦ | ១ ១០០ | ៥៨៦ | ១ ១៧៣ | ៦២៥ |
| អាយុ៥ឆ្នាំ | ៦៤០ | ៣២៦ | ៦៩០ | ៣៥១ | ៧៣៩ | ៣៧៧ | ៧៨៩ | ៤០២ |
| អាយុ៦-១១ឆ្នាំ | ២ ៦៥២ | ១ ៣១៣ | ២ ៨៥៨ | ១ ៤១៥ | ៣ ០៦៤ | ១ ៥១៧ | ៣ ២៧០ | ១ ៦១៩ |
| អាយុ១២-១៤ឆ្នាំ | ១ ៧៣៩ | ៩០៦ | ១ ៨៧៤ | ៩៧៦ | ២ ០០៩ | ១ ០៤៧ | ២ ១៤៤ | ១ ១១៧ |
| អាយុ១៥-១៧ឆ្នាំ | ១ ៧៨៤ | ៩៣៣ | ១ ៩២២ | ១,០០៥ | ២ ០៦១ | ១ ០៧៨ | ២ ១៩៩ | ១ ១៥០ |
| អាយុ១៨-២៤ឆ្នាំ | ២ ១១៣ | ១ ០៨១ | ២ ២៧៧ | ១ ១៦៥ | ២ ៤៤១ | ១ ២៤៩ | ២ ៦០៥ | ១ ៣៣៣ |
| អាយុ២៥-៦០ឆ្នាំ | ៦ ៣៧០ | ៣ ២៤២ | ៦ ៨៦៤ | ៣ ៤៩៤ | ៧ ៣៥៩ | ៣ ៧៤៥ | ៧ ៨៥៣ | ៣ ៩៩៧ |
| អាយុ៦១ឆ្នាំ | ១ ៦៧០ | ៨៣២ | ១ ៨០០ | ៨៩៧ | ១ ៩២៩ | ៩៦១ | ២ ០៥៩ | ១ ០២៦ |
| ប្រជាជនសរុប | ១៨៩៧១ | ៩៦៧៨ | ២០៤៤៤ | ១០៤២៩ | ២១៩១៦ | ១១១៨១ | ២៣ ៣៨១ | ១១៩៣២ |
| ចំនួនគ្រួសារ | ៣ ៦៩៩ | | ៣ ៩៨៧ | | ៤ ២៧៤ | | ៤ ៥៥៩ | |

### ២.១.៣.តម្រូវការដីជាមូលដ្ឋាន

#### ក.ដីលំនៅឋាន

ចំពោះដីភូមិ គឺសំដៅទៅលើដីសម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំនៅជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ៣៧៩ ហិកតា និងមានគ្រួសារសរុបចំនួន ៣ ៦៩៩ គ្រួសារ ជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារចំនួន ៦៥ គ្រួសារ ប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងតែរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈ និង គ្រួសារមួយចំនួនទៀតកំពុងតែរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ធ្វើការដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំតាមការសម្រេចចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**៣៧៩ ហិកតា / ៣ ៦៩៩ គ្រួសារ = 0,១០ ហិកតា/ គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើន 0,២៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយជូន ៦៥ គ្រួសារ ដែលគ្មានដីលំនៅឋានពិតប្រាកដ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីឃុំសាន់គនេះ។

ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៤ ៤១០ នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៥,១៣ នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន 0,១០ ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៤ ៤១០ នាក់/៥,១៣នាក់/គ្រួសារ = ៨៦0 គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ**

**៨៦0 គ្រួសារ x 0,១០ ហិកតា/គ្រួសារ = ៨៦ ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងឃុំសាន់គត្រូវកើនឡើងដល់ៈ**

**៣៧៩ ហិកតា + ៨៦ ហិកតា = ៣ ៤៦៥ ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៦៥ គ្រួសារតាមរយៈ

សម្បទានសង្គមកិច្ចមានចំនួនៈ **៦៥ គ្រួសារ x 0,២៥ ហិកតា/គ្រួសារ = ១៦,២៥ ហិកតា**

តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ៦៩៩ គ្រួសារ | ៤ ៥៥៩ គ្រួសារ | ៨៦0 គ្រួសារ |
| តម្រូវការដីលំនៅឋាន | ៣៧៩ ហិកតា | ៣ ៤៦៥ ហិកតា | ៨៦ ហិកតា |

## ខ.ដីកសិកម្ម

ចំពោះដីកសិកម្ម គឺសំដៅទៅលើដីសម្រាប់ធ្វើស្រែនិងដីចម្ការដំណាំ។ នៅក្នុងឆ្នាំ២០១៧ ជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ១៩១២៣,១៣ហិកតា និងមានគ្រួសារសរុបចំនួន៣៦៩៩គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះ សម្រាប់ធ្វើការនាំចេញទៅទីផ្សារ អាចដោះស្រាយជីវភាពរស់នៅ បានសមរម្យ លើកលែងតែគ្រួសារចំនួន ២៧៨គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

**១៨១៧៤ហិកតា / ៣៦៩៩គ្រួសារ = ៥ ហិកតា/ គ្រួសារ**

តែបើតាមអនុក្រឹត្យលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន២ហិកតាក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនប្រជាពលរដ្ឋ ២៧៨ គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋ ដែលមាននៅទីតាំងផ្សេងពីឃុំសាន់គ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៨៦០ គ្រួសារ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ**

**៨៦០គ្រួសារ x ៥ហិកតា/គ្រួសារ = ៤៣០០ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**១៨១៧៤ហិកតា + ៤៣០០ហិកតា = ២២៤៧៤ហិកតា**

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ២៥០ គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **២៧៨គ្រួសារ x ២ ហិកតា/គ្រួសារ =៥៥៦ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់កសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ៣ ៦៩៩ គ្រួសារ | ៤ ៥៥៩ គ្រួសារ | ៨៦០ គ្រួសារ |
| តម្រូវការដីកសិកម្ម | ១៨ ១៧៤ ហិកតា | ២៣ ៥៦៩,៣៣ ហិកតា | ៤ ៣០០ ហិកតា |

## គ.ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល ឧស និងអនុផលនានា មានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមជនបទតាមរយៈការប្រើប្រាស់ដោយផ្ទាល់ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះព្រៃឈើក៏បានដើរតួយ៉ាងសំខាន់នៅក្នុងចំណោមតួនាទីដទៃទៀត ដូចជា ការទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញនូវឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូនិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ (ជួយទប់ទល់នឹងខ្យល់ព្យុះ ទឹកជំនន់ ជួយការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់

ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាប គឺជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ។

ចំពោះស្ថានភាពប្រើប្រាស់ដីធ្លីបច្ចុប្បន្ននៅក្នុងឃុំសាន់គ បានឱ្យដឹងថា នៅក្នុងឃុំមានព្រៃគុម្ពោតចំនួន ១៦ ហិកតា ស្មើនឹង ០,០៧ ភាគរយ នៃផ្ទៃដីឃុំទាំងមូល និងមានព្រៃលិចទឹកទំហំផ្ទៃដី ១ ៦៨៣ ហិកតា ស្មើនឹង ៧,៥៨ភាគរយ នៃដីឃុំទាំងមូល ដែលក្នុងស្ថានភាពបែបនេះនៅពេលអនាគត ឃុំសាន់គមិនមានតម្រូវការពង្រីកផ្ទៃដីបន្ថែម សម្រាប់ព្រៃឈើនោះទេ ក្រៅតែពីការដាំដើមឈើបន្ថែមខ្លះៗនៅលើដីសាធារណៈផ្សេងៗ ដូចជាតាមដងផ្លូវ ប្រឡាយ អាងស្តុកទឹក សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើមប៉ុណ្ណោះ ។

### ឃ.ធនធានទឹក

ឃុំសាន់គ ជាឃុំមានសក្តានុពលទៅលើផ្នែកកសិកម្ម ដំណាំស្រូវ ដែលនាំឱ្យឃុំនេះ មានគោលដៅអភិវឌ្ឍ រយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវនេះ មិនអាចគេចចេញបានឡើយ។ ដូច្នេះដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើន គឺមានកត្តាទឹកជាកត្តាសំខាន់ដែរ ដែលត្រូវយកចិត្តទុកដាក់ដោយត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់ សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែទាំងអស់ដែលឃុំមាន ដើម្បីជួយដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួត និងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ដល់ការហូបចុកនិងជំរុញការនាំចេញបង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

ចំពោះឃុំសាន់គបច្ចុប្បន្ន មានបឹង អាងស្តុកទឹក និងស្រះ ដែលមានទំហំផ្ទៃដីសរុបចំនួន ១៩៥៤ហិកតា ស្មើនឹង ៨,៨០ ភាគរយ នៃផ្ទៃដីឃុំទាំងមូល។ នាពេលអនាគត ស្ថានភាពដីនៅក្នុងឃុំសាន់គ មិនមានអំណោយផលសមស្របទៅដល់ការរៀបចំអាងស្តុកទឹកបន្ថែម ដើម្បីបំពេញតម្រូវការដល់ការស្រោចស្រពដែលនាំឱ្យឃុំមិនមានតម្រូវការដី បន្ថែម សម្រាប់ប្រភពធនធានទឹកនោះទេ ។

### ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១.វិស័យអប់រំ

កុមារគ្រប់រូប មានសិទ្ធិចូលរៀនសូត្រដូចគ្នា មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញនៅក្នុងឃុំសាន់គទៅថ្ងៃអនាគត ក្នុងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនាក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

- **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៤ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ១៧៣ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលានៅក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ ៥០នាក់

-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ

**១ ១៧៣ នាក់ /៥០ នាក់/បន្ទប់= ២៣បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**២៣បន្ទប់ / ៥ បន្ទប់/អគារ = ៥ អគារ**

- **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ៣២៧០នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ

**៣២៧០នាក់ ៖ ៤៥នាក់/បន្ទប់ = ៧៣បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ

**៧៣បន្ទប់ ៖ ៦ បន្ទប់/អគារ = ១២អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**១២អគារ/វេន ៖ ២ វេន = ៦អគារ**

- **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ២ ១៤៤នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ(២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

**២ ១៤៤នាក់ ៖ ៤៥នាក់/បន្ទប់ = ៤៨ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**៤៨ បន្ទប់ ៖ ១២បន្ទប់/អគារ = ៤ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៤អគារ / វេន ៖ ២ វេន = ១ អគារ**

- **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ២១៩៩ នាក់

-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ

**២១៩៩ នាក់ ៖ ៤៥នាក់/បន្ទប់ = ៤៩ បន្ទប់**

-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ

**៤៩ បន្ទប់ ៖ ១២បន្ទប់/អគារ = ៤អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ

**៤ អគារ / វេន ៖ ២ វេន = ១ អគារ**

តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

| បរិយាយ | បច្ចុប្បន្ន២០១៧ | អនាគត ២០៣២ | បម្រែបម្រួល |
|---|---|---|---|
| សាលាមត្តេយ្យ | | | |
| សិស្ស | ៤៧ នាក់ | ១ ១៧៣ នាក់ | ១ ១២៦ នាក់ |

| | | | |
|---|---|---|---|
| បន្ទប់ | ២ បន្ទប់ | ២៣ បន្ទប់ | ២១ បន្ទប់ |
| អគារ | ២ អគារ | ៥ អគារ | ៣ អគារ |
| សាលាបឋមសិក្សា | | | |
| សិស្ស | ៣១៩៤នាក់ | ៣ ២៧០ នាក់ | ៧៦ នាក់ |
| បន្ទប់ | ៧៥បន្ទប់ | ៧៣ បន្ទប់ | -២ បន្ទប់ |
| អគារ | ១០អគារ | ១២ អគារ | ២ អគារ |
| អនុវិទ្យាល័យ | | | |
| សិស្ស | ៦៥០ នាក់ | ២១៤៤ នាក់ | ១ ៤៩៤ នាក់ |
| បន្ទប់ | ១៧បន្ទប់ | ៤៨ បន្ទប់ | ៣១ បន្ទប់ |
| អគារ | ២អគារ | ៤ អគារ | ២ អគារ |
| វិទ្យាល័យ | | | |
| សិស្ស | 0 | ២ ១៩៩ នាក់ | ២ ១៩៩ នាក់ |
| បន្ទប់ | 0 | ៤៩ បន្ទប់ | ៤៩ បន្ទប់ |
| អគារ | 0 | ៤ អគារ | ៤ អគារ |

### ង.២.សម្រាប់វិស័យសុខាភិបាល

យោងទៅតាមការស្រាវជ្រាវរកឃើញដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថា ឃុំសាន់គ មានមណ្ឌលសុខភាពមួយកន្លែង ដែលមានលទ្ធភាពផ្តល់សេវាកម្មក្នុងការព្យាបាលជូនប្រជាពលរដ្ឋនៅក្នុងឃុំសមស្របរួចហើយ ដែលទៅថ្ងៃអនាគត ១៥ឆ្នាំទៅមុខនឹងមិនមានតម្រូវការដីសម្រាប់រៀបចំទីតាំងផ្តល់សេវាកម្មសុខាភិបាលបន្ថែមនោះទេ ដោយគ្រាន់តែធ្វើការជំរុញការផ្តល់សេវាពីមណ្ឌលសុខភាព ដែលមានស្រាប់មួយនេះ ដើម្បីបម្រើជូនដល់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានប្រសើរឡើងតែប៉ុណ្ណោះ ហើយក៏នឹងអាចផ្តល់លទ្ធភាពឱ្យមានគ្លីនិកឯកជនបំពេញបន្ថែមទៀតផងដែរ។

### ង.៣.អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជាជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ។

បើយោងទៅតាមទិន្នន័យពីមន្ទីរផែនការនៅក្នុងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងឃុំសាន់គ មានប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីចំនួន៤៨ភាគរយ ហើយនៅសល់គ្រួសារប្រមាណ៥២ភាគរយ ដែលមិនទាន់បានទទួលសេវាកម្មនេះនៅឡើយ។ ដូច្នេះនៅពេលអនាគត១៥ឆ្នាំទៅមុខ នឹងមានការកើនឡើងនូវចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំសាន់គ ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់។

### ង.៤.ទីលានចាក់សំរាម

សំរាម គឺជារបស់អ្វីៗដែលធ្លាក់ក្បែរខ្លួនមនុស្ស ឬធ្លាក់ទៅកន្លែងផ្សេងៗ។ ដូច្នេះសំរាមគឺជាអ្វីៗដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ មានគំនរសំរាម នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលទៅដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាគត្បាតផ្សេងៗ ដោយសារតែការទទួលទានទឹកមិនស្អាត។

ចំពោះសំរាមនៅក្នុងឃុំសាន់គបច្ចុប្បន្ននេះប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកទីតាំងដីក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមចេញពីផ្ទះបាយ និងស្លឹកឈើផ្សេងក្រៅពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត ត្រូវលុបបំបាត់សំរាមប្លាស្ទីកឱ្យអស់ពីភូមិ ឃុំ។

### ង.៥.ដីកប់ខ្មោច

ជាទូទៅពិធីបូជាសព មានពីបែប គឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះ គឺពីធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដី សម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍនៅក្នុងសហគមន៍ ដែលមនុស្សរស់នៅ។ នៅក្នុងឃុំសាន់គបច្ចុប្បន្ន ក៏មានប្រើពីធីទាំងពីរនេះដែរ ហើយការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ក៏មានតម្រូវការកាន់តែច្រើនឡើង ស្របនឹងកំណើនរបស់ប្រជាពលរដ្ឋទៅថ្ងៃអនាគត ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធ ហើយជាពិសេសនោះ ក្រុមប្រឹក្សាឃុំសាន់គ ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសពដោយកប់នៅក្នុងដី ហើយជំនួសមកវិញដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិដែលជាជម្រើសល្អបំផុត។

### ង.៦.ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្សគ្រប់រូប។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែទឹកទាំងនោះមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត។ ឃុំសាន់គបច្ចុប្បន្ននេះ មានការប្រើប្រាស់ទឹកស្អាត សម្រាប់ទទួលទានតាមរយៈការប្រើប្រាស់ទឹកស្រះ និងទឹកអណ្តូងដូចដែលបានរៀបរាប់នៅក្នុងជំពូកទី១ នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះមិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ននេះ ក៏ដូចជា ឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំសាន់គត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋនៅក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សា រក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួន សម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលខ្សត់ទឹកហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីក

ស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជន ឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត។

## ២.២.តំបន់រសើប

តំបន់រសើប គឺជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីជានាថាឃុំ/សង្កាត់ត្រូវការដឹងពួនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។

នៅក្នុងឃុំសាន់គ តំបន់រសើបមានតំបន់ការពារព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ១ ៦៧៤ ហិកតា ដែលទាមទារនូវកិច្ចការពារបន្ថែមពិសេសនោះដោយសារតំបន់នេះមានសារៈសំខាន់ដល់ការធានាលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ហើយក៏មានទួលបុរាណចំនួន ០៩ កន្លែង គឺទួលអ្នកតាជ័យ ទួលខ្នា ទួលអង្កាញ់វៀន ទួលព្រះធាតុ ទួលស្បូវអំបែង ទួលយាយពុំ ទួលច្រេស ទួលស្រះស្មោ និងទួលក្តីអង្កុង ដែលទាមទារនូវកិច្ចការពារបន្ថែមពិសេសដែរនោះ ដោយសារតែតំបន់នេះ មានសារៈសំខាន់ផ្នែកវប្បធ៌ម ប្រវត្តិសាស្ត្រ តាមរយៈការធ្វើកំណាយសិក្សាស្រាវជ្រាវស្វែងរកសំណល់ជាភ័ស្តុតាង ដែលនាំឱ្យដឹងពីប្រវត្តិសាស្ត្រពីយូរលង់មកហើយ ព្រមទាំងតំបន់ដីសង្ស័យថាមានមីន មានផ្ទៃដីទំហំ ២៦៧,៤១ ហិកតា ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែមពិសេសដើម្បីធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះ ដែលនាំឱ្យពួកគាត់មានគ្រោះថ្នាក់ពីគ្រាប់មីន ដែលមិនទាន់ផ្ទុះ។ តំបន់រសើបដែលមាននៅក្នុងឃុំសាន់គ ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម។

ផែនទី 10៖ ផែនទីតំបន់រសើបឃុំសាន់គ



## ២.៣.ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

#### ក.កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងឃុំសាន់គ បានរកឃើញថា ប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំ គិតជាមធ្យមប្រមាណ ១,៥៥ ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានធ្វើការគិតគូរដោះស្រាយ ដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកក្នុងការដោះស្រាយ ដោយសារតែនៅក្នុងឃុំ ពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ។

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយដូចជាការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយដូចជា គ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំសង្កូវបន្ថែម។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម។

#### ខ.គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្ននេះនៅក្នុងឃុំសាន់គ គេបានកត់សម្គាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិ កើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម ។ ទន្ទឹមនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងឃុំសាន់គ ក៏មានភាពរេចរឹលទៅៗផងដែរ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិ ដោយសារតែការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតនៅលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផល ជាពិសេសនោះមច្ឆាជាតិ ដោយការនេសាទខុសច្បាប់ មានដូចជាការប្រើប្រាស់ឧបករណ៍ឆក់ នេសាទនៅរដូវបិទនេសាទជាដើម ។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងឃុំនៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនជាមិនមានយន្តការ ឬដំណោះស្រាយដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួត ព្រមទាំងមិនមានការកែប្រែឥរិយាបថ នៅក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញ បើគម្រោងអភិវឌ្ឍទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមាន វានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះ ដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយ ដូចជាស្ថានភាពនៅក្នុងឃុំសាន់គជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចអ្វីដែលបានរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះបានឱ្យដឹងថា នៅឃុំសាន់គ មានស្ថានភាពភូមិសាស្ត្រ ជាតំបន់វាលទំនាបមានធនធានដីអំណោយផលដល់

ដំណាំស្រូវ ដែលជាសក្តានុពលសម្រាប់ការអភិវឌ្ឍដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ។ ដូចនេះក្នុងឃុំសាន់គ គួរចៀសវាងជាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែ ដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍ ដូចជាគម្រោងចាក់លុបដីស្រែ បង្កកទុកលក់ ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម។ លើកលែងតែគម្រោងណាពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជាកសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍប៉ះពាល់ដល់ការរស់នៅ និងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយការអភិវឌ្ឍខាងលើ ដែលត្រូវចៀសវាង ក៏មានការប្រឈមនឹងអំពើអនាធិបតេយ្យ ដែលកើតឡើង ពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងឃុំផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់នៅតាមមាត់ប្រឡាយ តាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីព្រៃ ធ្វើស្រែបំពានទៅលើប្រឡាយ និងបឹង ជាដើម។

## ២.៤.ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារៈសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់ធ្វើ ដូចជាមនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឱសដុត សម្រាប់ផ្តល់កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែក ទង់ដែង ជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំសាន់គ យើងផ្តោតសំខាន់លើធនធានដី ដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ។ នៅក្នុងឃុំសាន់គមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ នៅពេលដែលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ
- អាកាសធាតុក្តៅ ហើយសើមអំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

### ២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។ បច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង សម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងឃុំសាន់គ គឺមានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះដដែលដែរនោះ ប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដែលអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាព

រស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង នៅក្នុងពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់នាពេលខាងមុខ ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ដ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត ឃុំសាន់គ ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ និងដំណាំចម្ការ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ ព្រមទាំងគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្ម ដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងឃុំសាន់គ។ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 35៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១.ខ្វះខាតដីលំនៅឋាន (៦៥គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល<br>ខ-កំណើនគ្រួសារក្នុងភូមិ | ក-ខ- ដោះស្រាយតាមរយៈដីសម្បទានសង្គមកិច្ច |
| ២.ខ្វះដីកសិកម្ម (២៧៨គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល<br>ខ-កំណើនគ្រួសារក្នុងភូមិ<br>គ-ដីកសិកម្មតិច | ក-ខ-គ-១-ស្នើសុំសម្បទានសង្គមកិច្ច<br>ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| ៣.ដីសង្ស័យថាមានមីន  | -ភូមិក្បិល<br>-ភូមិសារី<br>-ស្លែងខ្ពស់ | ក-ជាកន្លែងសមរភូមិប្រយុទ្ធសម័យសង្គ្រាម | ក-១-ដាក់សញ្ញាសម្គាល់ដីដែលមានមីន និងគ្រប់មិនទាន់ផ្ទុះ<br>ក-២-ហាមឃាត់មិនឱ្យប្រជាពលរដ្ឋចូលទៅក្នុងតំបន់សង្ស័យថាមានមីន |

| | | | |
|---|---|---|---|
| ៤.បាត់បង់ព្រៃលិចទឹក  | តំបន់៣ជុំវិញបឹងទន្លេសាប | ក-កាប់រានយកដីធ្វើស្រែប្រាំង | ក-១-មានវិធានការទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក<br>ក-២-ត្រូវអនុវត្តច្បាប់ដោយការដាក់ទោសទណ្ឌចំពោះអ្នកកាប់បំផ្លាញព្រៃឈើ<br>ក-៣-ផ្សព្វផ្សាយអនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹកស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប |
| ៥-ទិន្នផលស្រូវទាប  | ដីស្រែ | ក-ដីខ្វះជីជាតិ | ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត<br>ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក-៣-ជំរុញការចិញ្ចឹមសត្វដើម្បីបានលាមក |
| | | ខ-ខ្វះបច្ចេកទេសកសិកម្ម | ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ<br>ខ-២-បណ្តុះបណ្តាលការដាំដំណាំស្រូវ<br>ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ខ-៤-បណ្តុះបណ្តាលបច្ចេកទេសផលិតជីកំប៉ុស្ត<br>ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធតាមស្តង់ដា |
| ៦-ផ្លូវរងការខូចខាត  | -ផ្លូវគ្រួសក្រហមបែកចេញពីផ្លូវជាតិលេខ៦ត្រង់ភូមិសាន់គខ្លោះទៅភាគខាងជើងនៃឃុំស្របតាមប្រឡាយ៣០កញ្ញា<br>-ផ្លូវគ្រួសក្រហមបែកចេញពីផ្លូវជាតិលេខ៦ត្រង់ភូមិក្រសាំងខតាមបណ្តោយប្រឡាយរងទៅទល់នឹងប្រឡាយ៣០កញ្ញា<br>-ផ្លូវគ្រួសក្រហមបែកចេញពីផ្លូវជាតិលេខ៦ត្រង់ភូមិក្រសាំងកទៅភាគខាងជើង<br>-ផ្លូវលំដីសពីផ្លូវជាតិលេខ៦ត្រង់ភូមិក្បិលទៅភាគខាងត្បូងនៃឃុំ | ក-ឡានធុនធ្ងន់ដឹកលើសទម្ងន់ឆ្លងកាត់ | ក-១-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ទប់ស្កាត់ឡានដឹកលើសទម្ងន់តាមរយៈដាក់សញ្ញាកំណត់ទម្ងន់ដឹកជញ្ជូនរបស់រថយន្ត<br>ក-២-ដាក់បារាស់កាត់ផ្លូវដែលមានរថយន្តធំឆ្លងកាត់ |
| | | ខ-ខ្វះការថែទាំផ្លូវ | ខ-១- ថែទាំផ្លូវ ខួប ជាប្រចាំ<br>ខ-២-បង្កើតគណៈកម្មការថែទាំផ្លូវ |

| | | | |
|---|---|---|---|
| | -ផ្លូវលំដីសបែកចេញពីផ្លូវជាតិលេខ៦ត្រង់ភូមិក្បិលទៅភាគខាតត្បូងនៃឃុំទៅទល់នឹងអាស្តុកទឹក<br>-ផ្លូវលំដីសបែកចេញពីផ្លូវជាតិលេខ៦ទៅភូមិស្លែងខ្ពស់<br>-ផ្លូវលំដីសពីផ្លូវជាតិលេខ៦ទៅភូមិអំពិល | | |
| ៧-ធនធានមច្ឆាថយចុះ និងបាត់បង់<br> | បឹង<br>អាងស្តុកទឹក | ក-នេសាទខុសច្បាប់ | ក-១-ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា<br>ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ |
| ៨-ខ្វះទឹកស្អាតប្រើប្រាស់ | ក្នុងឃុំ | ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | ក-១-យកចិត្តទុកដាក់ជម្រុញឱ្យមានសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតបានគ្រប់ភូមិ |
| | | ខ-គ្រួសារមួយចំនួនខ្វះសម្ភារៈបរិក្ខារចម្រោះទឹកស្អាត | ខ-១-បំផុសឱ្យប្រជាពលរដ្ឋមានការប្រើប្រាស់ធុងចម្រោះទឹកស្អាត |

ប្រភព៖ *សៀវភៅផែនអភិវឌ្ឍ៥ឆ្នាំ និងក្រុមប្រឹក្សាឃុំសាន់គ ឆ្នាំ២០១៨*

ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក៣៖ ផែនការប្រើប្រាស់ដីអនាគតឆ្នាំ២០១៧-២០៣២

## ៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ ២០៣២ នៅក្នុងឃុំសាន់គ នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋ ៤៤១០នាក់ ដែលត្រូវនឹងចំនួន ៨៦០ គ្រួសារ និងបច្ចុប្បន្នមានអ្នកគ្មានដីលំនៅឋានពិតប្រាកដចំនួន ៧៩ គ្រួសារ និងអ្នកគ្មានដីកសិកម្មពិតប្រាកដ ដែលត្រូវដោះស្រាយទៅអនាគតចំនួន ២៧៨ គ្រួសារ។ ដោយសារតែកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែមសម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសាន់គទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចអ្វីបានរកឃើញ នៅក្នុងជំពូក២ខាងលើនៃរបាយការណ៍នេះ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្ននៅក្នុងឃុំ ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដូច្នេះដើម្បីដោះស្រាយតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែបន្ថែមនោះ គឺជាដំណោះស្រាយ ត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្នមិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម៉្យាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ចំពោះដីស្រែវិញមិនត្រឹមតែមិនបានពង្រីកបន្ថែមទៅតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀត ប្រសិនបើដីស្រែប្រាំងនៅក្នុងតំបន់៣ ដែលជាដីការពារជុំវិញបឹងទន្លេសាបមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ។ ជាដំណោះស្រាយ គឺត្រូវតែគិតគូរពិចារណាដោយធ្វើការយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និង ពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីនៅក្នុងឃុំសាន់គ នៅតែរក្សាទំហំក្រឡាផ្ទៃសរុបចំនួន ២២ ២០៦ ហិកតា ហើយមានការប្រើប្រាស់សម្រាប់លំនៅឋាន(រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ) ដីទួលបុរាណ ដីព្រៃលិចទឹក ដីបឹង ដីអាងស្តុកទឹក និងដីស្រះដូចកាប្រើប្រាស់ដីបច្ចុប្បន្នដដែល ដោយគ្រាន់តែមានការប្រែប្រួលតិចតួចពីដីព្រៃគុម្ពោតមានដើមឈើដុះរាយប៉ាយមកជាដីស្រែវស្សា និងដីស្រែប្រាំងក្នុងតំបន់៣ ដែលជាដីការពារនៅជុំវិញបឹងទន្លេសាបទៅជាដីព្រៃលិចទឹកវិញ ប្រសិនបើមិនត្រូវបាន អនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ហើយទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចដែលមានរៀបរាប់នៅក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ ។ ជាទូទៅធនធានដីក្នុងឃុំសាន់គ មានសក្តានុពលខ្ពស់សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីនៅក្នុងឃុំនេះមានទីតាំងភូមិសាស្ត្រអំណោយ ផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចម្បង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំ

សក្តានុពលនៃដី ហើយក៏ជាការគាប់ជួនដែលមានភាពអំណោយផលពីធនធានដី នៅក្នុងឃុំសមស្របលើវិស័យកសិកម្មដំណាំស្រូវនេះ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាស ដ៏ល្អសម្រាប់អភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំមានការរីកចម្រើនបាន តាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវនៅលើផ្ទៃដីកសិកម្ម ដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូល ដើម្បីបង្កើនទិន្នផលស្រូវ ដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុក ដែលមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅ របស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា។

## ៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ដីពីមុនតាមរយៈការរក្សាជំហរច្បាស់លាស់ ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបដោយទៅប្រសិទ្ធិភាពជាមួយនឹងផលប៉ះពាល់តិចតួចបំផុតចំពោះមនុស្ស នៅជំនាន់ក្រោយ ឧទាហរណ៍ ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរឹលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលបានផ្តល់ប្រយោជន៍ច្រើនយ៉ាងទៅដល់សហគមន៍មូលដ្ឋាន តែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ជាចំណីអាហារដ៏សំខាន់សម្រាប់ជិវិតរស់នៅមិនអាចខ្វះបានទាំងនេះ ជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត នៅលើទីតាំងដីដដែល។

យ៉ាងណាមិញក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតដល់ឆ្នាំ២០៣២ ការប្រើប្រាស់ដីនៅក្នុងឃុំសាន់គត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហា និងឆ្លើយតបនឹងកំណើនប្រជាពលរដ្ឋ ដូចបានរៀបរាប់ខាងលើ ជាពិសេស គឺការដោះស្រាយក្នុងការបែងចែកការប្រើប្រាស់ដីធ្លី ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ។ បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញថា មានការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីពីដីព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ មានទំហំផ្ទៃដី ១៦ហិកតា ជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ហើយត្រូវបានទុកចោលទំនេរមានដុះព្រៃគុម្ពោតតូចៗ និងមានដើមឈើមួយៗដុះរាយប៉ាយ ដែលមានផលប្រយោជន៍តិចតួចឱ្យក្លាយទៅជាដីស្រែ ដែលនឹងមានផលប្រយោជន៍ច្រើនជាងមុនដើម្បីពង្រីកផ្ទៃដីស្រែ ដែលជាមូលដ្ឋានដ៏រឹងមាំនៃការអភិវឌ្ឍឃុំសាន់គ វានឹងនាំឱ្យមានការកើនឡើងផលិតផលស្រូវ ដែលនឹងនាំឱ្យមានប្រាក់ចំណូលប្រសើរឡើង ជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

តារាង 36៖ តារាងផែនការប្រើប្រាស់ដីនាពេលអនាគត

| ប្រភេទដីប្រើប្រាស់ | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **៣៧៩** | **៣៧៩** | **0** |
| -ដីលំនៅឋាន ភូមិ ក្រៅតំបន់ការពារ | ៤៦ | ៤៦ | 0 |
| -ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៣៣៣ | ៣៣៣ | 0 |
| **ខ.ដីស្រែវស្សា** | **៨៦៧៦** | **៨៦៩២** | **១៦** |
| -ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ៥០៧៨,២៨ | ៥០៩៤,២៨ | **១៦** |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៣៤៥៦ | ៣៤៥៦ | 0 |
| -ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២ | ១៤១,៧២ | ១៤១,៧២ | 0 |
| **គ.ដីស្រែប្រាំង** | **៩ ៤៩៨** | **៩ ៤៩៨** | **0** |
| -ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៣០៣១ | ៣០៣១ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៥៥៩៣ | ៥៥៩៣ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៨៧៤ | ៨៧៤ | **0** |
| **ឃ.ដីព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយ** | **១៦** | **0** | **-១៦** |
| **ង.ដីព្រៃលិចទឹក** | **១ ៦៨៣** | **១ ៦៨៣** | 0 |
| -ព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៩ | ៩ | 0 |
| -ព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ១៦៧៤ | ១៦៧៤ | 0 |
| **ច.បឹង** | **៥១២** | **៥១២** | **0** |
| **ឆ.អាងស្តុកទឹក** | **១ ៤០៧** | **១ ៤០៧** | **0** |
| -ដីអាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៤៩៧ | ៤៩៧ | 0 |
| -ដីអាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៩១០ | ៩១០ | 0 |
| **ជ.ស្រះ** | **៣៥** | **៣៥** | **0** |
| -ស្រះក្រៅតំបន់ការពារ | ៦ | ៦ | 0 |
| -ស្រះទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២៩ | ២៩ | 0 |
| **សរុប** | **២២ ២០៦** | **២២ ២០៦** | **0** |

តារាង 37៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (ម៉ែត្រ) | ប្រវែងផ្លូវ១៥ឆ្នាំក្រោយ (ម៉ែត្រ) | បម្រែបម្រួល (ម៉ែត្រ) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ១២, ៧២២ | ៣០, ៣៩៩ | ១៧, ៦៧៦ |
| ផ្លូវក្រាលគ្រួសក្រហម | ៤៦, ៧៥២ | ១១១, ៨០៣ | ៦៥, ០៥០ |
| ផ្លូវលំដីស/ផ្លូវរទេះ | ២២៥, ២០១ | ១៤២, ៤៧៤ | ៨២, ៧២៧ |
| ប្រឡាយមេ | ១៥៥២១,០២ | ១៥៥២១,០២ | 0 |
| ប្រឡាយរង | ២៣២៦៧,១៦ | ២៣២៦៧,១៦ | 0 |
| ប្រឡាយតូច | ៥៧៨០៦,២៣ | ៦៣៥៧១,៣៦ | ៥៧៦៥,១៣ |

តារាង 38៖ តារាងផែនការផ្តែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមតេយ្យ | ២ | ១៣ | ១១ |
| សាលាបឋមសិក្សា | ១០ | ១២ | ០២ |
| សាលាអនុវិទ្យាល័យ | ០២ | ០៨ | ០៦ |
| សាលាវិទ្យាល័យ | 0.0 | ០៥ | ០៥ |
| មណ្ឌលសុខភាព | ០១ | ០១ | 0.0 |
| ទីចាក់សំរាម | 0.0 | 0.0 | 0.0 |
| ទីតាំងផ្សារ | 0.0 | 0.0 | 0.0 |
| សាលាឆទាន | ០៤ | ០៤ | 0.0 |
| វត្ត | ០៥ | ០៥ | 0.0 |

### ៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដី នាពេលអនាគតនៅក្នុងឃុំសាន់គ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយធ្វើការពឹងផ្អែកទាំងស្រុងទៅលើការវិភាគដី ដ៏សមស្របមួយ តាមរយៈការវាយតម្លៃបែបសាមញ្ញ ទៅលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដីធ្លី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ធ្វើជាមូលដ្ឋាន សម្រាប់នៅក្នុងការគិតគូរពិចារណា ដូចមានរំលេចឱ្យឃើញ នៅក្នុងតារាងប្រើប្រាស់ដីពេលអនាគតខាងលើនេះ ព្រមទាំងនៅក្នុងផែនទីប្រើប្រាស់ដីនាពេលអនាគតដូចខាងក្រោមនេះ ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាពតាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗ ដែលបានកំណត់នៅលើផែនទីនេះផងដែរ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតឃុំសាន់គ



### ៣.២.៣.សេចក្ដីអត្ថាធិប្បាយ

ផ្អែកទៅតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ដូចខាងក្រោម៖

#### ក.ដីលំនៅឋានភូមិ

ដីលំនៅឋាន ភូមិ គឺជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ ។ នៅក្នុងឃុំសាន់គ ដីលំនៅឋានភូមិ មានផ្ទៃដីសរុបទំហំ ៣៧៩ ហិកតា ដែលភាគច្រើនស្ថិតនៅសងខាងតាមបណ្ដោយផ្លូវជាតិលេខ៦ ក្នុងនោះមានមួយផ្នែកនៅខាងជើងជាប់ផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៤៦ ហិកតា និងមួយផ្នែកទៀតនៅខាងត្បូងជាប់ផ្លូវជាតិលេខ៦ដែរ ជាដីលំនៅឋាន ភូមិ ស្ថិតក្នុងតំបន់១ មានទំហំផ្ទៃដីចំនួន ៣៣៣ ហិកតា ។ ដីលំនៅឋាន ភូមិដែលស្ថិតនៅជាប់សងខាងផ្លូវជាតិលេខ៦មានចំនួន ០៩ភូមិ គឺភូមិបាឡាំង ភូមិតាំងក្រូច ភូមិសារី ភូមិសំពៅមាស ភូមិក្បិលភូមិសាន់គ ក ភូមិសាន់គ ខ ភូមិក្រសាំង ក និងភូមិក្រសាំង ខ ចំណែកដីលំនៅឋាន ដែលស្ថិតនៅខាងត្បូងចូលក្នុងឃ្លាតពីផ្លូវជាតិលេខ៦ចូលតាមដងផ្លូវឃុំមួយខ្សែមានចំនួន ០៣ភូមិ គឺភូមិស្លែងខ្ពស់ ភូមិវាល និងភូមិប្រាសាទ ព្រមទាំងមួយផ្នែកទៀត ស្ថិតនៅប៉ែកខាងកើតដាច់ពីគេមានមួយភូមិអំពិល។ ដីលំនៅឋាន ភូមិទាំងអស់ជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក មានប្រភេទក្រុមដីប្រទះឡាង និងដីបាកាន (ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ) ពណ៌ត្នោត ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ ដែលបច្ចុប្បន្នដីនេះត្រូវបានប្រើប្រាស់ សម្រាប់ដីលំនៅឋានភូមិ ដោយពុំមានការពង្រីកបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៣២ នោះឡើយ ដោយបច្ចុប្បន្នដីលំនៅឋានភូមិ នៅមានភាពទូលាយ ដែលត្រូវបានប្រើប្រាស់ទំហំដីចំនួន ០,១០ ហិកតា ក្នុងមួយគ្រួសារ ដែលអាចធ្វើការដោះស្រាយ សម្រាប់សាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ដោយនឹងត្រូវប្រើប្រាស់ទំហំដីថយចុះតិចតួចនៅសល់ប្រមាណ ០,០៨ហិកតា នៅក្នុងមួយគ្រួសារ ។ ដីដែលបានកំណត់ជាដីភូមិនេះ ពឹងផ្អែកទៅលើប្រភពទឹក សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋានបានមកពីអណ្ដូងស្នប់ ត្រពាំង ស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគតទីតាំងដីលំនៅឋានភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដី ខ្ពស់មិនលិចទឹកនៅរដូវវស្សានៅជាប់ផ្លូវជាតិលេខ៦ និងផ្លូវសំខាន់ៗនៅក្នុងឃុំ ងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋសមស្របសម្រាប់ការតាំងលំនៅឋាន ដែលជាជម្រកដ៏កក់ក្ដៅសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

#### ខ.ដីស្រែវស្សា

នៅក្នុងឃុំសាន់គដីស្រែវស្សាមានភាគច្រើនស្ថិតនៅប៉ែកខាងជើងជាប់ផ្លូវជាតិលេខ៦រហូតដល់ព្រំប្រទល់ឃុំភាគខាងជើង ដែលបច្ចុប្បន្ននេះ ត្រូវបាននឹងកំពុងប្រើប្រាស់ជាដីស្រែវស្សាមានទំហំផ្ទៃដី ៨ ៦៧៦ ហិកតា និងដីព្រៃគុម្ពោត និងដើមឈើដុះរាយប៉ាយទំហំ ១៦ ហិកតា ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ដែលមានទំហំផ្ទៃដីសរុបចំនួន ៨ ៦៩២ ហិកតា និងមានមួយភាគទៀតជាចំនួនតិចជាងស្ថិតនៅប៉ែកខាងត្បូងជាប់ផ្លូវជាតិចូលក្នុងប្រមាណ ២,៥គីឡូម៉ែត្រ ជាដីស្រែវស្សាស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដី ៣៤៥៦ហិកតា ដែលបច្ចុប្បន្នត្រូវបាននឹងកំពុងប្រើប្រាស់ជាដីស្រែវស្សា។ ដីដែលបានកំណត់ជាដីស្រែវស្សាទាំងអស់ខាងលើនេះជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក មានប្រភេទក្រុមដីប្រទះឡាង ក្រុមដីបាកាន (ខ្សាច់+ឥដ្ឋ=ខ្សាច់ល្បាយ)

ពណ៌ត្នោត ដែលជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ប្រើប្រាស់ដោយប្រជាពលរដ្ឋ ។ ដីស្រែវស្សាទាំងអស់នេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ការស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០ កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោង ស្ថិតនៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺប្រឡាយ ៣០ កញ្ញា ព្រមទាំងអាងស្តុកទឹកដែលមាននៅក្នុងឃុំ បឹងធម្មជាតិ និងស្រះ ហើយដីស្រែវស្សាដែលនៅក្បែរលំនៅឋាន ភូមិ ក៏អាចដាំដំណាំរួមផ្សំផងដែរ ដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខផ្សេងៗទៀត ជាដើមក្រោយពីច្រូតកាត់ស្រូវរួច។ នាពេលអនាគតទីតាំងដីទាំងនេះ នឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សាសមស្រប សម្រាប់ដំណាំស្រូវដើម្បីផ្គត់ផ្គង់ការហូបចុករបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។

**- ដីស្រែវស្សាក្នុងគម្របព្រៃឈើឆ្នាំ២០០២**

នៅក្នុងឃុំសាន់គ មានដីស្រែវស្សាក្នុងគម្របព្រៃឆ្នាំ ២០០២ ទំហំផ្ទៃដីសរុបចំនួន ១៤១,៧២ ហិកតា ដែលមាន ០៣កន្លែង ស្ថិតនៅភាគខាងជើងឃុំជាប់ព្រំប្រទល់ឃុំដំរីស្លាប់ ។ ដីស្រែវស្សាក្នុងគម្របព្រៃឆ្នាំ ២០០២ ជាតំបន់ទំនាបខ្ពស់ និងមធ្យម មានប្រភេទដីខ្សាច់សុទ្ធពណ៌ស និងដីខ្សាច់លាយពណ៌ប្រផេះ គឺជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្នត្រូវបាននឹងកំពុងប្រើប្រាស់ដោយប្រជាពលរដ្ឋជាដីស្រែវស្សា ដែលមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០ កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោង។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីស្រែវស្សាដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីទាំងនេះមានស្ថានភាពជាដីទាបលិចទឹកនៅក្នុងរដូវវស្សាសមស្របសម្រាប់ដំណាំស្រូវ ដែលផ្តល់ផលផ្គត់ផ្គង់ការហូបចុក សម្រាប់ជីវិតរស់នៅរបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ប៉ុន្តែនាពេលអនាគត ដីនេះនឹងត្រូវរក្សាទុកជាដីរបស់រដ្ឋដែលជាគម្របព្រៃឈើវិញ ប្រសិនបើមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យប្រជាពលរដ្ឋមានសិទ្ធិកាន់កាប់ប្រើប្រាស់តាមរយៈការស្នើសុំពីអាជ្ញាធរដែនដីទេនោះ។

### គ.ដីស្រែប្រាំង

នាពេលអនាគតដីស្រែប្រាំងក្នុងឃុំសាន់គ មានផ្ទៃដីទំហំ ៩ ៤៩៨ ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំដែលបច្ចុប្បន្ននេះ ក៏បាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំងដែរ ហើយស្ថិតនៅក្នុង ០៣ តំបន់ការពារជុំវិញបឹងទន្លេសាបផ្សេងគ្នា គឺតំបន់១ តំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**- ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់១ ស្ថិតនៅប៉ែកកណ្តាលនៃឃុំ ដោយចាប់គិតពីផ្លូវជាតិលេខ៦ ប្រវែងប្រមាណជា ២,៥គីឡូម៉ែត្រឆ្ពោះទៅទិសខាងត្បូងនៃឃុំរហូតដល់ប្រមាណ ០៣ គីឡូម៉ែត្រ មានផ្ទៃដីទំហំ ៣ ០៣១ ហិកតា ជាតំបន់រាបស្មើជម្រាលទាប ដែលមានប្រភេទក្រុមដីគោកគ្រប់(កណ្តេងខ្លះល្បាយខ្សាច់) ប្រផេះស្រាលនិងក្រុមដីក្រគរ និងជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ។ ដីដែលបានកំណត់ធ្វើជាដីស្រែប្រាំងក្នុងតំបន់១នេះ ពឹងផ្អែកទៅលើប្រភពទឹកសម្រាប់ការស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០ កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោង ស្ថិតនៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺជាប្រឡាយ ៣០កញ្ញា ព្រមទាំងអាងស្តុកទឹក បឹងធម្មជាតិ និងស្រះទឹក។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារតែទីតាំងដីទាំងនេះ មានស្ថានភាពជាដីទាបលិចទឹកខ្លាំងនៅរដូវវស្សាមិនអាចធ្វើស្រែវស្សាបានសមស្រប សម្រាប់ដំណាំស្រូវប្រាំងនៅពេលទឹកស្រកចុះវិញ សម្រាប់

ផ្គត់ផ្គង់ការហូបចុកសម្រាប់ ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុង និងក្រៅប្រទេសបានចំណូល បង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។

**- ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ ស្ថិតនៅភាគខាងត្បូងនៃឃុំបន្តជាប់ពីដីស្រែប្រាំងក្នុងតំបន់១ មានទំហំផ្ទៃដីចំនួន ៥ ៥៩៣ហិកតា គឺជាតំបន់ទំនាបរាបស្មើ មានប្រភេទក្រុមដីក្រគរ ក្រុមដីក្បាលពោ (ដីកណ្តោង ពណ៌ខ្មៅប្រផេះ) ដីល្បាប់ចាស់ និងជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងបានឡើយ។ ដីដែលបានកំណត់ជាដីស្រែប្រាំងក្នុងតំបន់២នេះពឹងផ្អែកទៅលើប្រភពទឹក សម្រាប់ការស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោង ស្ថិតនៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺប្រឡាយ ៣០ កញ្ញា ព្រមទាំងអាងស្តុកទឹក បឹងធម្មជាតិ និងស្រះដែលមានក្នុងឃុំ ។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំងក្នុងរដូវវស្សាមិនអាចធ្វើស្រែវស្សាបាន សមស្របសម្រាប់ដំណាំស្រូវប្រាំងពេលដែលទឹកស្រកចុះវិញ ដើម្បីបានផលិតផលស្រូវផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់នៅរបស់មនុស្សនិងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់កាពារព្រៃលិចទឹក នៅភាគចុងខាងត្បូងនៃឃុំមានទំហំផ្ទៃដីចំនួន ៨៧៤ ហិកតា ។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបព្រៃលិចទឹកដែលមានប្រភេទក្រុមដីក្បាលពោ (កណ្តោងសុទ្ធពណ៌ខ្មៅប្រផេះ) ដីកណ្តោងពពាយកណ្តុរ និងដីល្បាប់ចាស់ និងជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់គ្រប់ប្រភេទ ។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក ៣០ កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោង ស្ថិតក្នុងស្រុកស្ទោង ដែលបាននាំទឹកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែ គឺប្រឡាយ ៣០កញ្ញា។ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំង នៅរដូវវស្សាមិនអាចធ្វើស្រែវស្សាបាន សមស្របសម្រាប់ដំណាំស្រូវប្រាំងនៅពេលទឹកស្រកចុះវិញ ដើម្បីបានផលិតផលស្រូវផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ នាពេលអនាគតក្នុងករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងឃុំសាន់គមែននោះ ត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្តល់ដីស្រែក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ញានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើពិតជាមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្វៀលដីទាំងនេះជូនមែន ក៏ដីនេះ មិនមែនជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ ដោយពួកគាត់គ្រាន់តែមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ប៉ុន្តែប្រសិនបើមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋមានសិទ្ធិអាស្រ័យផលទេនោះ ដីស្រែប្រាំងទាំងនេះនឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកឡើងវិញ។

ង.ដីព្រៃលិចទឹក

នាពេលអនាគត ដីព្រៃលិចទឹកនៅក្នុងឃុំសាន់គមានផ្ទៃដីទំហំ ១ ៦៨៣ ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលបច្ចុប្បន្ននេះក៏ជាព្រៃលិចទឹកដែរ ហើយស្ថិតនៅក្នុង ០២ តំបន់ការពារជុំវិញបឹងទន្លេសាបផ្សេងគ្នា គឺតំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោមៈ

**- ដីព្រៃលិចទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីព្រៃលិចទឹកនៅក្នុងតំបន់២ គឺជាដីដែលត្រូវបានរាជរដ្ឋាភិបាល កំណត់ឱ្យប្រជាពលរដ្ឋជួយថែរក្សាទុក ដែលមានសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នា មានដូចជា ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្នាច់ និងដើមរាំងជាដើម ។ ព្រៃលិចទឹកក្នុងតំបន់២ មានផ្ទៃដីទំហំ ០៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋដែលត្រូវការពារ ស្ថិតនៅលើទីតាំងដីភាគខាងត្បូងនៃឃុំ មានស្ថានភាពដីទាបលិចទឹកជម្រាលរាបស្មើ ជាប្រភេទក្រុមដីក្បាលពោ ដីកណ្តោង ពពាយកណ្ដុរ និងដីល្បាប់ចាស់។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកក្នុងតំបន់២ដដែល ដើម្បីការពារ និងថែរក្សាទុកធ្វើឱ្យមានលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងប្រព័ន្ធជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធស្របទៅតាមការកំណត់របស់រាជរដ្ឋាភិបាលជាដីត្រូវការពារ ដែលប្រជាពលរដ្ឋក្នុងឃុំកំពុងអាស្រ័យផលលើដីក្នុងតំបន់២នេះ ត្រូវយកចិត្តទុកដាក់ថែរក្សាព្រៃលិចទឹកទាំងនេះ ដោយមិនត្រូវកាប់បំផ្លាញរានយកដីពង្រីកផ្ទៃដីស្រែថែមទៀតនោះឡើយ។

**- ដីព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ព្រៃលិចទឹកនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប គឺជាដីបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីព្រៃលិចទឹក មានទំហំផ្ទៃដីចំនួន ១ ៦៧៤ហិកតា រួមជាមួយដីស្រែប្រាំងមានទំហំផ្ទៃដីចំនួន ៨៧៤ហិកតា ដែលត្រូវបានរាជរដ្ឋាភិបាលកំណត់ជាដែនព្រៃលិចទឹកជុំវិញបឹងទន្លេសាបត្រូវការពារដាច់ខាត។ ដីព្រៃលិចទឹកក្នុងតំបន់៣នេះសម្បូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នា មានដូចជា ដើមភ្នំភ្លើង ត្រស់ កប្បាសព្រៃ ស្នាច់ ដើមរាំងជាដើម និងមានទំហំផ្ទៃដីសរុប ២ ៥៤៨ ហិកតា ជាដីសាធារណៈរបស់រដ្ឋ ដែលទទួលខុសត្រូវលើការគ្រប់គ្រង ការការពារ និងការថែរក្សាដោយអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងមានរដ្ឋបាលជលផល ជាអ្នកធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សា ការពារ និងចាត់វិធានការទោតាមច្បាប់ក្នុងករណីពិនិត្យឃើញមានសកម្មភាពដែលនាំឱ្យប៉ះពាល់ទៅដល់ព្រៃលិចទឹក។ ដីព្រៃលិចទឹកក្នុងតំបន់៣ ស្ថិតនៅលើទីតាំងដីចុងភាគខាងត្បូងនៃឃុំ មានស្ថានភាពដីទាបលិចទឹកជម្រាលរាបស្មើ ជាប្រភេទក្រុមដីក្បាលពោ ដីកណ្តោង ដីពពាយកណ្ដុរ និងដីល្បាប់ចាស់។ នាពេលអនាគតទីតាំងនេះនឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកក្នុងតំបន់៣ដដែល ដើម្បីធ្វើការការពារនិងថែរក្សាទុកធ្វើឱ្យមានលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃដីល្បាប់ ប្រព័ន្ធជីវចម្រុះបឹងនៃទន្លេសាប និងតំបន់ពាក់ព័ន្ធស្របទៅតាមការកំណត់របស់រាជរដ្ឋាភិបាល ជាដីត្រូវការពារដាច់ខាត ។ ដីព្រៃលិចទឹកក្នុងតំបន់៣ទាំងនេះ ហាមដាច់ខាតក្នុងកាប់បំផ្លាញរានយកដីធ្វើស្រែ យកឈើធ្វើសំរាស់ និងឧសដុត និងដុតព្រៃយកសត្វព្រៃជាដើម។

ច.ដីបឹង

ដីបឹងបច្ចុប្បន្ន ជាដីបឹងធម្មជាតិ មានចំនួន ០៧ កន្លែង ដូចជា បឹងរៀល បឹងប្រទេះជៀល បឹងស្តង់ បឹងស្មៅ បឹងចក បឹងត្រពាំងអង្រង បឹងឈូកវ៉ាន់ ដែលមានផ្ទៃដីសរុបទំហំ ៥១២ ហិកតា នៅក្នុងនោះមានបឹង ០១ កន្លែង ទំហំផ្ទៃដីចំនួន ០២ ហិកតា ស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប បឹង ០២ កន្លែង មានផ្ទៃដីទំហំ ៩១ ហិកតា ស្ថិតក្នុងតំបន់២ជុំវិញបឹងទន្លេសាប និងមានបឹង ០៤ កន្លែង ទៀត ទំហំផ្ទៃដីចំនួន ៤១៩ ហិកតា ស្ថិតនៅក្នុងតំបន់៣ជុំវិញ

បឹងទន្លេសាប ។ បឹងធម្មជាតិទាំងនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលនៅពេលអនាគតត្រូវការពារ និងថែរក្សាទុកប្រើប្រាស់ សម្រាប់ជាប្រភពទឹកស្រោចស្រពដំណាំកសិកម្ម និងការប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

ឆ.ដីអាងស្តុកទឹក

នាពេលអនាគត ដីអាងស្តុកទឹកនៅក្នុងឃុំសាន់គ មានទំហំផ្ទៃដីសរុបចំនួន ១ ៤០៧ ហិកតា ស្ថិតនៅភាគខាងត្បូងឃុំ ដែលបច្ចុប្បន្នក៏ជាអាងស្តុកទឹកដែរ ហើយស្ថិតនៅក្នុង ០២ តំបន់ការពារជុំវិញបឹងទន្លេសាបផ្សេងគ្នាគឺតំបន់១ និងតំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

**- ដីអាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប បច្ចុប្បន្ននេះមានចំនួន ០៤កន្លែង ត្រូវបានប្រើប្រាស់សម្រាប់បម្រើឱ្យការស្រោចស្រពដីស្រែប្រាំង និងប្រើប្រាស់ទៅតាមការចាំបាច់ផ្សេងៗទៀត ដែលមានទំហំ ៤៩៧ ហិកតា ស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់ចាត់ចែងដោយប្រជាពលរដ្ឋ។ នាពេលអនាគតអាងស្តុកទឹកនេះ នឹងនៅតែប្រើប្រាស់ជាអាងស្តុកទឹកទុក ជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់អាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ នៅក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

**- អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបពេលបច្ចុប្បន្ននេះមានចំនួន៣កន្លែង ដែលត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពលើដីស្រែប្រាំងនិងប្រើប្រាស់តាមការចាំបាច់ផ្សេងៗទៀត។ អាងស្តុកទឹកក្នុងតំបន់២នេះមានផ្ទៃដី ៩១០ហិកតា ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងឡើយ។ នាពេលអនាគតអាងស្តុកទឹកនេះ នឹងនៅតែប្រើប្រាស់ជាអាងស្តុកទឹកទុកជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

ជ.ស្រះទឹក

នៅក្នុងឃុំសាន់គ មានស្រះទឹកសរុបចំនួន ៦០ កន្លែង ទំហំផ្ទៃដីសរុបចំនួន ៣៥ ហិកតា ក្នុងនោះមានចំនួន ០៨ កន្លែង មានទំហំផ្ទៃដីចំនួន ០៦ ហិកតា ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ដែលភាគច្រើនស្ថិតនៅក្នុងតំបន់ស្រែវស្សាក្បែរតំបន់លំនៅឋានភូមិតាមបណ្តោយផ្លូវជាតិលេខ៦ប៉ែកខាងជើង និងមានស្រះទឹក ៥២ កន្លែង ទំហំផ្ទៃដីចំនួន ២៩ហិកតា ស្ថិតនៅក្នុងតំបន់១ ដែលភាគច្រើនស្ថិតនៅក្នុងតំបន់ស្រែវស្សា ក្បែរតំបន់លំនៅឋានភូមិតាមបណ្តោយផ្លូវជាតិលេខ៦ ប៉ែកខាងត្បូង។ ដីស្រះទឹកទាំងអស់នៅក្នុងឃុំសាន់គ គឺជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់និងចាត់ចែងដោយប្រជាពលរដ្ឋ លើកលែងតែដីស្រះអំពិលមួយប៉ុណ្ណោះ ដែលជាដីស្រះសហគមន៍ស្ថិតនៅក្នុងតំបន់១។ នាពេលអនាគតស្រះទាំងនេះ នឹងនៅតែប្រើប្រាស់ជាស្រះទឹក ទុកជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្គត់ផ្គង់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

## ៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិតបច្ចុប្បន្ន យើងបានរកឃើញថានៅក្នុងឃុំសាន់គមានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន ៨៦គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ២៧៨គ្រួសារ ដូចបានរកឃើញក្នុងជំពូកទី១នៃរបាយការណ៍នេះ បច្ចុប្បន្នពួកគាត់មួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ លើដីចំណីប្រឡាយ និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃដែលពួកគាត់ត្រូវស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត។ ដូច្នេះដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនទៅពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ត្រូវខិតខំដោះស្រាយតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច នៅថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំសាន់គ។ ដីធ្លីដែលត្រូវដោះស្រាយជូនទៅពួកគាត់ ដូចបាន ធ្វើការវិភាគដោះស្រាយក្នុងជំពូកទី២ ត្រង់ចំណុច ២.១.៣ខាងលើ គឺដីសម្រាប់លំនៅឋាន ដែលមានទំហំ១៦,២៥ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ ៥៥៦ ហិកតា។

## ៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីធ្លីទាំងនោះ ហើយការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូតដោយពុំមានឈប់ឈរ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់នេះ តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាឱ្យមាននិរន្តរភាព។

### ៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយចីរភាពដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ និងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រង លើការប្រើប្រាស់ដីទាំងអស់នៅក្នុងឃុំ ដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

#### ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមានក្នុងឃុំសាន់គ ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ ហើយបានកំណត់ច្បាស់ថាឃុំមានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគត ពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ។ ដូចនេះឃុំសាន់គ នឹងមានតួនាទីសំខាន់ក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវតែចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មក្នុងឃុំឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលឱ្យបានខ្ពស់អស់សក្តានុពល ដែលអាចមានលទ្ធភាពនាំស្រូវចេញបានច្រើន ដែលសល់ពីការហូបចុក ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជពលរដ្ឋ។

ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍឃុំដូចខាងលើ ត្រូវមានការគ្រប់គ្រងដីស្រែក្នុងឃុំឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តប្តូរមុខងារប្រើប្រាស់ដីពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងការប្រើប្រាស់ផ្សេងទៀត ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋនិងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាព និងអនុលោមតាមច្បាប់

លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងត្រូវមានការផ្សព្វផ្សាយជាចំហ។ ម្យ៉ាងទៀតដីស្រែប្រាំងនៅក្នុងឃុំសាន់គ បច្ចុប្បន្ន បានរកឃើញថា មានទំហំផ្ទៃដីចំនួន ៨៧៤ ហិកតា ស្ថិតនៅក្នុងតំបន់៣ ដែលជាដែនការពារព្រៃលិចទឹក ប្រសិនបើមិនមានការអនុញ្ញាតពីរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋបន្តកាន់កាប់អាស្រ័យផលនៅពេលអនាគត តាមរយៈការស្នើសុំពីអាជ្ញធរដែនដីទេនោះ នឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកវិញ នឹងនាំឱ្យទំហំផ្ទៃដីស្រែប្រាំងមានការថយចុះ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែក៏ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំតាមរយៈការស្តារប្រព័ន្ធប្រឡាយចាស់ៗ ដែលមានស្រាប់អាចនាំទឹកស្រោចស្រពដីស្រែបានគ្រប់គ្រាន់ដើម្បីអាចផ្តល់ទឹកនៅតាមប្រព័ន្ធប្រឡាយទាំងនោះផងដែរ។ បន្ទាប់ពីកត្តាដី និងទឹក ក៏នៅមានកត្តាបច្ចេកទេសជាដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើប ដូចមានលើកឡើងតាមការវិភាគក្នុងជំពូក២ត្រង់ចំណុចការផ្តល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះ នឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងតែគិតថាការធ្វើស្រែនាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតទៅការធ្វើស្រែតាមបែបប្រពលវប្បកម្មទំនើប កសិករក៏អាចពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្ម នៅឃុំសាន់គមិនមែនយកចិត្តទុកដាក់តែលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារ ក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែបានផលស្រូវមានគុណភាពតាមស្តង់ដាតម្រូវការទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១២.៣. អាចឱ្យយើងរំពឹងទុកអំពីបរិមាណស្រូវនាំចេញនាពេលអនាគតនៅក្នុងអំឡុងពេល ១៥ឆ្នាំខាងមុខ ដូចខាងក្រោម ប្រសិនបើមិនមានការប្រែប្រួលថយចុះដីស្រែប្រាំងនៅក្នុងតំបន់៣ទេនោះ។

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ២៣ ៣៨១ នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែវស្សាមាន ៨ ៦៩២ ហិកតា និងស្រែប្រាំង ៩ ៤៩៨ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវវស្សាជាមធ្យមចំនួន៤តោន/ហ.ត និងស្រូវប្រាំងចំនួន ៥ តោន/ហ.ត

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែវស្សាបាន ១ដង/ឆ្នាំ និងស្រូវប្រាំងបាន ២ដង/ឆ្នាំ

**-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ(២០១៧-២០៣២)ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យមៈ**

-ស្រូវវស្សាស្មើនឹង ៨ ៦៩២ ហិកតា x ៤ តោន/ហិកតា x ១ ដង = ៣៤ ៧៦៨ តោន/ឆ្នាំ

-ស្រូវប្រាំងស្មើនឹង ៩ ៤៩៨ ហិកតា x ៥ តោន/ហិកតា x ២ ដង = ៩៤ ៩៨០ តោន/ឆ្នាំ

-ទិន្នផលស្រូវសរុបស្មើរនឹង ៣៤ ៧៦៨ តោន + ៩៤ ៩៨០ តោន = ១២៩៧៤៨ តោន/ឆ្នាំ

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣ គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន ២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម

២ ៣៣៨១ នាក់ x ២២៤ គីឡូក្រាម = ៥ ២៣៧ ៣៤៤ គីឡូក្រាម/ឆ្នាំ ស្មើនឹង ៥ ២៣៧ តោន/ឆ្នាំ

**-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម ៖**

-ស្រូវវស្សាស្មើនឹង ៨ ៦៩២ ហិកតា x ៣០០ គីឡូក្រាម = ២ ៦០៨ តោន/ឆ្នាំ

-ស្រូវប្រាំងស្មើនឹង ៩ ៤៩៨ ហិកតា x ៣០០ គីឡូក្រាម = ២ ៨៤៨ តោន/ឆ្នាំ

-ពូជស្រូវសរុបស្មើរនឹង ២ ៦០៨ តោន + ២ ៨៤៨ តោន = ៥ ៦៩៦ តោន/ឆ្នាំ

-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យម

១២៩៧៤៨ តោន/ឆ្នាំ - ៥ ២៣៧ តោន/ឆ្នាំ - ៥ ៦៩៦ តោន/ឆ្នាំ = ១១៨ ៨១៥ តោន/ឆ្នាំ

**-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ**

**១១៨ ៨១៥ តោន/ឆ្នាំ x ៦០ % = ៧១២៨៩ តោន/ឆ្នាំ**

ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

ដោយឡែកធនធានព្រៃឈើវិញ យើងបានរកឃើញថា នៅក្នុងឃុំសាន់គមានព្រៃគុម្ពោតដុះលាយដើមឈើធំមួយៗរាយប៉ាយនៅលើដីទួលតាមវាលស្រែតិចតួច គឺជាដីកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលនឹងប្រែក្លាយជាដីស្រែនាពេលអនាគត។ តែទោះបីនៅពេលអនាគតមិនមានវត្តមានដីព្រៃគុម្ពោតទៀតនោះ ក៏ក្នុងឃុំសាន់គនៅមានទួលបុរាណដ្ឋានចំនួន ០៩កន្លែង ដែលត្រូវបានរក្សាទុកសម្រាប់ការដាំកូនឈើ រួមទាំងដីនៅតាមដងផ្លូវតាមប្រឡាយទឹក ទីធ្លាសាលាឃុំ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លាវត្តអារាម និងនៅតាមលំនៅឋានជាដើម ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំ ដើម្បីបម្រើផលប្រយោជន៍ដូចដែលបានលើកឡើងក្នុងជំពូកទី២នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ។

ទោះបីក្នុងឃុំសាន់គ មិនមានធនធានព្រៃឈើធម្មជាតិច្រើនក៏ដោយ ក៏ប៉ុន្តែនៅក្នុងឃុំសម្បូរទៅដោយព្រៃលិចទឹក ជាធនធានជលផលដ៏កម្រ ដែលរាជរដ្ឋាភិបាលបានកំណត់ជាដីការពារជុំវិញបឹងទន្លេសាប ដោយហាមដាច់ខាតការរំលោភដីព្រៃលិចទឹកទាំងអស់នេះ ដើម្បីរក្សាលំនឹងធម្មជាតិ ដែលជាជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ និងប្រព័ន្ធជីវចម្រុះនៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ ចំណែកមច្ឆាជាតិដែលជាធនធានជលផលនៅក្នុងឃុំដែរនោះ បច្ចុប្បន្ននេះមានតែតាមបែបធម្មជាតិនៅតាមបឹងអាងស្តុកទឹក ស្រះប្រឡាយទឹក និងក្នុងស្រែ ដែលអាចឱ្យប្រជាពលរដ្ឋនៅក្នុងឃុំអាចទទួលផលជាលក្ខណៈគ្រួសារបានតិចតួចតែប៉ុណ្ណោះ។ តែទៅថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់នៅក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងឃុំសាន់គ។ ហើយចំពោះស្ថានភាពសមស្របក្នុងឃុំគួរតែចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីនៅក្នុងស្រែ ដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម(តាមវាលស្រែ) ហើយមានប្រយោជន៍នៅក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំដូចបានលើកឡើងជាអនុសាសន៍នៅក្នុងជំពូក២នៃរបាយការណ៍នេះផងដែរ។ ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញគួរកត់សម្គាល់ឡើយ។

៣.៨.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយគ្រប់គ្រាន់ធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗសម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍ អភិរក្សដីធ្លីនិងធនធានធម្មជាតិនៅក្នុងឃុំសាន់គ ចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោមៈ

- កសាងប្រកផ្លូវបេតុង
- ជួសជុលផ្លូវលំគ្រួសក្រហម/ខ្សាច់ភ្នំ
- គម្រោងសាងសង់លូកាត់ផ្លូវ

- គម្រោងសាងសង់ផ្លូវលំដីស
- ស្តារប្រឡាយស្រោចស្រព
- ធ្វើអាងស្តុកទឹក
- ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក
- ផ្តល់ម៉ាស៊ីនបូមទឹក
- ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្រ្ត
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្រ្តីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្រ្តី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្រ្តីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល ច្បាប់ជលផលជូនដល់ប្រជាពលរដ្ឋ

## ៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ នៅក្នុងឆ្នាំ២០១៧នេះ បានឱ្យដឹងថាឃុំសាន់គ ជាឃុំមួយនៅក្នុងចំណោមឃុំ ១១ របស់ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានភូមិចំនួន១២ និងមានទំហំផ្ទៃដីសរុបចំនួន ២២ ២២០,៤៤ហិកតា។ ក្នុងឆ្នាំ២០១៧ ឃុំសាន់គ មានគ្រួសារសរុបចំនួន ៣ ៦៩៩គ្រួសារ ប្រជាជនសរុបចំនួន ១៨ ៩៧១នាក់ ក្នុងនោះស្រ្តី ៩ ៦៧៨នាក់ ហើយមានដង់ស៊ីតេប្រជាជនមធ្យម ៨៣នាក់/គ.ម២។ ឃុំសាន់គ មានសណ្ឋានភាពដី ជាវាលទំនាបលិចទឹកនៅក្នុងរដូវវស្សាជាប្រភេទដីប្រទះឡាន ដីបាកាន (ខ្សាច់ជាមួយឥដ្ឋខ្សាច់ល្បាយ) ពណ៌ត្នោត ក្រគរ គោកត្រប់ (កណ្តោងខ្លះ ល្បាយខ្សាច់) ប្រផះស្រាល ក្រុមដីក្បាលពោ (កណ្តោងសុទ្ធ ពណ៌ខ្មៅប្រផះ) និងក្រុមដីក្រគរ ត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង និងស្រែវស្សា ដែលបានផ្តល់នូវមុខរបរយ៉ាងសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៨២,១ភាគរយ សេវាកម្ម ១៧,៨ភាគរយ និងសិប្បកម្មមានចំនួន ០,១ភាគរយ ។ ទន្ទឹមនេះឃុំសាន់គ មានប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពរស់នៅពី១)ទឹកភ្លៀង ២)បឹង ៣)អាងស្តុក និង៥)ស្រះ ដែលអាចនាំទឹកមកប្រើប្រាស់តាមរយៈប្រឡាយមេចំនួន ០២ខ្សែ ប្រឡាយរង ៦ខ្សែ និងប្រឡាយតូចៗ ២៣ខ្សែ។ បន្ថែមពីលើនេះ ឃុំសាន់គ មានផ្លូវជាលេខ៦ ឆ្លងកាត់ ដែលមានទិសដៅពីភ្នំពេញទៅកាន់សៀមរាប ជាការផ្តល់ឱកាសឱ្យឃុំសាន់គ អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍនៅតាមផ្លូវនេះបាន ហើយឃុំនៅមានផ្លូវផ្សេងៗទៀតគ្រប់គ្រាន់ ដែលអាចភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយនៅក្នុងឃុំ និងអាចភ្ជាប់ទំនាក់ទំនងទៅឃុំ និងស្រុកផ្សេង រួមទាំងទីរួមខេត្តកំពង់ធំបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា នៅក្នុងរយៈពេល១៥ឆ្នាំខាងមុខ

រហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតទៅដល់ ២៣ ៣៨១ នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន។ ទន្ទឹមនឹងនេះក៏បានរកឃើញពីបញ្ហាប្រឈមមួយចំនួនលើសកម្មភាពនៃការអភិវឌ្ឍឃុំសាន់គបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែដែលមានសក្តានុពលនៅក្នុងការអភិវឌ្ឍឃុំ ដោយមិនទាន់ទទួលបានទិន្នផលស្រូវ សមស្របអស់លទ្ធភាពនៅឡើយ ដោយសារតែដីស្រែទាំងនេះ កាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ទៅដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសនៃការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយ ដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្ម ដោយសារតែចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាព ដោយឈ្មួញជាអ្នកកំណត់តម្លៃ។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍឃុំក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងឃុំបច្ចុប្បន្ននេះបានចំទិសដៅ និងមានភាពសមស្រប ដូចជា ការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្មប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល។ បន្ថែមពីលើនេះ ក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគត ដូចជា ត្រូវការសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យកាន់តែប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្ពានប្រឡាយ ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ ជាពិសេសនោះ ការដោះស្រាយដីសម្រាប់លំនៅឋានក្នុងភូមិ ដែលមានស្រាប់ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយនឹងកំណើនប្រជាជន ត្រូវពង្រឹងការធ្វើស្រែឱ្យបាន២ដងក្នុងមួយឆ្នាំនិងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពលសម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវចេញបានចំនួន ២០៧ ២៩៣,១៦ តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញដល់កំណើនសេដ្ឋកិច្ចនៅក្នុងឃុំ។ ការរកឃើញពីភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំសាន់គនាពេលអនាគត បានមកពីការវាយតម្លៃដ៏ត្រឹមត្រូវ ដោយផ្អែកលើធនធានដីរយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះ ដើមដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងឃុំសាន់គទៅអនាគតប្រកបដោយចីរភាព និងសមធម៌។

ដូច្នេះ ដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ស្របទៅតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបទៅដោយចីរភាព និងសមធម៌ រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនាពេលអនាគត ដូចបានរកឃើញមានចែងលម្អិត នៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំសាន់គ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ចៀបចូលនិងផែនការអភិវឌ្ឍឃុំ/សង្កាត់ ឱ្យបានប្រកបទៅដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ។

លេខ៖...១៥៥៣/២០២០...........

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ មេត្តាពិនិត្យ និង សម្រេច។**

ថ្ងៃ...[illegible]......ខែ.កត្តិក. ឆ្នាំ ជូត.ទោស័ក.ព.ស ២៥៦៤

សាន់គ ថ្ងៃទី...២១.....ខែ...តុលា.......ឆ្នាំ២០២០

**មេឃុំសាន់គ**

[illegible]

លេខ៖.....៤០៤ /២០២០................

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ...[illegible]...ខែ.កត្តិក. ឆ្នាំ.ជូត.ទោស័ក.ព.ស ២៥៦៤

កំពង់ស្វាយ ថ្ងៃទី.......០៩..............ខែ.វិច្ឆិកា...ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ**

**អ៊ុន ឃុន**

លេខ៖ ៥៤៥៥/២០២១

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ពុធ [illegible] ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

សុខ លូ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំសាន់គ



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំសាន់គ



# ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំសាន់គ




## សញ្ញាសម្គាល់

**ព្រំប្រទល់ និងទីតាំងរដ្ឋបាល**

- សាលាឃុំ
- ភូមិ
- ព្រំប្រទល់រដ្ឋបាលឃុំ

**ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន**

- មន្ទីរពេទ្យ មណ្ឌលសុខភាព
- វត្ត
- សាលារៀន
- ស្ពាន
- ទ្វារទឹក
- ផ្លូវជាតិលេខ ៦
- ផ្លូវគ្រួសក្រហម ឬក្រាលថ្ម
- ផ្លូវដីស ឬផ្លូវរទេះ
- ប្រឡាយមេ
- ប្រឡាយរង
- ប្រឡាយតូច

**ប្រភេទប្រើប្រាស់ដីបច្ចុប្បន្ន**

- ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ
- ដីកសិកម្ម
- ដីព្រៃ/គម្របព្រៃ
- ផ្ទៃទឹក និងខ្សែទឹក

**ប្រព័ន្ធកូអរដោនេ**

| | | |
|---|---|---|
| ចំណោលផែនទី | : | UTM |
| តំបន់ទី | : | 48N |
| ទិន្នន័យយោង | : | WGS 1984 |
| អេលីបសូអីត | : | WGS 1984 |

**ប្រភពទិន្នន័យ**

-ទីតាំងវិនិយោគ ប្រភពពីផែនការអភិវឌ្ឍឃុំរយៈពេល៥ឆ្នាំនិងអាជ្ញាធរមូលដ្ឋាន
-ទិន្នន័យទីតាំង និងព្រំប្រទល់រដ្ឋបាលប្រភពពីនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៥)
-ទិន្នន័យសំខាន់ៗផ្សេងទៀត ប្រភពពីមន្ទីរ/ស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត

**បញ្ជាក់**

-ព័ត៌មានដែលបង្ហាញនៅលើផែនទីនេះ គឺផ្អែកលើទិន្នន័យដែលបានបង្កើតឡើងដោយថ្នាក់ជាតិនិងត្រូវបានកែសម្រួលដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន
-ព្រំប្រទល់រដ្ឋបាលទាំងនោះ មិនអាចចាត់ទុកជាផ្លូវការ និងខ្សែបន្ទាត់ព្រំដែននៃផែនទីនេះ ពុំមានតម្លៃជាផ្លូវការអន្តរជាតិឡើយ
-ផែនទីនេះត្រូវបានបោះពុម្ពនៅ ខែ.................................. ឆ្នាំ២០.......

# ផែនទីគម្រោងវិនិយោគ ឃុំសាន់គ



# ឯកសារឧបសម្ព័ន្ធ



សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងម្រោងរបស់ក្រុមហ៊ុន



សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីរជុំវិញខេត្តរបស់ក្រុមការងារក្រុមហ៊ុន SBK



កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំសាន់គ



សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំសាន់គ



សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)



កិច្ចប្រជុំក្រុមប្រឹក្សាឃុំសាន់គ ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកំពង់ស្វាយ ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកកំពង់ស្វាយ
ក្រុមប្រឹក្សាឃុំសាន់គ

ថ្ងៃ...........ខែ...........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សាន់គ ថ្ងៃទី...១០....ខែ...........ឆ្នាំ២០២០....

**សេចក្តីជូនដំណឹង**
**ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំសាន់គ**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/០១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

ខ្ញុំបាទបាទជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមក ក្រុមប្រឹក្សាឃុំ សាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា៖ នៅថ្ងៃទី ១០ ខែ...... ឆ្នាំ២០២០... ដល់ថ្ងៃទី...... ខែ...... ឆ្នាំ២០២០.. ឃុំ សាន់គ ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគតដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់ ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យ ផ្តល់យោបល់អោយបានច្រើន កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ជ. ប្រធានក្រុមប្រឹក្សា

សៅ ថ្លុយ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកកំពង់ស្វាយ
ក្រុមប្រឹក្សាឃុំ សាន់គ

**របាយការណ៍បូកសរុប**
**លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង**
**សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ សាន់គ**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំសាន់គ បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំសាន់គ នូវឯកសារផែនទី និងសៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ (បានប្រជុំអនុម័តថ្នាក់ស្រុកកំពង់ស្វាយ រួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី ១០ ខែ...... ឆ្នាំ ២០២០ ដល់ថ្ងៃទី...... ខែ...... ឆ្នាំ ២០២០ មាន រយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

**១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សាន់គ**

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលក្ខិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន

**២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ សាន់គ**

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំសាន់គ



- ចាប់ពី ១.១. ស្ថានភាពឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
- ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន

- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត ២.១.១. ផែនការអភិវឌ្ឍឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន
- **ការវាយតម្លៃ**: ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សាន់គ សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងសម្រេចជំខ្ពង់ខ្ពស់។

ថ្ងៃ............ ឆ្នាំ............ ស័ក ព.ស. ២៥៦៤
សាន់គ ថ្ងៃទី...... ខែ...... ឆ្នាំ ២០២០
ប្រធានក្រុមប្រឹក្សាឃុំ និងជា

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅឃុំសាន់គ



កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ
ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសាន់គ

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពឃុំសាន់គស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត

២. ឯកសារព័ត៌មានស្ថានភាពឃុំសាន់គស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត

៣. ឯកសារព័ត៌មានស្ថានភាពឃុំសាន់គស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត

៤. ឯកសារព័ត៌មានស្ថានភាពឃុំសាន់គស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត

៥. ឯកសារព័ត៌មានស្ថានភាពឃុំសាន់គស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត

៦. ផែនការអភិវឌ្ឍឃុំរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

៧. កម្មវិធីវិនិយោគឃុំសាន់គ ឆ្នាំ២០១៧ របស់ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

៨. របាយការណ៍ស្តីពីការវិភាគប្រព័ន្ធគ្សេត្រ-បរិស្ថាន ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឆ្នាំ២០១៧

៩. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប